សាកលវិទ្យាល័យភូមិន្ទភ្នំពេញ
មហាវិទ្យាល័យអប់រំ

កម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន កម្រិតបរិញ្ញាបត្រ

# មុខវិជ្ជា៖
# ប្រវត្តិសាស្ត្រកម្ពុជាសម័យបុរាណ

កញ្ចប់សមត្ថភាពទី១
ចំណេះដឹងឯកទេសបរិញ្ញាបត្រ



# មុខវិជ្ជា៖
# ប្រវត្តិសាស្ត្រកម្ពុជាសម័យបុរាណ

កញ្ចប់សមត្ថភាពទី ១
ចំណេះដឹងឯកទេសកម្រិតបរិញ្ញាបត្រ

## ការពណ៌នាអំពីមុខវិជ្ជា

**លទ្ធផលសិក្សារំពឹងទុក៖**

*ក្រោយពីបញ្ចប់ការសិក្សាមុខវិជ្ជានេះដោយជោគជ័យអ្នកសិក្សានឹង៖*

លទ្ធផលសិក្សារំពឹងទុកទី ១៖

លទ្ធផលសិក្សារំពឹងទុកទី ២៖

លទ្ធផលសិក្សារំពឹងទុកទី ៣៖

លទ្ធផលសិក្សារំពឹងទុកទី ៤៖

លទ្ធផលសិក្សារំពឹងទុកទី ៥៖

**របៀបវាយតម្លៃសិក្សា**

*ដើម្បីបំពេញគ្រប់លក្ខខណ្ឌបញ្ចប់ការសិក្សាមុខវិជ្ជានេះ អ្នកសិក្សាត្រូវ*

១. វត្តមានចូលសិក្សា ១0%

២. ការចូលរួមសកម្មភាពសិក្សា ២0%

៣. ការវាយតម្លៃកំឡុងពេលសិក្សា ៣0%

៤. ការប្រឡងបញ្ចប់មុខវិជ្ជាសិក្សា ៤0%

**កិច្ចការគ្រូវអនុវត្តដើម្បីសម្រេចលទ្ធផលសិក្សារំពឹងទុក៖**

*ក្រោយពីបញ្ចប់ការសិក្សាមុខវិជ្ជានេះដោយជោគជ័យអ្នកសិក្សានឹង៖*

កិច្ចការទី ១៖

កិច្ចការទី ២៖

កិច្ចការទី ៣៖

កិច្ចការទី ៤៖

កិច្ចការទី ៥៖

## អារម្ភកថា

វិស័យអប់រំ ត្រូវបានរាជរដ្ឋាភិបាលកម្ពុជាចាត់ទុកថាជាវិស័យអាទិភាព និងត្រូវបានធ្វើកំណែទម្រង់ជាប្រចាំឆ្ពោះទៅលើកកម្ពស់គុណភាពនៃការសិក្សានៅគ្រប់កម្រិត។ ក្រសួងអប់រំ យុវជន និងកីឡាបាននិងកំពុងពិនិត្យឡើងវិញកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន និងជំរុញកំណែទម្រង់សាលារៀននៅគ្រប់កម្រិត ដើម្បីធានាថាសាលារៀនមានដំណើរការប្រកបដោយប្រសិទ្ធភាពសម្រាប់ការសិក្សារៀនសូត្ររបស់សិស្ស និងផ្តល់ដល់សិស្សនូវវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា កាយសម្បទា ឆ្លើយតបបានទៅតាមតម្រូវការទីផ្សារការងារ និងចូលរួមចំណែកពេញលេញក្នុងការអភិវឌ្ឍសហគមន៍ និងប្រទេសជាតិ ឈានឆ្ពោះទៅសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០ និងឆ្នាំ២០៥០ ។

ជាផ្នែកមួយនៃកំណែទម្រង់ការបណ្តុះបណ្តាលគ្រូបង្រៀន ឆ្ពោះទៅលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀនតាមរយៈគម្រោងកែលម្អការអប់រំចំណេះទូទៅ ក្រសួងបានរៀបចំ "ក្របខណ្ឌកម្មវិធីសិក្សាសម្រាប់ការបណ្តុះបណ្តាលបរិញ្ញាបត្រអប់រំ វិជ្ជាជីវៈគ្រូបង្រៀន ឯកទេសទាំង ៦ (អក្សរសាស្ត្រខ្មែរ, គណិតវិទ្យា, គីមីវិទ្យា, ជីវវិទ្យា, រូបវិទ្យា, ប្រវត្តិវិទ្យា) ដើម្បីប្រើប្រាស់ក្នុងកម្មវិធីវិក្រឹតការគ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀននៅតាមសាលារៀនចំណេះទូទៅ។ ក្របខណ្ឌកម្មវិធីសិក្សានេះជាឯកសាររស់ ដែលនឹងអាចមានការកែសម្រួលទៅតាមស្ថានភាពជាក់ស្តែង ជាពិសេសនៅដំណាក់កាលអន្តរកាលនៃការអនុវត្តយុទ្ធសាស្ត្រសហគមន៍សាលារៀន។

ក្រសួងមានជំនឿយ៉ាងមុតមាំ លើប្រសិទ្ធភាពនៃការអនុវត្តក្របខណ្ឌកម្មវិធីបណ្តុះបណ្តាលនេះ ដែលនឹងនាំគ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀននៅគ្រប់ភូមិសិក្សា សម្រេចបានគោលដៅអប់រំ ដែលនឹងចូលរួមចំណែកក្នុងការសម្រេចបានចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា។

ខ្ញុំសូមថ្លែងអំណរគុណ និងសូមកោតសរសើរដ៏ស្មោះចំពោះ ឯកឧត្តមបណ្ឌិតសភាចារ្យនាយកគម្រោង និងក្រុមការងារគម្រោងកែលម្អការអប់រំចំណេះទូទៅ ជាពិសេសក្រុមការងារនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញដែលបានខិតខំផលិតឯកសារក្របខណ្ឌកម្មវិធីសិក្សានេះឡើង សម្រាប់ប្រើប្រាស់ក្នុងការបណ្តុះបណ្តាលក្នុងគម្រោងកែលម្អការអប់រំចំណេះទូទៅ។

ថ្ងៃ ចន្ទ ៦ [illegible] ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែសីហា ឆ្នាំ ២០២៣
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

# គណៈកម្មការ

## ១. គណៈកម្មការគ្រប់គ្រង

| | | |
|---|---|---|
| ១. ឯកឧត្តមបណ្ឌិតសភាចារ្យ | **ហង់ជួន ណារ៉ុន** | រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា |
| ២. ឯកឧត្តមបណ្ឌិតសភាចារ្យ | **ណាត ប៊ុនរឿន** | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា |
| ៣. ឯកឧត្តមបណ្ឌិត | **ជេត ជាលី** | សាកលវិទ្យាធិការសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៤. លោកបណ្ឌិត | **ឈុន ហុក** | សាកលវិទ្យាធិការរង សាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៥. លោក | **ប៉ាល់ ដែល** | សាកលវិទ្យាធិការរង សាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៦. លោកបណ្ឌិត | **សំអោ អន្តារតន៍** | អគ្គនាយករង អគ្គនាយកដ្ឋានគោលនយោបាយ និងផែនការ |
| ៧. លោក | **ព្រឹង មរកត** | ប្រធាននាយកដ្ឋានមធ្យមសិក្សា |

## ២. គណៈកម្មការនិពន្ធ រៀបរៀង និងចងក្រង

| | | |
|---|---|---|
| ១. លោកបណ្ឌិត | **សុខ សុត្រា** | ព្រឹទ្ធបុរសមហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ២. លោក | **មាក ភារម៉ោន** | ព្រឹទ្ធបុរសមហាវិទ្យាល័យវិទ្យាសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៣. លោកបណ្ឌិត | **ជ័យ ចាន់អឿន** | ព្រឹទ្ធបុរសរងមហាវិទ្យាល័យវិទ្យាសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៤. លោកបណ្ឌិត | **ម៉ម សុជាតិ** | ព្រឹទ្ធបុរសរងមហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៥. លោក | **សុត វិសាល** | ប្រធានដេប៉ាតឺម៉ង់សិក្សាអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៦. លោកបណ្ឌិត | **ឃុន គឹមលាង** | ប្រធានដេប៉ាតឺម៉ង់រូបវិទ្យានៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៧. លោកស្រីបណ្ឌិត | **ស៊ូ កល្យាណ** | អនុប្រធានដេប៉ាតឺម៉ង់រូបវិទ្យានៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៨. លោក | **ហង់ ស៊ីម** | សាស្ត្រាចារ្យដេប៉ាតឺម៉ង់រូបវិទ្យានៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៩. លោក | **ដួង ប៉េងអាន** | អ្នកសម្របសម្រួលកម្មវិធីមធ្យមសិក្សា មហាវិទ្យាល័យអប់រំ |
| ១០. កញ្ញា | **ហុង ឡៃហៀក** | បុគ្គលិកមហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ១១. លោក | **សើ ពន្លក** | បុគ្គលិកមហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |

## ៣. គណៈកម្មការត្រួតពិនិត្យ និងកែលម្អ

| | | |
|---|---|---|
| ១. លោកបណ្ឌិត | **សំអោ អន្តារតន៍** | អគ្គនាយករង អគ្គនាយកដ្ឋានគោលនយោបាយ និងផែនការ |
| ២. លោក | **ព្រឹង មរកត** | ប្រធាននាយកដ្ឋានមធ្យមសិក្សា |
| ៣. លោក | **ម៉ៅ ប៉េងឡុង** | ប្រធាននាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹត្យការ |
| ៤. ឯកឧត្តមបណ្ឌិត | **សិត សេង** | នាយកវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ |
| ៥. លោកបណ្ឌិត | **ឈុក ច័ន្ទឆាយា** | អនុប្រធាននាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹត្យការ |
| ៦. លោក | **កែវ សារ៉ាត់** | ទីប្រឹក្សាបច្ចេកទេសគម្រោងកែលម្អការអប់រំចំណេះទូទៅ |

## ៤. ការីកុំព្យូទ័រ

| | | |
|---|---|---|
| ១. លោក | **ម៉ៅ ម៉ារ៉ាឌី** | បុគ្គលិកមហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ២. លោក | **ឱន សំណាង** | បុគ្គលិកមហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |

## លទ្ធផលសិក្សារំពឹងទុក

ការសិក្សាក្នុងកម្មវិធីនេះគឺផ្តោតលើប្រតិបត្តិជាក់ស្តែងរបស់អ្នកសិក្សាដែលអនុវត្តផ្ទាល់នៅសាលារៀន។ ទាំងអ្នកសិក្សា និងសិស្ស (ដែលអ្នកសិក្សានឹងធ្វើការជាមួយផ្ទាល់) ចាំបាច់មាន (១) បំណិនចិត្តសង្គម (២) បំណិនពុទ្ធិ និង (៣) បំណិនបច្ចេកទេស ជាមូលដ្ឋាន (ដូចក្នុងរូបទី១)។ កញ្ចប់សមត្ថភាពទាំងបីខាងដើមនឹងជួយឱ្យអ្នកសិក្សា អភិវឌ្ឍបំណិនចិត្តសង្គម បំណិនពុទ្ធិ និងពង្រឹងសមត្ថភាពផ្នែក (ក)ការសម្រេចចិត្ត ទំនាក់-ទំនង សេចក្តីអំណត់ ទឹកចិត្តអាណិតអាសូរ និងការគ្រប់គ្រងខ្លួនឯង ថែមទាំងអាចអនុវត្តការបង្រៀនមុខវិជ្ជា ឯកទេសរូបវិទ្យាប្រកបដោយវិជ្ជាជីវៈ និងនវានុវត្តន៍ដោយប្រើប្រាស់ឧត្តមានុវត្តន៍ផ្សេងៗ (ខ) ការដោះស្រាយបញ្ហា និង ការរៀបចំនិងការចាត់ចែង (គ) បច្ចេកទេសកម្រិតមធ្យម និងកម្រិតខ្ពស់។




*រូបភាពទី១*
*ប្រភព៖ WDR2018 (p.103)*

ដោយឡែក សម្រាប់អ្នកសិក្សាកម្មវិធីនេះផ្ទាល់ នឹងទទួលបាន៖

**(១) ចំណេះដឹងឯកទេសប្រវត្តិវិទ្យាកម្រិតបរិញ្ញាបត្រ**

- ប្រវត្តិសាស្ត្រកម្ពុជាសម័យបុរាណ
- ប្រវត្តិសាស្ត្រកម្ពុជាសម័យទំនើប
- ទ្រឹស្តីប្រវត្តិសាស្ត្រ
- ប្រវត្តិសាស្ត្រពិភពលោក
- ប្រវត្តិសាស្ត្រអាស៊ីអាគ្នេយ៍
- ចិត្តសង្គម ភាពជាអ្នកដឹកនាំ និងគ្រប់គ្រង
- សន្លឹកកិច្ចការស្វ័យសិក្សានៅមធ្យមសិក្សា
- ការសរសេរ និងការពារឯកសារជំនួយស្មារតីមុខវិជ្ជាឯកទេសប្រវត្តិវិទ្យា

**(២) ចំណេះដឹងវិធីគរុកោលស្យ សាស្ត្រូបង្រៀន និងការអប់រំប្រវត្តិវិទ្យាកម្រិតមធ្យមសិក្សា**

- ❖ វិធីសាស្ត្របង្រៀន
- ❖ វិធីសាស្ត្រវង្វាយតម្លៃ
- ❖ ការស្រាវជ្រាវប្រតិបត្តិ
- ❖ ប្រឹក្សាគរុកោសល្យ
- ❖ បំណិនឌីជីថលសម្រាប់ការអប់រំ

**(៣) ហ្វឹកហាត់កម្មសិក្សាគរុកោលស្យ និងការអនុវត្តជាក់ស្តែង**

- ❖ អនុវត្តស្តង់ដា នៃយុទ្ធសាស្ត្រសហគមន៍សាលារៀន
- ❖ ការអនុវត្តកម្មវិធីស្វ័យសិក្សារូបវិទ្យា ពីទីថ្នាក់៧-ទី១២
- ❖ របាយការណ៍នៃការអនុវត្តស្តង់ដា នៃយុទ្ធសាស្ត្រសហគមន៍សាលារៀន

លទ្ធផលសិក្សារំពឹងទុកសម្រាប់បរិញ្ញាបត្រអប់រំវិជ្ជាជីវៈគ្រូបង្រៀននេះ ត្រូវបានកំណត់ដូចខាងក្រោម៖

***វិជ្ជាសម្បទា***

PLO1- ពន្យល់អំពីទ្រឹស្តី និងគោលការណ៍នៃការអប់រំក្នុងបរិបទសកលលោក និងបរិបទប្រទេសដើម្បីឆ្លុះបញ្ចាំងទៅនឹងការអនុវត្តជាក់ស្តែងនៃការបង្រៀន។

PLO2- បកស្រាយអំពីដំណើរការអនុវត្តកិច្ចការសម្រាប់ការបង្វឹកលើការរៀបចំកម្មវិធីសិក្សា និងការបង្រៀនប្រវត្តិវិទ្យាប្រកបដោយប្រសិទ្ធភាព។

***បំណិនសម្បទា***

PLO3- អនុវត្តបំណិនចិត្តសង្គម និងបច្ចេកវិទ្យាឌីជីថលសម្រាប់បង្កើនការប្រាស្រ័យទាក់ទងគ្នាក្នុងការងារ និងជីវភាពប្រកបដោយវិជ្ជាជីវៈ និងដោះស្រាយបញ្ហាប្រកបដោយភាពច្នៃប្រឌិត និងការទទួលខុសត្រូវ។

PLO4- បង្កើតគន្លឹះ និងទម្រង់សម្រាប់ដឹកនាំ និងគ្រប់គ្រងការបង្រៀនដោយផ្តោតលើផលសម្រេចនៃការសិក្សារបស់សិស្សឆ្ពោះទៅរកស្តង់ដាសាលារៀនមានប្រសិទ្ធភាព និងនិរន្តភាពសាលារៀនតាមរយៈការសិក្សា ការអនុវត្តជាក់ស្តែង និងការស្រាវជ្រាវ។

PLO5- អនុវត្តការងារអភិវឌ្ឍកម្មវិធីសិក្សា ការរៀននិងការបង្រៀនរូបវិទ្យា និងការសិក្សាបែបគម្រោងភ្ជាប់នឹងបំណិនរកចំណូលសម្រាប់សាលារៀនប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ។

***ចរិយាសម្បទា***

PLO6- អភិវឌ្ឍឥរិយាបថវិជ្ជមាន និងវប្បធម៌រៀនពេញមួយជីវិតសម្រាប់បំពេញការងារ និងទាក់ទងជាមួយអ្នកដទៃប្រកបដោយគុណតម្លៃ មនុស្សធម៌ សាមគ្គីភាព និងការចែករំលែកគ្នា។

PLO7- បង្កើត/បង្ហាញការដឹកនាំបណ្តាញសម្រាប់កសាងភ្នាក់ងារពង្រីកឧត្តមានុវត្តន៍សម្រាប់ការរៀន និងការបង្រៀន។

សម្គាល់៖ Program Learning Outcome (PLO) លទ្ធផលសិក្សាកម្មវិធីអប់រំ

## កញ្ចប់សមត្ថភាព និង រចនាសម្ព័ន្ធកម្មវិធីសិក្សា

កម្មវិធីបរិញ្ញាបត្រអប់រំវិជ្ជាជីវៈគ្រូបង្រៀននេះ តម្រូវឱ្យអ្នកសិក្សាសិក្សាចំនួន ៦៣ ក្រេឌីតដែលមានរយៈពេលចន្លោះពី ១២ ទៅ ១៨ខែ។ ការសិក្សានិងធ្វើឡើងតាមរយៈការរៀនពីចម្ងាយ (ភាគច្រើនចន្លោះពី ៦០% ទៅ ៧០%) និងសិក្សាផ្ទាល់នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញនិង សាលាហាត់ការ (ភាគតិចចន្លោះពី ៤០% ទៅ ៣០%)។ ការសិក្សាផ្តោតលើបណ្តុំមុខវិជ្ជា (១)ចំណេះដឹងឯកទេសកម្រិតបរិញ្ញាបត្រ (៣៦ ក្រេឌីត) (២)ចំណេះដឹងគរុកោសល្យ វិធីសាស្ត្របង្រៀន និងការអប់រំមធ្យមសិក្សា (១២ (+៣) ក្រេឌីត) (៣) ហ្វឹកហាត់កម្មសិក្សាគរុកោសល្យ និងការអនុវត្តជាក់ស្តែង(១២ ក្រេឌីត)។ បន្ថែមពីលើនេះទៀតអ្នកសិក្សាត្រូវអនុវត្តខ្លឹមសារមេរៀនដែលបានសិក្សាក្នុងកម្មវិធីនៅសាលាសាមីផ្ទាល់តែម្តងដោយមានការណែនាំពីគ្រូបង្វឹក ប្រឹក្សាគរុកោសល្យ គ្រូបង្រៀននៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងមន្ត្រីអប់រំមកពីនាយកដ្ឋានជំនាញផ្សេងៗរបស់ក្រសួងអប់រំ យុវជន និងកីឡាដែលមានបទពិសោធន៍អនុវត្តជាក់ស្តែងកន្លងមក ។

| បណ្តុំមុខវិជ្ជា | ចំនួនក្រេឌីត |
|---|---|
| (១)ចំណេះដឹងឯកទេសកម្រិតបរិញ្ញាបត្រ (៦០%) | ៣៦ |
| (២)ចំណេះដឹងគរុកោសល្យ វិធីសាស្ត្របង្រៀន និងការអប់រំមធ្យមសិក្សា (២០%) | ១២ (+៣) |
| (៣)ហ្វឹកហាត់កម្មសិក្សាគរុកោសល្យ និងការអនុវត្តជាក់ស្តែង (២០%) | ១២ |
| សរុប | ៦០ (+៣) |

***សម្គាល់៖*** *សម្រាប់កញ្ចប់សមត្ថភាពចំណេះដឹងគរុកោសល្យ វិធីសាស្ត្របង្រៀន និងការអប់រំមធ្យមសិក្សាបានបន្ថែមមុខវិជ្ជាបំណិនឌីជីថលសម្រាប់ការអប់រំចំនួន ៣ក្រេឌីត*

## លក្ខណៈទូទៅនៃមុខវិជ្ជាសិក្សា

មុខវិជ្ជាសិក្សាសម្រាប់កម្រិតបរិញ្ញាបត្រអប់រំនេះនឹងជួយឱ្យអ្នកសិក្សាបំពេញកញ្ចប់សមត្ថភាពដូចខាងក្រោម ដើម្បីឆ្លើយតបនឹងលទ្ធផលសិក្សាកម្មវិធីអប់រំហើយឱ្យអ្នកសិក្សាមានសមត្ថភាពសម្រាប់បំពេញការងារប្រកបដោយវិជ្ជាជីវៈ។

| បណ្តុំមុខវិជ្ជា | មុខវិជ្ជាសិក្សា | ក្រេឌីត |
|---|---|---|
| (១)ចំណេះដឹងឯកទេសកម្រិតបរិញ្ញាបត្រ (៦០%) | ប្រវត្តិសាស្ត្រកម្ពុជាសម័យបុរាណ | ៣ |
| | ប្រវត្តិសាស្ត្រកម្ពុជាសម័យទំនើប | ៣ |
| | ទ្រឹស្តីប្រវត្តិសាស្ត្រ | ៣ |
| | ប្រវត្តិសាស្ត្រពិភពលោក | ៣ |
| | ប្រវត្តិសាស្ត្រអាស៊ីអាគ្នេយ៍ | ៣ |
| | ការអនុវត្តសន្លឹកកិច្ចការឯកទេសប្រវត្តិវិទ្យាសម្រាប់សិស្សស្វ័យសិក្សាកម្រិត១ (ចងចាំ) | ៣ |
| | ការអនុវត្តសន្លឹកកិច្ចការឯកទេសប្រវត្តិវិទ្យាសម្រាប់សិស្សស្វ័យសិក្សាកម្រិត២ (យល់ដឹង) | ៣ |
| | សន្លឹកកិច្ចការឯកទេសប្រវត្តិវិទ្យាសម្រាប់សិស្សស្វ័យសិក្សាកម្រិត៣ (ហ្វឹកហាត់) | ៣ |
| | សន្លឹកកិច្ចការឯកទេសប្រវត្តិវិទ្យាសម្រាប់សិស្សស្វ័យសិក្សាកម្រិត៤ (វាយតម្លៃ) | ៣ |

| | | |
|---|---|---|
| | ការសរសេរ និងការពារឯកសារជំនួយស្មារតីមុខវិជ្ជាឯកទេស | ៩ |
| (៣)ចំណេះដឹងគរុកោសល្យ វិធីសាស្ត្របង្រៀន និង ការអប់រំមធ្យមសិក្សា (២០%) | វិធីសាស្ត្របង្រៀន បត់បែនតាមសមត្ថភាពសិស្ស និងទស្សនទានអប់រំថ្មីៗ | ៣ |
| | ប្រឹក្សា និងហ្វឹកហ្វឺនគរុសល្យលើយុទ្ធសាស្ត្រសហគមន៍សាលារៀន | ៣ |
| | មូលដ្ឋានគ្រឹះវង្វាយតម្លៃអប់រំ | ៣ |
| | មូលដ្ឋានគ្រឹះនៃការស្រាវជ្រាវប្រតិបត្តិ | ៣ |
| | បំណិនឌីជីថលសម្រាប់ការអប់រំ * | ៣ |
| (៤)ហ្វឹកហាត់កម្មសិក្សា គរុកោសល្យ និងការអនុវត្តជាក់ស្តែង (២០%) | ការអនុវត្ត ស្តង់ដាយុទ្ធសាស្ត្រសហគមន៍សាលារៀន (ស្តង់ដាទី១) | ៣ |
| | ការអនុវត្ត ស្តង់ដានៃយុទ្ធសាស្ត្រសហគមន៍សាលារៀន (ស្តង់ដាទី២) | ៦ |
| | របាយការណ៍និងការការពារស្តីពីការអនុវត្តស្តង់ដាយុទ្ធសាស្ត្រ សហគមន៍សាលារៀន | ៣ |
| **សរុប** | | **៦៣** |

## លំហូរបង្រៀន និងរៀន

**លំហូរបង្រៀននិងរៀន ១មេរៀន ឬកិច្ចការមួយ រួមជាមួយបំណិនមួយ និងចរិយាមួយ**




## ការវាយតម្លៃលើការសិក្សា

ការវាយតម្លៃលើការសិក្សារបស់អ្នកសិក្សាគឺផ្តោតលើលទ្ធផលសិក្សាជាគោល។ ការវាយតម្លៃលើការសិក្សាមានបីដំណាក់កាលធំៗ គឺ (១) ការវាយតម្លៃលើការសិក្សាមុខវិជ្ជា (២) ការវាយតម្លៃលើការសរសេរឯកសារជំនួយស្មារតីមុខវិជ្ជាឯកទេស និង (៣) ការវាយតម្លៃសរុបដោយពិនិត្យលើការបំពេញគ្រប់លក្ខខណ្ឌសម្រាប់បញ្ចប់ការសិក្សា។

### ៦.៤.១ គោលការណ៍វាយតម្លៃ

គោលការណ៍រួមសម្រាប់ការវាយតម្លៃលើការសិក្សារបស់អ្នកសិក្សាមានដូចតទៅ៖

១) អ្នកសិក្សាតម្រូវឱ្យមានវត្តមានក្នុងការសិក្សាតាមមុខវិជ្ជានីមួយៗ មិនតិចជាង៧០%។ ក្នុងករណីអ្នកសិក្សាមានវត្តមានតិចជាង៧០% នឹងមិនត្រូវបានអនុញ្ញាតឱ្យប្រឡងបញ្ចប់មុខវិជ្ជានោះទេ

២) ក្នុងករណីដែលអ្នកសិក្សាធ្លាក់មុខវិជ្ជាណាមួយក្នុងឆមាស នឹងមិនអនុញ្ញាតឱ្យបន្តការសិក្សាទៅឆ្នាំបន្ទាប់ និងប្រឡងបញ្ចប់ឡើយ

៣) អ្នកសិក្សាទាំងអស់ត្រូវធ្វើកិច្ចការស្រាវជ្រាវសំខាន់ៗតាមមុខវិជ្ជានីមួយៗ និងប្រគល់ជូនគ្រូឧទ្ទេសតាមមុខវិជ្ជាដែលបានកំណត់

៤) អ្នកសិក្សាត្រូវប្រឡងបញ្ចប់ការសិក្សាដែលធ្វើឡើងបន្ទាប់ពីចប់ឆមាសនីមួយៗ តាមការកំណត់ក្នុងកម្មវិធីសិក្សា

៥) អ្នកសិក្សាត្រូវចងក្រងឯកសារវឌ្ឍនភាពនៃកិច្ចការស្នូលរួមមានការហាត់ការ និងកម្មសិក្សាដែលផ្ដោតលើ (ក) សកម្មភាពប្រតិបត្តិ (ខ) លទ្ធផលដែលសម្រេចបាន និង (គ) ការឆ្លុះបញ្ចាំង និងមេរៀនបទពិសោធន៍ និង

៦) អ្នកសិក្សាត្រូវតែជាប់មធ្យមភាគនៃការសិក្សាមុខវិជ្ជានិងការធ្វើកម្មសិក្សា ដើម្បីទទួលការអនុញ្ញាតឱ្យការពារឯកសារជំនួយស្មារតីមុខវិជ្ជាឯកទេស។

## ការផ្ដល់ពិន្ទុ និងប្រព័ន្ធចំណាត់ថ្នាក់

អ្នកសិក្សាអាចទទួលពិន្ទុចាប់ពី 00 ដល់ 100 ទៅតាមការវាយតម្លៃផ្អែកលើលក្ខណៈវិនិច្ឆ័យដែលបានកំណត់ក្នុងការសិក្សាមុខវិជ្ជា ការបំពេញកម្មសិក្សា និងការសរសេរនិងការការពារឯកសារជំនួយស្មារតីមុខវិជ្ជាឯកទេស។ ពិន្ទុដែលជាប់ត្រូវចាប់ផ្ដើមពីមធ្យមភាគពិន្ទុ 50% ឬពិន្ទុនិទ្ទេស 2.00 ឡើងទៅ។

ពិន្ទុគឺកំណត់ពី 00.00 ដល់ 100 (មធ្យមភាគនៃពិន្ទុនិទ្ទេសសរុប ឬ Grade Point Average–GPA)។ រូបមន្តគណនារកមធ្យមភាគនៃពិន្ទុនិទ្ទេសសរុប (GPA) គឺមធ្យមភាគនៃពិន្ទុនិទ្ទេសសរុប (GPA) ស្មើផលបូកសរុបរវាងផលគុណនៃពិន្ទុនិទ្ទេស (Grade Point–P) និងតម្លៃក្រេឌីតដែលត្រូវយកនៃមុខវិជ្ជានីមួយៗ (Attempted Credit Value–C) ចែកនឹងផលបូកសរុបនៃតម្លៃក្រេឌីតដែលត្រូវយកគ្រប់មុខវិជ្ជា។

ប្រព័ន្ធចំណាត់ថ្នាក់កម្មវិធី គឺផ្អែកទៅលើតម្លៃនៃពិន្ទុអតិបរមា 100% និង 50% នៃពិន្ទុអប្បបរមា។ ប្រព័ន្ធដាក់ពិន្ទុនេះ ត្រូវបានបកប្រែទៅជា «ពិន្ទុជានិទ្ទេស» និង «ពិន្ទុជាតម្លៃលេខ» ដូចដែលពិពណ៌នាខាងក្រោម៖

| ពិន្ទុជាភាគរយ% | និទ្ទេស | ពិន្ទុនិទ្ទេស | មូលវិចារណ៍ |
|---|---|---|---|
| 85%-100% | A | 4.00 | ល្អប្រសើរ |
| 80%-84% | B+ | 3.50 | ល្អណាស់ |
| 70%-79% | B | 3.00 | ល្អ |
| 65%-69% | C+ | 2.50 | ល្អបង្គួរ |
| 50%-64% | C | 2.00 | មធ្យម |
| <49% | F | 1.50 | ធ្លាក់ |

## ៦.៥ គោលការណ៍ប្រតិបត្តិ

ដើម្បីធានានូវការផ្តល់សេវាអប់រំប្រកបដោយគុណភាព និងភាពស័ក្តិសិទ្ធិ មហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញអនុវត្តតាមគោលការណ៍ បទបញ្ញត្តិ និងបទដ្ឋានគតិយុត្តិរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងគោលការណ៍ច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

ជាមួយគ្នានេះដែរ អ្នកសិក្សាម្នាក់ៗ ត្រូវគោរពតាមបទបញ្ជាផ្ទៃក្នុងរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងឈរលើស្មារតីស្មោះត្រង់ ទទួលខុសត្រូវខ្ពស់ និងភាពម្ចាស់ការ និងគោលការណ៍សុចរិតភាពនៃការសិក្សា។ សម្រាប់គោលការណ៍សុចរិតភាពនៃការសិក្សា អ្នកសិក្សាម្នាក់ៗ ត្រូវបានវាយតម្លៃលើចំណុចសំខាន់ៗដូចខាងក្រោម៖

### ៦.៥.១ ការវាយតម្លៃលើវិន័យ សីលធម៌ ឥរិយាបថ និងអាកប្បកិរិយា

ការវាយតម្លៃលើវិន័យ សីលធម៌ ឥរិយាបថ និងអាកប្បកិរិយារបស់អ្នកសិក្សាម្នាក់ៗ ត្រូវបានប្រមូលផ្តុំលើការគោរពវិន័យចាត់តាំង ការមករៀនទៀងទាត់ ការយកចិត្តទុកដាក់ក្នុងការសិក្សា ការខិតខំស្រាវជ្រាវ ការអនុវត្តភារកិច្ច និងស្មារតីសាមគ្គីភាពនៅក្នុងថ្នាក់ ក្នុងគ្រឹះស្ថានសិក្សា និងក្រៅគ្រឹះស្ថានសិក្សា។ ការវាយតម្លៃលើវិន័យ សីលធម៌ ឥរិយាបថ និងអាកប្បកិរិយារបស់អ្នកសិក្សាម្នាក់ៗ ត្រូវបានធ្វើឡើងតាមរយៈយោបល់ឯកភាពពីមតិភាគច្រើនដាច់ខាតរបស់ក្រុមប្រឹក្សាវិន័យ ដោយផ្អែកលើលក្ខណសម្បត្តិជាក់ស្តែងរបស់អ្នកសិក្សាម្នាក់ៗ និងបទបញ្ជាផ្ទៃក្នុងរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

### ៦.៥.២ ការក្លែងបន្លំឯកសារ

អ្នកសិក្សាដែលក្លែងបន្លំឯកសារ នឹងត្រូវលុបឈ្មោះចេញពីបញ្ជីនិស្សិតដោយស្វ័យប្រវត្តិ ព្រមទាំងទទួលទោសតាមច្បាប់ជាធរមាន។ អ្នកសិក្សាត្រូវចាំថា ការលួចចម្លងស្នាដៃ ការលួចកម្មសិទ្ធិបញ្ញា និងគំនិតរបស់អ្នកដទៃគឺជាបទល្មើសសិក្សាធ្ងន់ធ្ងរដែលអាចឈានដល់ការបញ្ឈប់បុគ្គលដែលប្រព្រឹត្តបទល្មើសពីកម្មវិធី។ ត្រូវសម្រេចឱ្យធ្លាក់ជាស្ថាពរ បើអ្នកសិក្សារូបណាចម្លងដោយផ្ទាល់ពីអ្នកសិក្សាដទៃទៀត ឬប្រភពផ្សេងៗ ឬការប្រើសម្ភារៈ ឬឯកសារផ្សេងទៀត ដែលមិនត្រូវបានអនុញ្ញាតក្នុងការប្រឡង។

### ៦.៥.៣ ឯកសារជំនួយស្មារតី/របាយការណ៍/កិច្ចការស្រាវជ្រាវ

អ្នកសិក្សាត្រូវបង្ហាញនូវសុចរិតភាពនៃការស្រាវជ្រាវរបស់ខ្លួនឱ្យបានខ្ជាប់ខ្ជួន ចាប់តាំងពីពេលចូលរៀនរហូតដល់ចុងបញ្ចប់នៃវគ្គបណ្តុះបណ្តាល។ រាល់សំណេរការងារសិក្សាទាំងអស់ មិនត្រូវដកស្រង់គំនិត សរសេរ ឬចម្លងស្នាដៃផ្សេងៗរបស់អ្នកដទៃមកធ្វើជាគំនិត ជាស្នាដៃ ឬជាកម្មសិទ្ធិរបស់ខ្លួនដោយគ្មានការបញ្ជាក់ពីប្រភពច្បាស់លាស់នៃឯកសារយោង ឯកសារពិគ្រោះ ឬការអនុញ្ញាតពីម្ចាស់ប្រភព។

ក្នុងករណីរកឃើញមានការលួចចម្លងស្នាដៃអ្នកដទៃ អ្នកសិក្សានឹងត្រូវប្រឈមមុខចំពោះក្រុមប្រឹក្សាបច្ចេកទេស និងក្រុមប្រឹក្សាវិន័យរបស់មហាវិទ្យាល័យអប់រំ ឬសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដោយត្រូវទទួលពិន័យឱ្យរៀនត្រួតថ្នាក់ ឬអាចត្រូវបញ្ឈប់ពីកម្មវិធីដោយគ្មានសំណងប្រាក់សិក្សាដែលបានបង់រួចហើយ និងមិនមានការចេញលិខិតស្នាមបញ្ជាក់ការសិក្សាអ្វីដែរ។

**សម្គាល់៖** កម្មវិធីបណ្តុះបណ្តាលសូមរក្សាសិទ្ធិក្នុងការកែប្រែការអនុវត្តជាក់ស្តែងឱ្យឆ្លើយតបទៅនឹងវឌ្ឍនភាពការរៀននិងបង្រៀន សមត្ថភាពរៀននិងការអនុវត្តជាក់ស្តែង និង ស្ថានភាពរៀននិងបង្រៀនជាក់ស្តែង ដើម្បីសម្រេចបានលទ្ធផលសិក្សាល្អបំផុត និងសម្រេចស្តង់ដាសហគមន៍សាលារៀននៃគម្រោងកែលម្អការអប់រំចំណេះទូទៅ (GEIP) ។

# មុខវិជ្ជា៖ ប្រវត្តិសាស្ត្រកម្ពុជាបុរាណ

## ដោយសាស្ត្រាចារ្យបណ្ឌិត វង់ សុធារ៉ា

## មេរៀនទី១៖ សេចក្តីផ្តើម

ប្រវត្តិវិទ្យា =ការសិក្សាអំពីជីវភាពមនុស្សពីអតីតកាល （ថែមសិក្សាអំពីចំណេះដឹង និងបទពិសោធន៍អតីតកាលរបស់មនុស្ស ដោយពឹងផ្អែកលើប្រភព/សម្រាប់សហសម័យ អាចថែម ដោយពឹងបន្ថែមលើឯកសាររស់ ឬសាក្សីរស់)

ប្រវត្តិសាស្ត្រ = កម្រងរឿងរ៉ាវអតីតកាល

ខេមរយានកម្ម Khmerisation 1965-66-67

Histoire / History = ប្រវត្តិវិទ្យា/ប្រវត្តិសាស្ត្រ

ប្រវត្តិវិទ្យា

វិទ្យាសាស្ត្រ = ក្បួន ច្បាប់ តម្រា ដែលចងក្រងឡើងដោយ
ពឹងផ្អែកលើភស្តុតាង

*- សតវត្សរ៍ < ឝតវត្សរ = រយឆ្នាំ = 100 ឆ្នាំ = Century

ឆ្នាំ ១ ដល់១០០ = សតវត្សរ៍ទី១ = $1^{st}$ Century / 1er Siècle

ឆ្នាំ ១០១ដល់២០០ = សតវត្សរ៍ទី២ = $2^{nd}$ century

ឆ្នាំ ១៩០១ដល់២០០០ = សតវត្សរ៍ទី២០ = $20^{th}$ century

ឆ្នាំ២០០១ដល់២១០០ = សតវត្សរ៍ទី២១ = $21^{st}$ century

ឆ្នាំ១៧៩៥ = សតវត្សរ៍ទីប៉ុន្មាន?

១៧៩៥/១០០= 17 + 95 = សតវត្សរ៍ទី១៨

១៨០១ = $19^{th}$ century

សម្រាក ១៥នាទី 9:50 បន្តទៀត

ទសវត្សរ៍ = ១០ឆ្នាំ = Decade

ទសវត្សរ៍ឆ្នាំ១៩០០ = ឆ្នាំ១៩០០ ដល់ ១៩០៩

ទសវត្សរ៍ឆ្នាំ១២២០ = ឆ្នាំ១២២០ ដល់១២២៩

ទសវត្សរ៍ឆ្នាំ១៩៨០= ឆ្នាំ១៩៨០ដល់១៩៨៩

ទសវត្សរ៍ឆ្នាំ២០២០= ឆ្នាំ២០២០ដល់២០២៩

ទសវត្សរ៍ឆ្នាំ៥០ = ឆ្នាំ៥០ ដល់ ៥៩

ទសវត្សរ៍ឆ្នាំ៦៥០ = ឆ្នាំ៦៥០ ដល់ ៦៥៩

*- សករាជ?

ព.ស.២៥៦៧ = ពុទ្ធសតវត្សរ៍ ទី២៦

- ថៃ រាប់ពុទ្ធសករាជ ចាប់ពីថ្ងៃ១មករា(សុរិយគតិ) ចាប់ពីទសវត្សរ៍ឆ្នាំ១៩៥០

- ខ្មែរ រាប់ពុទ្ធសករាជ ចាប់ពីថ្ងៃ/តិថី ១រោចខែពិសាខ (ចន្ទគតិ)

* ពុទ្ធសករាជ កើតមុនគ្រឹស្តសករាជ ៥៤៣ឆ្នាំ ១រោច ពិសាខ

* មហាសករាជ ឬ គក/សក កើតក្រោយគ្រឹស្តសករាជ ៧៨/៧៩ឆ្នាំ ដោយសារសករាជនេះរាប់ចាប់ពីថ្ងៃ១កើតខែចេត្រ

* ឝក៏ = ឈ្មោះស្តេចដើមនៃរាជវង្សសកៈ នាំឱ្យខ្មែរហៅ «សករាជ»

** ក្រោយពេលយើងរាប់កាលបរិច្ឆេទតាមព្រឹត្តិការណ៍ព្រះពុទ្ធបរិនិព្វាន និងរាប់តាមកាលបរិច្ឆេទនៃស្តេចចុល្ល ឬ ចោឡ នាំឱ្យយើងខ្ចីពាក្យ «សករាជ» ដំបូងមកប្រើជាគោលវិញមាន ពុទ្ធសករាជ, «សករាជ» ក្លាយជាមហាសករាជ, ដោយធៀបសករាជកើតក្រោយគេ គឺ ចុល្លសករាជ ។

* គ្រឹស្តសករាជ = គ.ស. រាប់ចាប់ពីថ្ងៃ១មករា (ក្រោយពេលព្រះយេស៊ូគ្រឹស្តប្រសូតបាន១សប្តាហ៍/៧ថ្ងៃ, ២៥ធ្នូឆ្នាំសូន្យ)

** របៀបរាប់លេខខ្មែរបុរាណ ៖

- ខ្នងរាយ មាន៥តួឯករាជ្យ៖ មួយ/ម្វាយ =មួយ, វ្យារ៑/វេរ៑/ព្យារ = ពីរ, បី/បិយ៑=បី, ប្វន៑/ប្វាន៑= បួន, ប្រំ/ប្រាំ=ប្រាំ, ប្រាំមួយ៑, ប្រំវ្យារ៑, ប្រំបី, ប្រាំប្វាន៑, តប៑/តប្ប

- លេខខ្មែរខ្ទង់«ដប់» រាប់បានពីររបៀប គឺពីឆ្វេងទៅស្តាំ (របៀបរាប់របស់ខ្មែរ) និងពីស្តាំទៅឆ្វេង (របៀបរាប់របស់ឥណ្ឌា)

ដប់មួយ ដប់ពីរ/តប៑វ្យរ៑ ដប់បី ដប់បួន ដប់ប្រាំ...= មួយទន្ដប់, ពីរទន្ដប់, បីទន្ដប់, បួនទន្ដប់, ប្រាំទន្ដប់ ....

ម្វយកៃយ៑/ភយ៑ => ម្ភៃ = វិង្សោត្តរ

កៃយ៑ម្វយ៑ម្វយ៑ = ម្ភៃមួយ

កៃម្វយ៑ប្រំប្វន៑ = ម្ភៃប្រាំបួន = ឯកុនតឹង្សា

កៃម្វយ៑តប៑ = សាមសិប = (បីដប់) = ត្រីគោត្តរ

វ្យរ៑កៃយ៑ = សែសិប = (បួនដប់) = ចត្តាឡីស

កៃវ្យរ៑វ្យរ៑ = សែសិបពីរ

កៃវ្យរ៑តប៑ = ហាសិប = (ប្រាំដប់) = ?

បីកៃយ៑ = ហុកសិប = (ប្រាំមួយដប់) = ឆទ្យុត្តរ

កៃបីប្រាំម្វយ៑ = ហុកសិបប្រាំមួយ

កៃបីតប៑ = ចិតសិប = (ប្រាំពីរដប់) = សប្តោត្តរ

ប្វនិ/ប្វានិកៃ = ប៉ែតសិប = (ប្រាំបីដប់) = អស្ដោត្តរ

កៃប្វនិតបិ = កៅសិប = (ប្រាំបួនដប់) = នវត្យុត្តរ

ឝត > សត = រយ (ភាសាថៃ)

វត្សរ / វច្ឆរ = ឆ្នាំ

ពាក់កណ្ដាលទី១ ឬ ភាគទី១ នៃសតវត្សរ៍ទី១០=

First half of the 10th century = 901-950 AD (Adno Domina), AC (After Christ)

ពាក់កណ្ដាលទី២ ឬ ភាគទី២ នៃសតវត្សរ៍ទី១០=

Second half of the 10th century= 951-1000 AD

ពាក់កណ្ដាលភាគទី១ នៃសតវត្សរ៍ទី១០ =

the middle of the first half of the 10th century

= 920s (920-929 + 930) / 925 AD

ពាក់កណ្ដាលភាគទី២ នៃសតវត្សរ៍ទី១០ =

the middle of the first half of the 10th century

= 970s (970-979 + 980) / 975 AD

- 1st quarter of the 10th century = 901-925 AD

- 2nd quarter of the 10th century = 926-950 AD

- 3rd quarter of the 10th century = 951-975 AD

- 4th quarter of the 10th century = 976-1000 AD

មួយភាគបួនទី១,២,៣,និង ទី៤នៃសតវត្សរ៍ទី១០

បក្ខ បក្ស

គរុកោសល្យ = បាលីសំស្ក្រឹត

គរុកោសល្ល = បាលី, គុរុកោសល្យ = សំស្ក្រឹត

អាផ្កាធរ / អាផ្កាបត្រ=អាផ្កាបណ្ណ

សំផ្កាបត្រ= សញ្ញាបណ្ណ= សញ្ញាបត្រ(បា.សំ.)

អាណាបក្ក(បា.)= អាផ្កាបក្រ(សំ.)= អាណាបក្រ

ស្ស ស sa

ឝ្ឝ ឝ śa / ça = ស, ឝាលា=សាលា

ឞ្ឞ ឞ ṣa /sha = ស, ឝិឞ្យ= សិស្ស, ឫឞី=ឫសី/ឥសី

វិទ្យាសាស្ត្រ= វិទ្យា/វិជ្ជា + សាស្ត្រ = Science

វិទ្យា/វិជ្ជា = Science/scientifique

+ សាស្ត្រ = Science/Scientifical

សាសនា =? religion ( religion = the belief in and worship of a superhuman controlling power, especially a personal God or gods: *ideas about the relationship between science and religion, (2)* a particular system of faith and worship: *the world's great religions*. (3) a pursuit or interest followed with great devotion: *consumerism is the new religion*.)

នយោបាយ politic

វិទ្យាសាស្ត្រនយោបាយ Political Science

= រដ្ឋសាស្ត្រ/រដ្ឋវិទ្យា/រដ្ឋវិជ្ជា (ត្រូវជាង)

Fou-nan > Funan = ហ្វូណាន = ខាងត្បូងប្រកៀក

= Carried South = (Xenonym ឈ្មោះបរទេសដាក់ឱ្យ)

= 富南

# សម័យអង្គរ ៖ ការកសាងអារ្យធម៌ខ្មែរ

ដោយ វង់ សុធារ៉ា
ដេប៉ាតឺម៉ង់ប្រវត្តិវិទ្យា
សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

## មាតិកា

- ១_រាជកិច្ចគ្រាដំបូងរបស់ព្រះបាទបរមេស្វរៈ
- ១. ក. យុទ្ធសាស្ត្របង្រួបបង្រួម
- ១. ខ. ធម្មនុញ្ញភាពឬធម្មភាពនយោបាយ
- ១. គ. ទស្សនៈរៀបចំទីក្រុងនិងសុខមាលភាព
- ២_ ស្ថាប័ននយោបាយនិងអង្គការរដ្ឋបាល
- ៣_ការកសាងរាជធានី
- ក្រុងយសោធរបុរៈ (ក្រុងអង្គរទី១_៤)
- រាជធានីទៅកោះកេរ្តិ៍ (ឆោកគរគី )
- ៤_ការកសាងប្រាសាទ និងបារាយណ៍

៥_ គមនាគមន៍, សង្គមកិច្ច, អប់រំ
៦_បទបញ្ញត្តិខ្លះ និងសញ្ញាណទស្សនវិជ្ជាខ្មែរ
៧_សង្គ្រាមជាមួយចាម្ប
៨_ សង្គ្រាមជាមួយយួន
៩_ការបែងចែក និងសង្គ្រាមបង្រួបបង្រួម សំខាន់ៗ
១០_ការប្រជែងខាងសាសនា និងការផ្លាស់ប្តូរ
១១_ការរាយលុករបស់សៀម

# សំណួរពិភាក្សាមេរៀនទី៣៖ អារ្យធម៌ខ្មែរសម័យអង្គរ

- ១. តើព្រះបាទជយវម៌្មទី២ប្រើប្រាស់យុទ្ធសាស្ត្រដូចម្តេចខ្លះក្នុងការបង្រួបបង្រួមប្រទេស?
- ២. តើព្រះបាទជយវម៌្មទី២ បានបង្កើតធម្មនុញ្ញនយោបាយដូចម្តេចខ្លះចាប់ពីឆ្នាំ៨០២មក?
- ៣. តើនៅសម័យអង្គរមានរាជធានីនៅទីណាខ្លះ? មានភស្តុតាងដូចម្តេចខ្លះ?
- ៤. តើរដ្ឋបាលគ្រប់គ្រងប្រទេសនៅសម័យអង្គរមានរចនាសម្ព័ន្ធដូចម្តេចខ្លះ?
- ៥. តើស្តេចខ្មែរនៅសម័យអង្គរកសាងអារ្យធម៌ដូចម្តេចខ្លះ?
- ការកសាងប្រាសាទ និងបារាយណ៍ ឬទន្លេ?
- ផ្លូវគមនាគមន៍,សង្គមកិច្ច, សុខាភិបាល, អប់រំ ឬអាស្រម......

## សម័យអង្គរ

- ចាប់ផ្តើមពីឆ្នាំ៨០២ ដល់១៤៣២គ.ស.
- ចាប់ពីរាជ្យព្រះបាទជយវម៌្មទី២ជាស្ថាបនិក ដល់រាជ្យព្រះបាទពញាយ៉ាត ជាស្តេចចាកចោលអង្គរ
- «អង្គរ» ជាឈ្មោះកាលសម័យ ដែលប្រវត្តិវិទូដាក់តាមឈ្មោះអ្នកស្រុកហៅតំបន់អតីតរាជធានីនេះនៅសម័យទំនើប។
- «អង្គរ» ជាពាក្យហៅផលពីភាសាសំស្ក្រឹតថា «នគរ»
- គេចាត់ទុកជាសម័យកាលរុងរឿងបំផុតមួយរបស់កម្ពុជា ដោយសារសំណល់ភស្តុតាងប្រាសាទថ្មធំៗ និងបារាយណ៍ធំៗជាច្រើន ដែលគេស្មានថា កើតចេញពីមហាអំណាចនយោបាយ យោធា សេដ្ឋកិច្ច ប្រជាជន ដែលប្រកបដោយបញ្ញាញាណច្នៃប្រឌិតខ្ពស់ ព្រមទាំងការឧស្សាហ៍ព្យាយាមដ៏អស្ចារ្យ

# ១.ក. យុទ្ធសាស្រ្តបង្រួបបង្រួម

តើព្រះបាទជយវម៌្មទី២ប្រើប្រាស់យុទ្ធសាស្រ្តដូចម្តេចខ្លះក្នុងការបង្រួបបង្រួមប្រទេស?

១). អាពាហ៍ពិពាហ៍នយោបាយ (Wolters, W.O.; Judith Jacobsen)

•ព្រះអង្គប្រហែលចាប់ផ្តើម បង្រួបបង្រួមប្រទេសចាប់តាំងពីយ៉ាងហោចណាស់ឆ្នាំ៧៨១ បើតាមសិលាចារឹកនៅសំបូរ K.134 តាមរយ:«អាពាហ៍ពិពាហ៍នយោបាយ»ជាមួយស្តេចស្រី ជយេន្ទ្រវល្លភា, ស្រ្តីជាច្រើន ដែលជាប្អូនស្រីរបស់មេទ័ពសំខាន់ៗ, កូនស្រីរបស់មេដឹកនាំសំខាន់ៗ, ជាពិសេសកូនស្រីនៃស្តេចវ្យាធបុរៈ នាមធរណីន្ទ្រទេវី ដែលព្រះអង្គបានលើកជាអគ្រមហេសី។ malyāṅមល្យាង

២). បង្ហាញពីមហិទ្ធិឫទ្ធិ ឬថ្វីដៃខាងយោធា ឱ្យស្តេចនៃក្សត្របុរីដទៃទៀតកោតស្ញប់ស្ញែងនិងចុះចូល

• ដោយវាយឈ្នះពានចាម្ប(ឬជ្វានៅពាក់កណ្តាលសតវត្សរ៍ទី១១)ដែលមានអំណាចខ្លាំងក្លា នៅរវាងឆ្នាំ៧៩០ (បើតាមសិលាចារឹកK.583) ជាពិសេសនៅភាគទី២នៃសតវត្សរ៍ទី៨នោះ

# ១.ក. យុទ្ធសាស្រ្តបង្រួបបង្រួម

៣). ការលើករាជធានីញឹកញាប់ទៅជិតតំបន់មិនទាន់រួបរួម (George Cœdès)

•ក្រោយពីត្រឡប់ពីច្បាំងជាមួយចាម្បវិញ «ព្រះអង្គលើករាជធានីជាញឹកញាប់» ដូចជា ឥន្ទ្របុរៈ, ហរិហរាលយ, អមរេន្ទ្របុរៈ, និងមហេន្ទ្របវ៌ត ដើម្បីបង្កភាពងាយស្រួលក្នុងការបញ្ចុះបញ្ចូល៕

៤). លើកឋានៈមន្រ្តីឱ្យដូចស្តេចសម័យមុនអង្គរ ដោយការប្រទានបរមនាម«វម៌្ម»នៅខាងចុងនាមមន្រ្តី

•បើតាមសិលាចារឹករបស់ឥន្ទ្រវម៌្មទី១ ប្រហែលជាព្រះអង្គរក្សាគោរម្យងារដូចស្តេច ឱ្យមន្រ្តីថ្នាក់ខេត្តទាំងឡាយ ដោយឈ្មោះគេម្នាក់ៗបញ្ចប់ដោយពាក្យ —វម៌្ម ដែលនៅសម័យមុនអង្គរ មានតែអធិរាជទេ ទើបមានព្រះនាមបញ្ចប់ដោយបច្ចេកពាក្យនេះ។ ផ្ទុយទៅវិញចាប់ពីពាក់កណ្តាលទី២នៃស.វ.ទី៩ នាមមន្រ្តីត្រឹមតែ«ម្រតាញ» ក៏ត្រូវបំពាក់រហស្សនាមជា —វម៌្ម នៅខាងចុងនៃឈ្មោះដែរ៕




# ១. រាជកិច្ចដំបូងនៃព្រះបាទបរមេស្វរៈ ឬជយវរ្ម័នទី២

- ក្រោយពីយាងត្រឡប់មកពីធ្វើសង្គ្រាមជាមួយចាម្ប នៅរវាងក្រោយឆ្នាំ៧៩០ បើតាមសិលាចារឹក K.583 ព្រះអង្គបានយាងទៅគង់នៅ
- ឥន្ទ្របុរៈ (ប្រហែលជា)បន្ទាយព្រៃនគរ «ស្រុកពញាក្រែកនៃខេត្តត្បូងឃ្មុំ»
- សិលាចារឹកវត្តសំរោងK.956ថា ព្រះអង្គឱ្យម្រតាញប្រថិវិនរេន្ទ្រធ្វើពិធីកល្យាណសិទ្ធិនៅរំដួល ដើម្បីប្រតិស្ថានអ្នកតាការពារទ្វារព្រះនគរកុំឱ្យជ្វា(ចាម)ឈ្លានពានដណ្តើមយកកម្ពុជទេសបាន៕
- បន្ទាប់មកព្រះអង្គបានលើករាជធានីមកនៅជិតអនាគតតំបន់អង្គរ ដែលជាភូមិភាគកណ្តាលប្រទេសខ្មែរ ក្នុងរាជ្យព្រះបាទជយវរ្ម័ទី១ និងព្រះរាជិនី ជយទេវី គឺបុរន្ទរបុរៈ៕
- 

# ១. រាជកិច្ចដំបូងនៃព្រះបាទជ័យវរ្ម័នទី២

- ឱ្យដីនៅកុតិ (ខេត្តបូព៌ាទិស)ទៅសិវកៃវល្យបង្កើតភូមិដ្ឋានដាក់ខ្ញុំបម្រើ (ទំនងត្រង់ប្រាសាទបន្ទាយក្តីសព្វថ្ងៃ)
- ហរិហរាល័យ ជាទីក្រុងទី២(សព្វថ្ងៃនៅរលួស ទំនងត្រង់ប្រាសាទព្រៃមន្ទីរ)
- អមរេន្ទ្របុរៈ ជាទីក្រុងទី៣ (បន្ទាយឆ្មារ,ក្បែរបារាយណ៍ទឹកថ្លា,ភ្នំស្រុក, និងនៅពាយ័ព្យនៃខេត្តបាត់ដំបង)
- មហេន្ទ្របរ័ត ជាទីក្រុងទី៤ នៅលើភ្នំគូលេន ធ្វើពិធីលេហានៅឆ្នាំ៨០២




N
Mar 22, 2012
8:05am
Image © 2012 GeoEye
Data SIO, NOAA, U.S. Navy, NGA, GEBCO
9981 ft
Google
13°26'31.38" N 103°44'20.51" E
Mar 3, 2010
Eye alt 34551 ft


N
Banteay Chmar_Amarendrapura
© 2012 Google
© 2012 Tele Atlas
© 2012 Cnes/Spot Image
Data SIO, NOAA, U.S. Navy, NGA, GEBCO
4064 ft
Google
14°04'10.50" N 103°06'31.01" E
Eye alt 14739 ft


Khelang
Plae
Mae Yom
Maenam
Si Satchanalai
SAI FONG
Mekong
Hamsavati
Kusumi
Sudhammavati
Chot
Tak
QUANG-BINH
QUANG-TRI
Phu Khiao Kao
Amarāvati
Tra-kiêu
Mi-sơn
Đong Dương
Mun R.
Phimai
Si Thep
Lavo
U Thong
Menam
DANGREK
Vat Ph'u
Sa-huynh
Preah Vihear
Koh Ker
MLU PREI
Vijaya
Phong Tuk
Phra Pathom
Amarendrapura
ANGKOR
ROLŪOS
Purandarapura
Preah Khan
Cape Varella
Lingaparvata
Beng Mealea
Aninditapura
Sambor P. Kuk
Icanapura
Bhavapura
Sambhupura
Kauthāra
Vo-canh
Lingaparvata
Indrapura
Pāndurange
Angkor Borei
Vyadhapura
XUĀN-LÔC
PLAINE DES JONCS
Isthmus of Kra
KALAH
OC EO
Bay of Bandon
Grahi
Khao Phra Narai
Takkola
Nagara Śrī Dharmarāja, Dharmanagarī


KOH KER
NORTH CHANNEL
LOVEA
PHNOM KULEN
Beng Mealea
Preah Khan
Bayon
Pre Rup
EAST ROAD
BENG MEALEA
Ph. Bakheng
Ta Prohm
Chau Srei Vibol
Angkor Wat
ANGKOR
Bakong
ROLUOS
20 km

# ១.២. ធម្មនុញ្ញភាព ឬ ធម្មភាពនយោបាយ

តើព្រះបាទជយវម៌្មទី២ បានបង្កើតធម្មនុញ្ញនយោបាយដូចម្តេចខ្លះចាប់ពីឆ្នាំ៨០២មក?ឆ្នាំ៨០២ នៅលើមហេន្ទ្របព៌តគឺភ្នំគូលែន ព្រះអង្គបានអញ្ជើញព្រាហ្មណ៍ហិរណ្យទាម ធ្វើពិធីបុណ្យលេបហតាមគម្ពីរវិនាសិខៈ:

១). ប្រតិស្ឋានអ្នកតាការពារប្រទេស (K.956, K.1158, K.235C)

• សូមកុំបីឱ្យប្រទេសកម្ពុជានេះអាចចំណុះជ្វាបានឡើយ = លេងកំបិកម្ពុជទេគនេះអាយត្តតជវាលេយ

២). លើកឱ្យមានតែព្រះបាទជយវម៌្មទី២ ជាស្តេចចក្រពត្តិ The World King

• សូមឱ្យមានតែមហាក្សត្រនៃកម្ពុជទេសប៉ុណ្ណោះជាចក្រវតិ៌ន ៖ ស្តេចចក្រពត្តិ

៣). ប្រតិស្ថានលិង្គព្រះឥស្វរ ជាស្តេចនៃអាទិទេព សម្រាប់ស្តេចគោរពបូជាជានិយ័ត

• អាទិទេពមជ្ឈឹមធំមួយនេះមានឋាននូវនាមជា កម្រតេងជគតតរាជ=ទេវរាជ = ទេពម្យ៉ាងជារូបលិង្គ = Supreme God=Çiva, [Dieu-roi, The Master of Universe who is the King]

# ១.២. ធម្មនុញ្ញភាព ឬ ធម្មភាពនយោបាយ

៤). ស្តេច និងព្រាហ្មណ៍អ្នកប្រាជ្ញហិរណ្យទាម ប្រគល់តួនាទីកាន់កាប់បដិមាស្តេចនៃអាទិទេពនេះឱ្យគ្រួសារសិវកៃវល្យបន្ទាប់ពីបង្រៀនគាត់ឱ្យចេះមន្តអាគមតាមគម្ពីរដ៏សំខាន់៤

•ព្រាហ្មណ៍ហិរណ្យទាម បង្រៀនសិវកៃវល្យៈ នូវគម្ពីរ៤គឺ វ្រះវិនាសិខៈ, នយោត្តរៈ,សំមោហៈ និងវ្រះសិរស្ឆេទ គឺជាគម្ពីរតន្ត្រៈ ដែលគេនិយមរៀននៅឥណ្ឌា, នេប៉ាល់, សិរីលង្កា, បង់ក្លាដេស។ គាត់បង្ហាត់សិវកៃវល្យៈ សរសេរ និងសូត្រគាថាគម្ពីរនោះ និងធ្វើពិធីបូជាស្តេចនៃអាទិទេពនោះជាមុន។ ទុម្ពុរុ គឺព្រះឥស្វរមុខ

៥). បង្កើតស្ថាននាម«អង្គភូមិសាស្ត្រ»(Geo-body of Politic)នយោបាយថ្មីមួយសម្រាប់ហៅប្រទេសដ៏ធំ ដែលមានចម្រុះជាតិសាសន៍ថា «កម្វុជទេស» គឺប្រទេសជាកូនចៅឥសីកម្ពុកើតឯង និងទេពអប្សរមេរា ដែលទាំងពីរអង្គនេះ មិនមានបញ្ជាក់អត្តសញ្ញាណជនជាតិណាមួយឡើយ។

# ១.៣. ការរៀបចំគ្រឹះសេដ្ឋកិច្ចនិងសុខមាលភាពនគរ

- ស្ពានសិវលិង្គ នៅបាតស្ទឹងក្រាលដោយថ្មធម្មជាតិ ដើម្បីបញ្ចុះមន្តអាគម និងធ្វើឱ្យទឹកស្ទឹងសៀមរាបក្លាយជាទឹកថ្នាំ និងជាទឹកអម្រឹតតាមធម្មជាតិ
- សញ្ញាណនៃការយកចិត្តទុកដាក់លើសុខមាលភាពសង្គម តាមរយៈជំនឿសាសនា
- អ្នកប្រើទឹកនោះមានសិរីសួស្តីជយមង្គល
- ដំណាំដែលស្រោចដោយទឹកមន្តនេះ នឹងមានផ្លែផ្កាល្អ
- ទំនងជីកព្រែកភ្ជាប់ក្រុងហរិហរាល័យចំខាងលិចអនាគតប្រាសាទបាគង និងស្ទឹងសៀមរាបត្រង់ខាងត្បូងទីក្រុងសៀមរាបសព្វថ្ងៃ
- បង្កើតមូលដ្ឋានទស្សនវិស័យជយភូមិសម្រាប់តំបន់មូលដ្ឋានរាជធានីក្នុងពេលអនាគត

| អគ្គទេវី ឬ អគ្គមហេសី | អធិរាជ ឬ ចក្រពត្តិន | រាជទាយាទ ឬ យុវរាជ |
| --- | --- | --- |
| • ជាស្ថាប័នកំពូលដ៏សំខាន់ ដោយសារផ្តល់នីតិសម្បទាជាព្រះមហាក្សត្រ ឬអធិរាជជាប្តី<br>• ព្រោះសង្គមខ្មែរប្រកាន់ខ្សែខាងស្រី ស្ត្រីជាម្ចាស់ទ្រព្យ និងមុខតំណែងរបស់គ្រួសារ ហើយស្តេចច្រើនជាងពាក់កណ្តាលឡើងសោយរាជ្យបានដោយធ្វើរាជប្រហារ | • គ្រប់គ្រងរដ្ឋាភិបាលដែលមានសមាជិក គណៈរដ្ឋមន្ត្រីយ៉ាងធំ<br>• ឧបរាជ<br>• ចតុរាចារ្យ ឬអាចារ្យប្រធាន<br>• រាជកុលមហាមន្ត្រី<br>• សភាបតី<br>• គុណទោសទសី<br>• ខ្លោញឃ្លាំង<br>• វ្រះលំវាង<br>• មហាសេនាបតី និងសេនាបតី<br>• តម្រួតរាជការ<br>• រាជគ្រូ និងទីប្រឹក្សា<br>• សវ៌ាធិការី ...... | មានឋានន្តរនាមធម្មតាដូចមន្ត្រីថ្នាក់ទី១ គ្រាន់តែមានពាក្យ«យុវរាជ»<br>•ធ្វើការជាមួយប្រធានរាជកុល មហាមន្ត្រី<br>•មិនសូវមានសកម្មភាពខាងសាសនា<br>•ប្រហែលមិនមានសិទ្ធិគ្រប់គ្រងកងទ័ព ឬមានកងទ័ពមាំមួន<br>•យុវរាជ ជាស្តេចត្រៀម តែភាគច្រើនមិនបានស្នងរាជ |

# ២. រចនាសម្ព័ន្ធនយោបាយ

1. អធិរាជ(រាជាធិរាជ), ជា ស្តេចមជ្ឈឹម, ជាស្តេចនៃស្តេចទាំងឡាយនៃស្តេចទាំងឡាយ ជា ចក្រវត្តិន, ជាស្តេចចក្រពត្តិ ឬស្តេចនៃពិភពលោក = Universal Ruler/King

- រាជាធិរាជ ជាអ្នកបង្កើតធម៌ និង ការពារធម៌ ឬ ច្បាប់ ជាសាវ័ករបស់អាទិទេព/ស្តេចនៃអាទិទេព/ព្រះឥស្វរ (ក្រោយទិវង្គត-> នៅឋានសួគ៌, អាទិទេព)

2. អគ្រទេវី ឬ អគ្គមហេសី (សំខាន់ខ្លាំងសម្រាប់ប្រពៃណីប្រកាន់ខ្សែស្រឡាយខាងស្រី) ព្រះអង្គបាន ជួយបំពេញភាពស្របច្បាប់(និត្យានុកូលភាព)ឱ្យព្រះរាជា ជា «ប្តី»

3. យុវរាជ_វរជ្ឈទាយាទ (បេក្ខភាពដែលត្រូវឡើងស្នងរាជ្យ)= ភាគច្រើនមិនបានឡើងសោយរាជ្យបន្តពី បិតា ឬ បងប្រុស ដូចបានគ្រោងទុក។ ឧទាហរណ៍៖ យុវរាជរបស់ជយវរ្ម័ទី៣, យុវរាជរបស់ ជយវម៌្មទី៥, យុវរាជរបស់ជយវម៌្មទី៦, យុវរាជរបស់សូរ្យវម៌្មទី២...

# ២. រចនាសម្ព័ន្ធនយោបាយ

- មន្ត្រីរដ្ឋាភិបាល និងស្ថាប័នរដ្ឋបាល
- ឧបរាជ (ប្រហែល) ធូលីជេងវ្រះកម្រតេងអញគ្រី......វម៌្ម
- ធូលីជេងវ្រះកំស្តេងអញគ្រី......វម៌្ម (នាយករដ្ឋមន្ត្រីរបស់ឧបរាជ?)
- (វ្រះកំស្តេងអញ)រាជកុលមហាមន្ត្រី លោកជេន្ទើរថា នាយករដ្ឋមន្ត្រី (ប្រហែលខុស)
- អាចារ្យប្រធាន(៤រូប) រដ្ឋមន្ត្រីខាងសាសនា (ធូលីជេងវ្រះកម្រតេងអញ...បណ្ឌិត)
- ព្រះសភាបតី(៤រូប) រដ្ឋមន្ត្រី ខាងយុត្តាធិការ ឬ យុត្តិធម៌
- គុណទោសទសី(ន) (៤រូប) រដ្ឋមន្ត្រី ខាងសន្តិសុខ
- ព្រះឃ្លាំង (៤រូប) រដ្ឋមន្ត្រីខាងហិរញ្ញវត្ថុ
- មហាសេនាបតី និងសេនាបតី ៖ មេទ័ពធំ (ពេលខ្លះមាន៤នាក់ដែរ)និងអ្នកជំនិត ៖ អ្នកសញ្ជក (ក្រោយស្លាប់ត្រូវតម្លើងជា អំតេង) និង
- វ្រះលំវាង_(ព្រះលំពាំង?) មន្ត្រីវាំង(៤រូប)

# ២. រចនាសម្ព័ន្ធនយោបាយ

- តម្រួតរាជការ មាន៤កម្រិត
- មន្ត្រីកាន់តំណែងកិត្តិយស ឬ ជំនួយការរដ្ឋ
- រាជគ្រូ (វរជនចំណេះដឹង) ជា បណ្ឌិត
- រាជបុរោហិត, ហោតរ, (អ្នកបួសជាព្រាហ្មណ៍_ធ្វើពីធីបុណ្យបូជា) ជាបណ្ឌិត(ប្រធាននីតិបញ្ញត្តិ)
- ទីប្រឹក្សា (វរជនចំណេះដឹង + ផោហា) ជា បណ្ឌិត
- មន្ត្រីជំនាញ៖ ខាងយុត្តិធម៌ មានច្រើន សភាសត, ធម្មាធិការិ(ន),ស្នួតកាំពីធម្មសាស្ត្រ, ចារ,..
- សព្វាធិការិ(ន), ជាអគ្គនាយកការងារ
- វ្យាបារ:(មន្ត្រីរាជការ), ប្រត្យ័យ(មន្ត្រីលេខាធិការ), ស្រេស្ឋិន(មន្ត្រីពាណិជ្ជកម្ម)
- ភូតាស:, យាជក:, ខ្ញុំព្រះក្រឡាអច្ច៌ន, កម្មាន្តរ... មន្ត្រីអ្នកបួស,

# ២. រចនាសម្ព័ន្ធនយោបាយ

- ឋានន្តរស័ក្តិមន្ត្រី តាមជីវតាក្វាន់
- _មន្ត្រីជិះព្រែក្រស្នែងមាស១ បាំងក្លស់ដងមាស៤ _ឋាន:ធំជាងគេ, បាំងក្លស់ដងមាស២_ឋាន: បន្ទាប់, និងបាំងក្លស់ដងមាស១ _មន្ត្រីបាំងក្លស់ដងមាស១, មន្ត្រីបាំងក្លស់ដងប្រាក់ ដូចគ្នានឹងខាងបាំងក្លស់ដងមាសដែរ (ក្លស់ ឬ ឆត្រ) មានរដ្ឋមន្ត្រី ៨កម្រិត
- ឋានន្តរស័ក្តិមន្ត្រី តាមសិលាចារឹក
- មន្ត្រីជិះព្រែក្រស្នែងដងមាសក្បាលនាគ កំពូល៥,៣,១ និងមានក្លស់មាស ឬ ក្លស់ប្រាក់
- កន្លងមកគេថា តាមរូបចម្លាក់ ឋានន្តរស័ក្តិធំ_តូច គួរតែចំណាំដោយចំនួនខ្លស់ ដែលបាំងជុំវិញមន្ត្រីម្នាក់ៗ តែបើតាមសិលាចារឹកចំនួនខ្លស់,គ្រាន់តែជាចំនួនគ្រឿងឥស្សរិយយសប៉ុណ្ណោះ

# ២. រចនាសម្ព័ន្ធនយោបាយ

- រដ្ឋមន្ត្រីនៃមុខការនីមួយៗ មានការបែងចែកជា៤កម្រិត គឺ នាឯក,ទោ,ត្រីណី និងនាចត្វារី
- ចៅហ្វាយខេត្ត និងតម្រួតរាជការខេត្ត ប្រហែលមាន៤កម្រិតដូចរដ្ឋមន្ត្រី
- ចាប់ពីរជ្ជកាលជយវម្ម័ទី៥ មន្ត្រីរាជការត្រូវរើសចេញពីវណ្ណៈ២, គឺ ខ្លុកវ្រះក្រលាអច្ចិន:+កម្មាន្តរ:
- ជីវតាក្វាន់ថា មន្ត្រីតាំងពីក្នុងវាំងរហូតដល់ខេត្តទាំងឡាយជាញាតិរបស់ស្តេច,ប្រជាជនចូលធ្វើរាជការត្រូវយកកូនស្រីស្អាតទៅថ្វាយស្តេចធ្វើស្រីស្នំ ទើបក្រុមគ្រួសារអាចចូលធ្វើរាជការបាន
- សិលាចារឹកគោកពោធិ៍ថា មានមន្ត្រីម្ឫតកធន/មត៌កធនធាន ខ្លះអាចធ្វើមន្ត្រីបានដោយសារបានលក់ស្រែដើម្បីយកវត្ថុមានតម្លៃ ជូនមន្ត្រីជាន់ខ្ពស់(ម្ឫតកធន=មន្ត្រីគ្រប់គ្រងទ្រព្យអ្នកស្លាប់/ទ្រព្យរបស់គ្រួសារនីមួយៗ) ម្ឫត្យុ មច្ចុ រាជ / យមរាជ ម្ឫតក មត៌ក អ្នកស្លាប់, ម្ឫតកធន =ទ្រព្យអ្នកស្លាប់

# ២. រចនាសម្ព័ន្ធនយោបាយ

- **រចនាសម្ព័ន្ធដែនដីរដ្ឋបាល**
- ប្រមាណ (ថ្នាក់ភូមិភាគ គ្មានវត្តមានមន្ត្រី) ទំនងមានស្តេចត្រាញ់ទទួលខុសត្រូវ
- វិសយ (ថ្នាក់ខេត្ត មានមុខមន្ត្រីដូចរដ្ឋបាលមជ្ឈិម) ខ្លោញបយ៌្យងវ្រិហិវិសយ(ប្រធានប្រេងស្រូវខេត្ត)
- ស្រុក (ថ្នាក់ឃុំ ឬភូមិ មានមន្ត្រីស្រដៀងនឹងថ្នាក់ខេត្ត)
- ចំណត (ភូមិដ្ឋានថ្មីៗ និងតូចៗ)
- ភូមិ (ដី ឬដីធ្លី ដែលជាកម្មសិទ្ធិរបស់គ្រួសារមន្ត្រី, ឬគ្រួសារអ្នកមាន—ស្រដៀងគ្នានឹងចំណតដែរ)
- (វ្រះ)អន្រាយ (ភូមិដ្ឋានចំណុះឱ្យប្រាសាទ ដែលត្រូវផ្តល់ស្បួយជាប្រចាំដល់ប្រាសាទ)

## បំណែងចែកដែនដីរដ្ឋបាលអាណាចក្រ និងសាសនាចក្រ

| បច្ចេកពាក្យហៅដែនដីរដ្ឋបាល | អាណាចក្រ | សាសនាចក្រ |
|---|---|---|
| ប្រមាណ គឺថ្នាក់ភូមិភាគ (គ្មានវត្តមានមន្ត្រី) | ★ | |
| វិសយ គឺថ្នាក់ខេត្ត (មានមន្ត្រីដូចរដ្ឋបាលមជ្ឈិម) | ★ | ★ |
| ស្រុក គឺជាភូមិ, ឃុំ, ស្រុក, ខេត្ត, ឬប្រទេសមួយ | ★ | ★ |
| ចំណត/ចំនត គឺជាភូមិថ្មីៗ ឬ តូចៗ | ★ | ★ |
| ភូមិ គឺជាដីផ្តីកម្មសិទ្ធិឯកជន (មានកុំបម្រើច្រើន នាំឱ្យមានភូមិដ្ឋានធំ មានផ្ទះច្រើនខ្នង) | ★ | |
| អន្រាយ/វ្រះអន្រាយ គឺជាភូមិដ្ឋានចំណុះប្រាសាទ | | ★ |

## មុខងារ និងឋានានុក្រមមន្ត្រីដែនដី ខេត្ត, ស្រុក, វិសយ ឬប្រមាណ

| មុខងារ | ឋានន្តរនាមភាគច្រើន | ឋានន្តរនាមភាគតិច |
|---|---|---|
| ប្រធាន, ខ្លោញវិសយ | ម្រតាញខ្លោញ, ក្សុង, ម្រតាញ | វ្រះកម្រតេងអញ, វាប |
| ខ្លោញពល | ម្រតាញខ្លោញ, ម្រតាញ | វាប, លោញ |
| សភាបតី | កំស្តេង, ម្រតាញខ្លោញ | ម្រតាញ |
| គុណទោសទសី | ម្រតាញខ្លោញ,ម្រតាញ | ម្រតាញខ្លោញ |
| ខ្លោញឃ្លាំង | ម្រតាញខ្លោញ, ម្រតាញ | ម្រតាញ, ស្តេង |
| ខ្លោញបយ៉្សងវ្រហ៊ | វាប, ម្រតាញ, ម្រ.ខ្លោញ | វាប, លោញ, ម្រតាញ |

មុខងារ និងឋានន្តរក្រមមន្ត្រីដែនដី ស្រុក ឬភូមិ

| មុខងារ | ឋានន្តរនាមភាគច្រើន | ឋានន្តរនាមភាគតិច |
|---|---|---|
| ម្ចាស់, អម្ចាស់ ស្រុក | លោញ, ម្រតាញ, ម្រតាញខ្លោញ,កំស្តេង, | វ្រះកំស្តេង, វ្រះកម្រតេងអញ, .... |
| បុរសប្រធាន, ប្រធានស្រុក, ខ្លោញស្រុក (ម្នាក់) | វាប, លោញ | ម្រតាញ, ម្រតាញខ្លោញ |
| គ្រាមវ្រឹទ្ធ (គ្រាមវ្ឫទ្ធ) ៤នាក់ | វាប | ម្រតាញ |

# ៣. រាជធានីនៅសម័យអង្គរ

- នៅសម័យនេះ ទោះបីមានរាជធានីខ្លះនៅកន្លែងផ្សេងពីតំបន់អង្គរ តែក្នុងរយៈពេលរាប់រយឆ្នាំនេះ រាជធានីតាំងនៅតែតំបន់អង្គរ ដូចជា៖
- ហរិហរាល័យនៅតំបន់រលួស ខាងកើតក្រុងសៀមរាបសព្វថ្ងៃ១៦គីឡូម៉ែត្រ
- មហេន្ទ្របព៌ត នៅលើខ្នងភ្នំគូលែន មួយរយៈខ្លី?
- យសោធរបុរៈទី១ ដែលមានភ្នំបាខែងជាផ្ចិត ដោយព្រះបាទយសោវម៌្មទី១(៨៨៩-៩១០គ.ស.) មានជីកបារាយណ៍យសោធរតដាកនៅទិសឥសាននៃរាជធានី ដែលរាជេន្ទ្រវម៌្មសាងប្រាសាទមេបុណ្យកើត នៅចំកណ្ដាល និងប្រាសាទប្រែរូបនៅខាងត្បូង ខាងក្រៅទំនប់បារាយណ៍
- ឆោគគរគ្យរ = ឆោកគគីរ ឬ អ្វរគគីរ គឺនៅកោះកេរ្តិ៍ សព្វថ្ងៃ កសាងដោយព្រះបាទជយវម៌្មទី៤
- ជយេន្ទ្រនគរី ដែលមានប្រាសាទតាកែវ ឬ ហេមស្ឫង្គគិរី ជាផ្ចិត (ត្រូវរន្ទះបាញ់នៅរាជ្យសូរ្យវម៌្មទី១)

# ៣. រាជធានីនៅសម័យអង្គរ

- យសោធរបុរៈទី២ ដែលមានប្រាសាទបាពួនជាផ្ចិត កសាងដោយព្រះបាទឧទយាទិត្យវរ្ម័ទី២ (១០៥០ -១០៦៦គ.ស.) និងជីកពង្រីកបារាយណ៍ទឹកថ្លាធ្វើជាមហាសមុទ្រមានវិស្ណុផ្ទំលើនាគសេសៈ
- យសោធរបុរៈទី៣ ដែលមានប្រាសាទអង្គរវត្ត ឬ បរមវិស្ណុលោក ជាផ្ចិត កសាងដោយព្រះបាទសូរ្យវម្ម័ទី២ (១១១៣-១១៥០គ.ស.) នៅសល់កេរដំណែលដរាបសព្វថ្ងៃ អ្នកស្រុកហៅថា អង្គរតូច។
- យសោធរបុរៈទី៤ ដែលមានប្រាសាទបាយ័នជាផ្ចិត កសាងដោយព្រះបាទជយវរ្ម័ទី៧ នៅសល់កេរដំណែលដរាបសព្វថ្ងៃ អ្នកស្រុកហៅថា អង្គរធំ។ កណ្តាលទន្លេជយតដាកមានសាងប្រាសាទនាគព័ន្ធ
- ទួលប៉ាសាន ដែលមានទីតាំងស្ថិតនៅវត្តស៊ីធរ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាលសព្វថ្ងៃ ។ ជារាជធានីនៅអំឡុងឆ្នាំ១៣៧១-១៣៨៩ តាមរបាយការណ៍អ្នកការទូតចិន។

## ៣. ការកសាងរាជធានី ៖ ហរិហរាល័យ




• ប្រាសាទបុរាណមុនអង្គរ។

▲ សំណង់ដែលកសាងឡើងដោយព្រះបាទឥន្ទ្រវម៌ ទី១

... តំបន់ស្រោចទឹក




## ៣. ការកសាងរាជធានី ៖ មហេន្ទ្របវ៌ត



# ៣. ការកសាងរាជធានី ៖ ហរិហរាល័យ ប្រាសាទបាគង

ប្រាសាទភ្នំជាស្នូលរាជធានីកសាងដោយព្រះបាទឥន្ទ្រវម៌្មទី១(៨៧៧ – ៩១០គ ស។)





១ - ប្រាសាទបាគង



# ៣. ការកសាងរាជធានី ៖ យសោធរបុរៈ១

- ព្រះបាទយសោវម៌ទី១ បានផ្លាស់រាជធានីពីរលួស ទៅកាន់តំបន់អង្គរបច្ចុប្បន្ន
- ឈ្មោះក្រុងថ្មីរបស់ព្រះអង្គ «យសោធរបុរៈ» គេប្រើជាផ្លូវការរហូត—ចុងសម័យអង្គរ
- ផ្ចិតទីក្រុងនេះស្ថិតនៅលើភ្នំបាខែងសព្វថ្ងៃ ឬ «រ្នំកណ្តាល ឬ មធ្យាទ្រិ»
- តម្កល់លិង្គផ្ទាល់ខ្លួន—យសោធរេស្វរៈ នៅចំកណ្តាលប្រាសាទ
- ស្ថាបនាលើភ្នំធម្មជាតិ ដោយចិតកំពូលថ្ម ធ្វើវាលរាបនៅខាងកើត និងជុំវិញ
- កាត់ច្រិបថ្មភ្នំធ្វើខឿនច្រើនជាន់ត្រួតលើគ្នា
- គំនិតនិមិត្តរូបលើស្ថាបត្យកម្ម ១ជ្រុង១មើលឃើញតួប៉មពាព៖ អាទិទេពពាពអង្គក្នុងហិណ្ឌ ចំនួនតួប៉មសរុបគឺ ១០៨តួ ដែលស្មើនឹងចំនួនថ្ងៃនៃវដ្តចន្ទ្រគ្រាស និងសូរ្យគ្រាស

# ៣. ការកសាងរាជធានី ៖ យសោធរបុរៈ១






Temple du Phnom Bakheng (fin IXe s.), centre de la première ville d'Angkor, vue aérienne; Cf. Madeleine Giteau, *Histoire d'Angkor*. p.15

ក្រោមរាជ្យព្រះបាទរាជេន្ទ្រវរ្មិ

# ៣. ការកសាងរាជធានី ៖ យសោធរបុរៈ១




២ – យសោធរបុរី I ប្រាសាទភ្នំបាខែង

- សិលាចារឹកសហសម័យនៅថ្កល់បារាយណ៍ ព្រះបាទយសោវរ្ម័នទី១ ស្ថាបនាទីក្រុង«កម្ពុបុរៈ» រកមិនឃើញទីក្រុងណាក្រៅពីនៅភ្នំបាខែង យសោធរបុរៈ៖ភ្នំកណ្តាល៖ភ្នំបាខែង ជាប្រភពពត៌មាននៅរជ្ជកាលស្តេចបច្ឆាជនបន្តបន្ទាប់ អាទិទេពសំខាន់ គឺព្រះលិង្គរបស់ព្រះបាទយសោវរ្ម័ទី១ ហៅ យសោធរេស្វរៈ





ប្លង់ប្រាសាទភ្នំបាខែងនៃរាជធានីស្រីយសោធរបុរៈទី១

# ៣. ការកសាងរាជធានី ៖ យសោធរបុរៈ១

- ស្នាដៃព្រះអង្គក្រៅពីប្រាសាទភ្នំបាខែង
- ។ប្រាសាទភ្នំបូកដែលស្ថិតនៅទិសឥសាន, ប្រាសាទភ្នំក្រោមនៅទិសខាងត្បូងភ្នំបាខែងជាប់មាត់បឹងទន្លេសាប
- តាមសិលាចារឹកថា ព្រះអង្គបានលើកបារាយណ៍ខាងកើតអង្គរ(ស្ងួតហើយ)_តែលោកទុម៉ាស័យ ថា បារាយណ៍នេះផ្តើមលើកដោយព្រះបាទឥន្ទ្រវម៌ទី១
- ផ្អែកលើសិលាចារឹកព្រះអង្គបាន ស្ថាបនាសំណង់សាសនាជាច្រើនដែរនៅតំបន់អង្គរសម្រាប់អ្នកលទ្ធិផ្សេងៗព្រះឥសូរ+នារាយណ៍ប្រហែលមានព្រះពុទ្ធដែរ
- មានប្រាសាទព្រះវិហារ(សិខរីស្វរ) និងភ្នំសណ្តក (សិវបុរទន្ទេន)


Phnom Bakheng
យសោធរបុរៈទី១
យសោធរបុរៈទី៣
ANGKOR WAT
0 500 1,000 m
Show
3D


Baphuon temple
Yaśodharapura 2
Bayon temple
Yaśodharapura 4
0 100 200 m
Petit Circuit
Show
3D

# ៣_ការកសាងរាជធានី_រាជធានីថ្មីនៅកោះកេរ្ដិ៍ (ឆោកគគីរ)

- ជយវរ្ម័ទី៤ ប្ដូរពីយសោធរបុរៈ ទៅនៅកោះកេរ្ដិ៍ (ឆោកគគីរ) ឆោកគរគ្យរ
- លោក ក្លូតហ្សាក់ ជឿថា កោះកេរ្ដិ៍ទឹកដីកំណើតរបស់ព្រះអង្គ
- អ្នកប្រាជ្ញខ្លះ_សម្មតិកម្ម_ព្រះអង្គចង់បង្ហាញសមត្ថភាពជាអធិរាជខ្លាំងពូកែ១អង្គដែរ
- ៩២១ ប្រជែងកសាងក្រុងកោះកេរ្ដិ៍ ដំណាលគ្នានឹងចុងរជ្ជកាលហាស៍វម៌្មទី១
- ៩២៨ ប្រកាសអធិរាជភាពរបស់ខ្លួន
- ៩៣០ កសាងប្រាសាទភ្នំ នៅក្នុងប្រាសាទធំ—កោះកេរ្ដិ៍
- មានសិលាចារឹកបី គឺប្រាសាទបក្សីចាំក្រុង, ប្រាសាទអណ្ដូង និងប្រាសាទដំរី ថាព្រះអង្គបានកសាងសិវលិង្គធំ១ កម្ពស់៣៦ម៉ែត្រ តែគេហៅតាមឈ្មោះព្រះសិរះ៣ខុសគ្នា ដែលលោក សឺដេស មិនដឹងថាត្រូវនឹងសិវលិង្គនៅប្រាសាទណា៕

## ផែនទីតំបន់កោះកេរ្ដិ៍នៃអតីតរាជធនីឆោកគគីរ



# ប្លង់ ទីក្រុងឆោកគរគី_កោះកេរ្តិ៍






ប្រាសាទលិង្គនៃអតីតរាជធានីឆោកគីរនៅខាងជើងបារាយណ៍រហាល






# សិទ្ធបព៌តនៅកម្ពុជា ដែលជយទម៍ទី៤ស្ថាបនាបន្ថែម



សិវលិង្គនៅភ្នំព្រះធាតុស្រុកសាមគ្គីមានជ័យមើលពីទិសអាគ្នេយ៍



# លិង្គបព៌តនៅកម្ពុជា ដែលជាយថាទីទី៤ស្ពានបន្ថែម



លិង្គាទ្រិប្បលិង្គបព៌តមើលពីទិសឧត្តរត្រង់ទំនប់បាក់



លិង្គបព៌ត មើល ពីទិស ខាង ត្បូង






លិង្គាទ្រិនៅភ្នំព្រះធាតុ
នៅលើប្រាសាទថ្ម
បាយក្រៀមក្នុងរាជ្យ
ព្រះបាទជយវម៌្មទី៤
ដែលស្ថាបនាពីលើ
ខឿនប្រាសាទចាស់ធ្វើ
ពីឥដ្ឋបាក់បែកក្នុងរចនាបថ
សំបូរព្រៃគុកសតវត្សរ៍ទី៧

# លិង្គបព៌តនៅវត្តត្បូកៅ





## លិង្គបព៌តនៅភ្នំត្បូកៅវត្តត្បូ



# លិង្គបព៌ត នៅជ្រោយវ៉ារេល្លា



# លិង្គបព៌ត នៅមីសឺន



លិង្គបព៌ត នៅដាំរីខេត្តឡាំដុង



លិង្គបព៌ត នៅដាំរីខេត្តឡាំដុង



៣.ការវិលត្រឡប់មកយសោធរបុរៈវិញ



៣ - ប្រាសាទបក្សីចាំក្រុង

•ប្រាសាទបក្សីចាំក្រុង

•_ប្រាសាទភ្នំ សាងដោយព្រះបាទហស៍វម៌្មទី១ ទំនងជាបង្ហើយដោយរាជេន្ទ្រវម៌្ម ជាបុត្រាដើមរបស់ព្រះបាទជយវម៌្មទី៤

•_ស្ថិតនៅជើងភ្នំបាខែង ភាគឥសាន

•_មានចារឹករឿងនិទានស្តីពីដើមកំណើតនៃសន្តតិវង្សធំពីរដែលបានបង្កើតកម្ពុជទេសនៅសម័យអង្គរ គឺសោមវង្ស (កៅណ្ឌិន្យ+សោមា) និងសូរ្យវង្ស(កម្ពុ+មេរា)

៣.ការវិលត្រឡប់មកយសោធរបុរៈវិញ



៥ - ប្រាសាទប្រែរូប

•ប្រាសាទប្រែរូប

•ប្រាសាទភ្នំនៅលើវាលរាបដែលសាងដោយព្រះបាទរាជេន្ទ្រវម៌្ម (៩៤៤_៦៨)នៅឆ្នាំ៩៦១(មើលពីខាងក្រោយឬខាងលិច)

•មានតួប៉មដែលធ្វើពីឥដ្ឋបូកបាយអ

•មានចារឹកអត្ថបទមួយផ្ទាំងធំជាភាសាសំស្ក្រឹតដែលវែងជាងសិលាចារឹកទាំងអស់របស់កម្ពុជា

# ៣. ការកសាងរាជធានី ៖ ជយេន្ទ្រនគរីប្រាសាទកែវ

- ហេមស្រឹង្គគិរី៖ ប្រាសាទកែវ ឬ តាកែវ ជាប្រាសាទស្នូលនៃរាជធានីជយេន្ទ្រនគរី
- ផ្ដើមកសាងដោយ ព្រះបាទជយវម្ម័ទី៥ (សិលាចារឹកប្រាសាទគោកពោធិ៍ ឬស្ទែតទ្វីបរបស់តេងត្វនព្រះមន្ទីរ និយាយពីរឿងនេះ កសាងព្រះមន្ទីរជយេន្ទ្រនគិរី)
- បោះបង់ចោលដោយ ព្រះបាទសូរ្យវម្ម័ទី១ ដោយសាររន្ទះបាញ់។
- តាមពិតព្រះអង្គបានប្រើព្រាហ្មណ៍ យោគីស្វរបណ្ឌិត ជាកូនប្រុសារ ឱ្យទិញថ្មបន្តកសាងបង្ហើយ។
- ថ្មត្រូវបានលើកបន្តុបរួចរាល់ តែមិនទាន់បានវិចិត្ររចនាឱ្យស្អាតល្អផង ក៏ត្រូវរន្ទះបាញ់ ក៏បញ្ឈប់ការដ្ឋានសំណង់។
- ទើបគេឃើញប្រាសាទនេះសាងមិនទាន់ស្រេច (សូមមើលរូបនៅទំព័របន្ទាប់)

# ៣. ការកសាងរាជធានី ៖ ជយេន្ទ្រនគរីប្រាសាទកែវ



# ៣. ការកសាងរាជធានី ៖ ជយេន្ទ្រនគរី ប្រាសាទតាកែវ




# ៣. ការកសាងរាជធានី ៖ យសោធរបុរៈ២ ប្រាសាទបាពួន





៣ – យសោធរបុរីទី II ប្រាសាទបាពួន – បារាយណ៍ខាងលិច



៧ - ប្រាសាទបាពួន

ប្រាសាទភ្នំមាសតម្កល់សិវលិង្គឈ្មោះត្រីភូវនេស្វរៈ(ភូវន>ភួន>ពួន)

ជាស្នូលនៃរាជធានីយសោធរបុរៈទី២របស់ព្រះបាទឧទយាទិត្យវរ្ម័ទី២

(១០៥០>១០៦៦គ.ស.)

# ៣. ការកសាងរាជធានី ៖ យសោធរបុរៈ៣ អង្គរវត្ត




*Figure 27* Yaśodharapura, phase 3. The triangles indicate foundations made in the first three quarters of the twelfth century.

# ៣. ការកសាងរាជធានី ៖ យសោធរបុរៈ៣ អង្គរវត្ត




Carte de la région d'Aṅkor, mettant en relief l'ancien cours présumé de la rivière de Siem Râp.

# ៣. ការកសាងរាជធានី ៖ យសោធរបុរៈ៣ អង្គរវត្ត






## ៣. ការកសាងរាជធានី ៖ យសោធរបុរៈ៤ បាយ័ន



ប្រាសាទបាយ័នកសាងដោយព្រះបាទជយវម៌្មទី៧(១១៨១_១២២០)មានតួប៉ម

ចំនួន៥៤(រាប់ទាំងខ្លោងទ្វារ៥)ប្រហែលត្រូវនឹងអាយុឡើងសោយរាជ្យរបស់ព្រះអង្គ



១០ - ប្រាសាទបាយ័ន



# មេរៀនទី៤

# សម័យអង្គរ និង អារ្យធម៌

# ដូចម្ដេចហៅថា «អរិយធម្ម/អារ្យធម៌» ?

- «ធម៌» មានន័យថា ក្បួន, ខ្នាត, ច្បាប់, ភាវៈទ្រទ្រង់, ភាវៈពេញលេញ មានរូបរាង និងមុខងារ ដំណើរការតាមធម្មជាតិ និងច្បាប់របស់វា
- «អារ្យ» ឬ «អរិយៈ» ជាភាវៈរីកចម្រើន, ខ្ពង់ខ្ពស់, ថ្កើងថ្កាន, ឧត្តុង្គឧត្តម...
- អារ្យធម៌ គឺ អ្វីៗទាំងអស់ដែលខ្ពង់ខ្ពស់ ចម្រើន ជឿនលឿន ដែលមនុស្សភាគច្រើនឱ្យតម្លៃ និងចង់បាន ចង់ធ្វើតាម។ បើអ្វីៗទាំងនោះ គេឃើញហើយ មិនចង់បាន មិនចង់ធ្វើតាម  មិនអាចចាត់ទុកជាអារ្យធម៌នោះទេ។
- civilization |ˌsɪvɪlʌɪˈzeɪʃ(ə)n| (also civilisation) noun [ mass noun ] the stage of human social development and organization which is considered most advanced : the Victorians equated the railways with progress and civilization.

# Civilization

- the process by which a society or place reaches an advanced stage of social and cultural development and organization.
- the society, culture, and way of life of a particular area.

Similar to “advancement”, “progress”, “enlightenment”

# ៤. ការកសាងប្រាសាទនិងបារាយណ៍

- ការកសាងប្រាសាទ និងបារាយណ៍ គឺជាវប្បធម៌ដ៏សំខាន់របស់ខ្មែរនាសម័យអង្គរ ដើម្បីជំនឿសាសនា និងការប្រកួតប្រជែងកេរ្តិ៍ឈ្មោះ។
- ប្រាសាទអង្គរវត្ត ឬ អង្គរធំ-បាយ័ន បង្ហាញអំពីគុណតម្លៃនៃគំនិតច្នៃប្រឌិត ចេញជាសំណង់ដ៏ធំអស្ចារ្យ ស្ថាបត្យកម្មស្មុគស្មាញ ដែលគ្មានប្រទេសកាន់ព្រហ្មញ្ញសាសនាដូចគ្នាមួយណាអាចធ្វើសំណង់ដ៏ធំសម្បើមអំពីថ្មបែបនេះ នៅពេលជាមួយគ្នានោះ សូម្បីនៅស្រុកឥណ្ឌាដែលជាម្ចាស់វប្បធម៌។
- សំណង់ប្រាសាទមានរចនាបថស្ថាបត្យកម្មខុសៗគ្នា និងបង្ហាញពីស្នាដៃកាន់តែឆើតឡើងៗ។
- គូទឹកបានប្រែក្លាយមុខងារខ្លួន ទៅជានយោបាយធារាសាស្ត្រ បម្រើផលប្រយោជន៍ខាងកសិកម្ម និងសង្គមកិច្ច (ស្រោចស្រពវាលស្រែចំការ និងប្រើក្នុងជីវភាពប្រចាំថ្ងៃ_នៅខែប្រាំង)

# ៤. ការកសាងប្រាសាទនិងបារាយណ៍

- តម្រូវការខាងសំណង់សម្រាប់ព្រះ ត្រូវធ្វើតាមទ្រឹស្តីលោកធាតុ គឺពិភពលោកត្រូវព័ទ្ធដោយទឹកសមុទ្រជៀស(Cosmology > Microcosmose) នាំឱ្យធ្វើប្រាសាទត្រូវព័ទ្ធដោយគូទឹក ដែលជារចនាសម្ព័ន្ធមិនអាចខ្វះមួយណាបាន៕ ជាចំណុចខុសគ្នាស្រឡះពីប្រាសាទនៅស្រុកឥណ្ឌា៕

- គូទឹកបានប្រែក្លាយមុខងារខ្លួន ទៅជានយោបាយធារាសាស្ត្រ បម្រើផលប្រយោជន៍ខាងកសិកម្ម និងសង្គមកិច្ច (ស្រោចស្រពវាលស្រែចំការ និងប្រើក្នុងជីវភាពប្រចាំថ្ងៃ_នៅខែប្រាំង)

- ខ្មែរសម័យអង្គរ ប្រមូលផល៣_៤ដងក្នុងមួយឆ្នាំ(ជីវតាក្វាន់) នេះហើយជាមូលដ្ឋានសេដ្ឋកិច្ចដ៏សំខាន់របស់អង្គរ៕

# ៤. ការកសាងប្រាសាទនិងចម្លាក់យំណើ

- ប្រាសាទមិនត្រឹមជាកន្លែងតម្កល់ទេវរូប ឬបដិមាជាទីសក្ការៈសម្រាប់គោរពបូជាប៉ុណ្ណោះទេ
- ជាកន្លែងមជ្ឈមណ្ឌលវប្បធម៌ និងសាសនាដ៏សំខាន់របស់ខ្មែរ គឺកន្លែងសិក្សាខាងទស្សនវិជ្ជាសាសនា និងវិជ្ជាជីវៈជាច្រើន៕ ជាកន្លែងផ្តល់នូវពត៌មាន ចំណេះដឹងដល់មនុស្សគ្រប់វ័យ ព្រោះប្រាសាទតែងតែមានអមដោយអាស្រម ដែលជាសាលារៀន និងជារោងជាងសម្រាប់អប់រំ និងបណ្តុះបណ្តាលយុវវ័យក្នុងស្រុកផងដែរ ៕
- ជាកន្លែងបម្រើឱ្យវិស័យសង្គមកិច្ច និងសុខាភិបាល៕ ព្រោះជួនកាល ពេលឈឺថ្កាត់ អ្នកស្រុកត្រូវពឹងពាក់គ្រូហ្មជាអ្នកបួសនៅទីនោះ និងបន់ស្រន់បួងសួងសូមសេចក្តីសុខ ពីអាទិទេពដែលខ្លួនគោរពនៅក្នុងសហគមន៍នីមួយៗ
- ជាមជ្ឈមណ្ឌលសម្រាប់ការប្រមូលផ្តុំគ្នាប្រារព្ធធ្វើពិធីបុណ្យប្រពៃណីជាតិផ្សេងៗ

សំណុំប្រាសាទនៅអង្គរផ្ទុះសំណុំផ្កាយនាគ កាលពី២០០០០ឆ្នាំមុន



## ប្លង់ប្រាសាទព្រះវិហារឬស្រីសិខរីស្វរ:










Vong Sotheara & Nop Sokha- History Dept.






## ៤_ប្រាសាទភ្នំរុង _ នៅប្រទេសថៃ



# ៤.ប្រាសាទភិម៉ៃ នៅនគររាជសីមា ប្រទេសថៃ






# ៤_ប្រាសាទវត្តភូ - ប្រទេសឡាវ



# ៤_ប្រាសាទអង្គរវត្ត

• កសាងដោយសូរ្យវម៌ទី២(១១១៣_១១៥០) ដើម្បីឧទ្ទិសថ្វាយព្រះវិស្ណុ និងជាទីបច្ឆាមរណៈរបស់ព្រះអង្គដែលមាននាមថា បរមវិស្ណុលោក



# ៤. ប្លង់ប្រាសាទបន្ទាយឆ្មារ

• កសាងនៅឆ្នាំ១២១៦គស
• ឧទ្ទិសចំពោះមេទ័ព,កងទ័ព និងរាជគ្រូ
• ជាប្រាសាទរំឭកគុណអ្នកប្រយុទ្ធដើម្បីផែនដីរបស់ព្រះអង្គ



## រូបវីរក្សត្របង្ក្រាបអ្នកបះបោរឈ្មោះតរតរាហុ



## ៤_ប្រាសាទព្រះខ័ន



៩ - ប្រាសាទព្រះខ័ន

- ប្រាសាទឧទ្ទិសថ្វាយព្រះបិតាព្រះបាទជយវម៌ទី៧
- ឈ្មោះដើម ជយស្រី កសាងនៅឆ្នាំ១១៩១
- តាមសិលាចារឹករបស់វីរកុមារ និងសូរ្យកុមារ ដែលជាបុត្រា១អង្គរបស់ព្រះបាទជយវម៌ទី៧ ជាមួយព្រះជាយារាជេន្ទ្រទេវី បានបង្ហាញអំពីទ្រព្យសម្បត្តិមហាសាល ទាំងអចលនទ្រព្យ និងចលនទ្រព្យ ជាពិសេសខ្ញុំបម្រើរាប់សែននាក់ដែលជាជនជាតិចាម, មន និងមនបាហ្គន

# ប្រាសាទនាគព័ន្ធកណ្តាលបារាយណ៍ជយតដាករបស់ជយវម៌្មទី៧



Figure 50 1995

- ប្រាសាទស្រះថ្នាំបុរាណសម្រាប់ព្យាបាលជំងឺ
- ក្នុងប្រាសាទនេះមានស្រះប្រាំ,ស្រះធំ១នៅចំកណ្តាលគេធ្វើប្រាសាទឧទ្ទិសថ្វាយព្រះពោធិសត្វលោកេស្វរៈដែលខឿនប្រាសាទមានរាងជាកោះមូលទ្រទ្រង់ដោយនាគ១គូ៕
- ស្រះ៤ទៀតតូចជាងស្រះកណ្តាលដែលស្ថិតនៅក្រៅជាប់ជ្រុងទាំង៤នៃស្រះកណ្តាលនិងភ្ជាប់ស្រះធំនេះដោយរន្ធបង្ហូរមួយ៕
- រន្ធបង្ហូរទឹកភ្ជាប់ពីស្រះធំទៅស្រះតូចជ្រុងខាងកើតមានរូបក្បាលមនុស្សជានិមិត្តរូប,ទៅស្រះតូចជ្រុងខាងត្បូងមានក្បាលគោ,ទៅស្រះតូចជ្រុងខាងលិចមានក្បាលសេះនិងទៅស្រះតូចជ្រុងខាងជើងមានក្បាលដំរី៕

Figure 49 Lokeśvara, northern face of Neak Pean's central sanctuary, 1938.



# ៤_ការកសាងប្រាសាទ និងបារាយណ៍

- ខ្លោងទ្វារប្រាសាទព្រះបាឡិល័យ
- ប្រាសាទឧទ្ទិសពុទ្ធរាជនៅចុងសតវត្សរ៍ទី១២ និងស វ ទី១៣
- មានព្រះពុទ្ធរូបនៅចំពីមុខផ្លូវចូល
- ចម្លាក់ពិពណ៌នាអំពីរឿងសម័យពុទ្ធកាល និងរឿងវេស្សន្តរជាតក ដែលជាជាតកប្រពៃណីក្នុងពុទ្ធសាសនាថេរវាទភាសាបាលី






# ៥_ផ្លូវគមនាគមន៍សម័យអង្គរ

**Appendix 14** **Distributions of indicators of decentralised administration (cont.)**




Figure A 14.3 Sites with mentions of courts and court officials

Figure A 14.4 Sites with mentions of exchange

# ៥_បណ្ដាញគមនាគមន៍

- ផ្លូវគមនាគមន៍ខ្មែរសម័យបុរាណមាន៥ខ្សែ ពីអង្គរទៅបណ្ដាខេត្ត ដែលមានសំណល់ស្ពាន
- តើជាផ្លូវសម្រាប់ធ្វើអ្វី? គឺជាផ្លូវដើម្បីផលប្រយោជន៍ខាងនយោបាយ និងសេដ្ឋកិច្ច ដែលគេថា
- ងាយស្រួលក្នុងការទំនាក់ទំនងពាណិជ្ជកម្ម (ជំនាន់អាណាព្យាបាលបារាំង)
- បម្រើផលប្រយោជន៍ផ្នែកយោធា (លោក ហ្ស៊ុយណូ ហ្ស៊ូគីយេ) ពីព្រោះរូបចម្លាក់នៅប្រាសាទបាយ័ន+បន្ទាយឆ្មារបង្ហាញពីកងទ័ពកំពុងដើរឆ្លងកាត់ស្ពាន
- ផ្លូវសម្រាប់មហាក្សត្រធ្វើការផ្សព្វផ្សាយអំណាចឥទ្ធិពល ដើម្បីធានាឱ្យមានឯកភាពក្នុងការដឹកនាំក្នុងអាណាចក្រដ៏ធំធេង
- ការដឹកជញ្ជូនតាមគោក_ប្រហែលជានិយមជើងទឹកជាង
- វិសាលភាពនៃបណ្ដាញគមនាគមន៍ ជាតឹកតាងបញ្ជាក់ពីកិត្តិស័ព្ទល្បីល្បាញរបស់ខ្មែរសម័យបុរាណ

# ៥. ស្ពានកំពង់ក្ដី ឬស្ពានប្រាប់ទិស





# ៦. សង្គមកិច្ចៈ សាលាសម្នាក់ និងមន្ទីរពេទ្យ

- តាមបណ្តោយផ្លូវសំខាន់ទាំងប្រាំខ្សែ មានកសាងផ្ទះសំណាក់ ឬធម្មសាលា និង អារោគ្យសាលា
- តាំងពីរាជ្យយសោវម៌្មទី១មានការកសាង១០០យសោធរាស្រម និងទំនងមានការកសាងសាលាសំណាក់នៅតាមផ្លូវក្នុងផ្ទៃប្រទេសផងដែរ
- នៅរាជ្យ ជយវម៌ទី៧ មានធម្មសាលា១២១ អារោគ្យសាលា(មន្ទីរពេទ្យបុរាណ)១០២កន្លែង៕
- តាមផ្លូវពីរាជធានីយសោធរបុរទៅរាជធានីវិជយរបស់ចាម្ប មាន៥៧ធម្មសាលា និងភ្លើង
- ពីរាជធានីទៅដល់ទីក្រុងវិម៉ាយ(ភិម៉ៃ) មាន១៧ធម្មសាលា និងភ្លើង
- ពីរាជធានីទៅទីក្រុងជយវតី, ជយសិង្ហវតី, ជយវីរវតី, ជយរាជគិរី, ស្រីជយសុវីរបុរី, មកដល់យសោធរបុរៈវិញ មាន១៤ធម្មសាលា និងភ្លើង
- ផ្លូវពីរាជធានីទៅភវបុរៈ និងឥន្ទ្របុរៈ និងផ្លូវពីរាជធានីទៅស្តុកកក់ធំ គ្មានបញ្ជាក់ចំនួនថែម
- ១នៅសូរ្យបវ៌តគឺភ្នំជីសូរ, ១នៅវិជយាទិត្យបុរៈ, ១នៅកល្យាណសិទ្ធិកៈ សរុប១២១

# ៧-សង្គមកិច្ចៈ មន្ទីរពេទ្យ

- សិ ចា សាយហ្គុង(វៀងច័ន្ទ_ឡាវ) មាន៖
- គ្រូពេទ្យជំនាញ២នាក់អ្នកទទួលខុសត្រូវ+ឧបការី+ផ្គត់ផ្គង់ស្បៀង+ថ្នាំបុរាណ+ដាំបាយ+ដាំទឹក+អ្នកបម្រើផ្សេងៗ សរុបជាង៩០នាក់ នៅបម្រើការតាមអារោគ្យសាលានីមួយៗ៕
- អនុញ្ញាតប្រជាជនគ្រប់វណ្ណៈមិនរើសអើង៕
- ជយវម៌ទី៧ត្រូវគេគិតថា ជាស្តេចគំលង់៕ ព្រោះយល់ច្រឡំបដិមា និមរាជ ដែលស្ថិតនៅទីលានស្តេចគំលង់ទិសពាយ័ព្យនៃរាជវាំងអង្គរធំ ដែលជាកន្លែងវាលមេរុ សម្រាប់បូជាសពរាជវង្ស ជាមួយរឿងព្រេងស្តេចគម្លង់, និងរូបចម្លាក់នៅប្រាសាទបាយ័ន ដែលបង្ហាញពីអ្នកធំម្នាក់កំពុងឈឺនៅចុងដៃជើង និងមានថានដាក់ផ្លែក្របៅមួយ ដែលសម្រាប់ព្យាបាលជម្ងឺឃ្លង់ពីបុរាណ៕

# ៨. ការអប់រំ

- ប្រាសាទជាច្រើនមានអមដោយអាស្រម ដែលជាវិទ្យាល័យ និងមហាវិទ្យាល័យខាងសាសនា
- ចំណេះដឹងវិជ្ជាសាស្ត្រទាំងឡាយនៅជំនាន់នោះត្រូវពឹងផ្អែកលើទ្រឹស្តីសាសនា ឬការបកស្រាយតាមបែបទស្សនវិជ្ជាសាសនា (ព្រហ្មញ្ញសាសនា និងពុទ្ធសាសនា)
- គ្រូបង្រៀន គឺជាព្រាហ្មណ៍ ឬព្រះសង្ឃក្នុងពុទ្ធសាសនា
- មានគ្រូពីរប្រភេទ
- ១_អធ្យាបកៈ (គ្រូបង្រៀននៅតាមអាស្រមផ្ទាល់)
- ២_គុរុ ដែលជាព្រាហ្មណ៍ ឬក៏ជាបណ្ឌិត និមន្តមកពីខាងក្រៅបរិវេណប្រាសាទ)

# ៨. ការអប់រំក្នុងរាជ្យយសោវម្ម័នទី១

- អាស្រម៖ វិទ្យាល័យ ឬសាកលវិទ្យាល័យ ដូចមានភស្តុតាងនៅប្រទេសម៉ាឡេស៊ីសព្វថ្ងៃ គេហៅអន្តេវាសិកដ្ឋានសាកលវិទ្យាល័យ ថា អាស្រម (លោកស្រីបណ្ឌិត ពៅ សាវរស អះអាង)
- ព្រះបាទយសោវម្ម័ទី១ បានកសាងអាស្រមសំខាន់ៗដូចជា៖ ក្រៅពី ១០០យសោធរាស្រម ឬ១០០វិទ្យាល័យ នៅមានសាកលវិទ្យាល័យ៤ទៀត
- ព្រាហ្មណាស្រម(សាលានិស្សិតភក្តីភាពចំពោះព្រះសីវៈ ឬឥសូរ) បើតាមសិលាចារឹកព្រៃប្រាសាទ
- វៃស្ណាវាស្រម (សាលានិស្សិតភក្តីចំពោះវិស្ណុ ឬព្រះនារាយណ៍)បើតាមសិលាចារឹកប្រាសាទកំណប់
- សៅគតាស្រម (និស្សិតភក្តីចំពោះពុទ្ធសាសនាមហាយាន_នៅប្រាសាទបាតជុំ) បើតាមសិលាចារឹកទេពប្រណម (G. Cœdès, 1989:253-63)
- ចំណែកព្រះរាជគ្រូសិវសោម និងវាមសិវៈ បានកសាង សិវាស្រម ដ៏ល្បីល្បាញ, K.235

# ៨. ការអប់រំក្នុងរាជ្យជ័យវរ្ម័នទី៧



- តាមសិលាចារឹកព្រះនាងឥន្ទ្រទេវី ថានៅក្នុងរាជ្យព្រះបាទជយវម៌ទី៧ មានសាកលវិទ្យាល័យមួយចំនួនដូចជា
- _ជយស្រី (ប្រាសាទព្រះខ័ន)
- _រាជវិហារ (ប្រាសាទតាព្រហ្ម)
- _នគេន្ទ្រទុង្គ (មិនស្គាល់កន្លែង)
- _នរេន្ទ្រាស្រម ខាងពុទ្ធសាសនា (មិនស្គាល់កន្លែង)
- _តិលកោត្តរ (មិនស្គាល់កន្លែង តាមអ៊ានហារីស)

## បណ្ណាល័យប្រាសាទព្រះខ័ន ដែលកសាងនៅឆ្នាំ១១៩១



បណ្ណាល័យប្រាសាទបាយ័នដែលកសាងដោយព្រះបាទជយវរ្ម័ទី៧



ប្រាសាទរាជវិហារ ហៅតាព្រហ្ម កសាងនៅឆ្នាំ១១៨៦
ដើម្បីឧទ្ទិសថ្វាយព្រះរាជមាតារបស់ព្រះបាទជយវរ្ម័ទេវទី៧





## ប្រាសាទប្រាតជុំ ជាសៅគតាស្រម
## របស់ព្រះបាទយសោវម៌្មទេវទី១ (៨៨៩-៩១០គ.ស.)








# ២.(៩) សញ្ញាណទស្សនវិជ្ជាខ្មែរសម័យអង្គរ

### បទបញ្ញត្តិខ្លះ

- K.444 នៅកំពង់ស្វាយ, K.868 នៅទួលទងចាស់ ខេត្តបន្ទាយមានជ័យ និងK.175 គោកឫស្សីនៅសៀមរាប
- ជយវម៌្មទី៥ ធ្វើពិធី «ព្រហ្មយជ្ញ មហាទ្វារ»សម្ពោធការបញ្ចប់ការសិក្សាជាមួយរាជគ្រូនៅឆ្នាំ៩៧៥ ទ្រង់បានប្រកាសបង្កើត វណ្ណៈ(ក្រុមការងារជំនាញ)ពីរ បន្ថែមលើវណ្ណៈចំនួនប្រាំពីរ ដែលព្រះអង្គមានក្នុងពេលនោះ
- ខ្ទុកព្រះក្រលាអច្ឆិនៈ (អ្នកបួសបូជានៅអាសនព្រះ ឬអ្នកធ្វើខ្ទុក កំបោរ?) និង
- កម្ម៉ាន្តរៈ (មានបន្សល់ទុកក្នុងសង្គមឥណ្ឌាសតវត្សរ៍ទី១៩ ហៅក្រុមប្រកបរបរធ្វើពិធីបុណ្យខ្មោច ឬភ្នាក់ងារខាងរៀបចំចាត់ចែងពិធីបុណ្យសពសម្រាប់រាជវង្សានុវង្ស )
- ព្រះរាជាកំណត់ថា មន្ត្រីរាជការទៅថ្ងៃអនាគតអាចតែងតាំងបាន លុះត្រាតែធ្លាប់បួសនៅក្នុងវណ្ណៈពីរនេះឯង៕

# ២.(៩) សញ្ញាណទស្សនវិជ្ជាខ្មែរសម័យអង្គរ

## ព្រះរាជប្បញ្ញត្តិ

- មានរាជប្បញ្ញត្តិជាច្រើនដែលព្រះរាជាបន្សល់ទុកនៅតាមសិលាចារឹក ដូចជា៖
- ព្រះរាជាបានដាក់បញ្ញាតិឱ្យសមាជិកជាស្រ្តីភេទ ដែលអ្នកចេញពីក្រុមគ្រួសារជំនាន់ក្រោយនៃសន្តាន សិរកែវល្យ មានសិទ្ធិរៀបចំ និងធ្វើបុណ្យបូជានៅតាមប្រាសាទនានា ក្នុងករណីណាគ្រួសារនេះគ្មាន សមាជិកជាមនុស្សប្រុស៕ ស្រ្តីទាំងនោះ បើកាលណារៀបឱ្យមានគូរស្រករលុះត្រាតែប្តីនោះឯងជាអ្នក ជឿនិងគោរពចំពោះព្រះឥស្វរ
- មានសិលាចារឹកជាច្រើនទៀតដែលបានបញ្ជាក់អំពីសេចបញ្ញាតិទាំងឡាយ ទាក់ទងការលើកលែងពន្ធ អាករផ្សេងៗ ចំពោះប្រាសាទ នឹងការកំណត់ចំពោះភូមិ ស្រុក និងដីធ្លីមួយចំនួនដែលត្រូវស្ថិតនៅ ចំណុះ ឬមួយត្រូវថ្វាយនូវភស្តុភារជាប្រចាំចំពោះប្រាសាទ
- សិលាចារឹកខ្លះទៀតបានកត់ត្រាអំពីការសម្រេចក្តី (សាលក្រម) របស់តុលាការ ក្រោមការបង្គាប់បញ្ជា របស់ព្រះមហាក្សត្រក្នុងការដោះស្រាយវិបត្តិ ឬក៏ទំនាស់ដីធ្លី៕

# ២.(៩) សញ្ញាណទស្សនវិជ្ជាខ្មែរសម័យអង្គរ

គំនិតទស្សនវិជ្ជារបស់ខ្មែរសម័យអង្គរ ត្រូវបានឆ្លុះបញ្ចាំងតាមរយៈ

•«គំនិតច្នៃប្រឌិតមិនឈប់ឈរ» មិនសាងអ្វីៗឱ្យដូចរបស់អ្នកដទៃ_អក្សរ, សំណង់

•«ការឱ្យតម្លៃលើវីរភាព, ភក្តីភាព និងកតញ្ញូតាធម៌» តាមគម្រូគំនិតអក្សរសិល្ប៍សាសនារបស់ឥណ្ឌា ដែលជាក់ស្តែងបង្ហាញដោយផ្ទាំងរូបចម្លាក់

•ការគិតអំពីផលប្រយោជន៍សាធារណៈជាធំ(ឬប្រយោជន៍សាធារណៈធំជាងប្រយោជន៍ផ្ទាល់ខ្លួន)

•ការចាត់ទុកតម្លៃនៃបុណ្យរបស់អ្នកថែរក្សា ដូចតម្លៃនៃបុណ្យរបស់អ្នកកសាងដែរ និង

•ការចាត់ទុកបុណ្យ ឬបាបរបស់សមាជិកសន្តានម្នាក់ គឺជាបុណ្យឬបាបរបស់សមាជិកសន្តានទាំងមូល_ធ្វើឱ្យមនុស្សក្នុងសន្តាននីមួយៗចេះដាស់តឿនគ្នា

# ២.(៩) សញ្ញាណទស្សនវិជ្ជាខ្មែរសម័យអង្គរ

- ការប្រើមនុស្សដែលប្រឆាំងគ្នា និងប្រកួតប្រជែងគ្នា ឱ្យបំពេញភារកិច្ចតែមួយ។ ដូចជា ការដាក់ទេវតាតំណាងសភាវៈល្អ និងយក្សតំណាងឱ្យសភាវៈអាក្រក់អង្គុយយាមច្រកចូលរាជធានី និងប្រាសាទដូចគ្នា ដើម្បីញ៉ាំងប្រយោជន៍ខាងសន្តិសុខ
- ការផ្សះផ្សារសត្រូវឱ្យក្លាយជាមិត្តដោយសន្តិវិធី ដោយប្រើគោលដៅរួមរបស់គូសត្រូវធ្វើជាស្នូលនៃការរួបរួមគ្នាឡើងវិញ ដូចជាគ្រុឌ និងនាគ
- «ទុក្ខរបស់ប្រជារាស្ត្រធំជាងទុក្ខរបស់ព្រះមហាក្សត្រ» ដែលលោក សឺដេស អះអាងថា មានតែមេដឹកនាំប្រទេសនៅសតវត្សរ៍ទី២០ប៉ុណ្ណោះ ដែលមានឆន្ទៈ និងស្មារតីទទួលខុសត្រូវបែបនេះ
- ចិញ្ចឹមក្សត្របរទេសឱ្យវាយគ្នាឯង ដើម្បីអាចគ្រប់គ្រងគេបាន(ករណីចាម្ប)

# ២.(៩) សញ្ញាណទស្សនវិជ្ជាខ្មែរសម័យអង្គរ

- ព្រះបាទជយវរ្ម័ទី៧ ឧទ្ទិសឱ្យប្រជារាស្ត្ររបស់ព្រះអង្គមានសុខភាពល្អ ចាកផុតពីជំងឺបៀតបៀនដោយសារកុសលបុណ្យកើតពីការកសាងមន្ទីរពេទ្យ
- ដោយព្រះអង្គចាត់ទុកអារោគ្យសាលាជាប្រទេស, អ្នកជំងឺជាសមរភូមិ, ជំងឺជាខ្មាំងឈ្លានពាន, គ្រូពេទ្យ ជាយុទ្ធជន, ការព្យាបាល ជាការប្រយុទ្ធប្រឆាំងសត្រូវ, ឱសថជាអាវុធ,
- ទុក្ខបណ្តាលមកពីជំងឺរបស់ប្រជារាស្ត្រ មានទំហំធំជាង, ឈឺជាងទុក្ខដែលកើតពីការឈឺចាប់ដោយសារជំងឺលើព្រះកាយព្រះអង្គ (ទុក្ខប្រជារាស្ត្រធំជាងទុក្ខរបស់អ្នកដឹកនាំ, ព្រះមហាក្សត្រ)

# ២.(៩) សញ្ញាណទស្សនវិជ្ជាខ្មែរសម័យអង្គរ

- ”ទេហេនា ម្មេហរោគោ យន្មនោរោគោ រុជត្តរាមិរាម្រ្តទុះខំ ហិភត្ត្ឫណាន្ទុះខន្ទុះខន្ទុនាត្មនះ”
- *dehinām deha rogo yanmanorogo rujattarām rāṣṭra duḥkham hi bharṛrnān duḥkhan duḥkhan tu Nātmanaḥ"*
- *Translated as "the bodily pain of the diseased became in Him a mental agony more tormenting than the former. For the real pain of a King is the pain of his subjects, not that his own (body)"*
- «ក្តីឈឺចាប់ក្នុងប្រាណបណ្តាលពីរោគាបៀតបៀនរបស់ព្រះអង្គ គឺគ្រាន់តែជាក្តីឈឺផ្សារាងកាយខាងក្រៅ មិនធ្ងន់ធ្ងរដូចទារុណកម្មខាងផ្លូវចិត្តនោះទេ។ ទុក្ខរបស់រាស្ត្រ(ប្រជាជាតិ និងរដ្ឋ) ទើបជាទុក្ខពិតប្រាកដរបស់ព្រះមហាក្សត្រ។ ពោលគឺមិនមែនទុក្ខលើរាងកាយព្រះអង្គផ្ទាល់នោះឡើយ»។

# ២.(៩) សញ្ញាណទស្សនវិជ្ជាខ្មែរសម័យអង្គរ

- ការសាងអ្វីៗឱ្យខុសពីរបស់អ្នកដទៃ ដែលជាគំនិតវិទ្យាសាស្ត្រដ៏អស្ចារ្យ
- អក្សរសាស្ត្រ៖ ខ្មែរបានអភិវឌ្ឍន៍ទម្រង់ដើមនៃតួអក្សរ បល្លវៈ ដែលខ្មែរបានយកជាគំរូតាំងពីសតវត្សទី៣ ឬទី៥មកនោះ ឱ្យក្លាយជាទម្រង់អក្សរដែលមានលក្ខណៈឯករាជ្យដាច់ចេញពី ទម្រង់អក្សរបល្លវៈ ៕ អក្សរនេះព្រះរាជាខ្មែរ យសោវម៌ទី១ បានឱ្យនាមថា «កម្វុជាក្សរ» មានន័យថា អក្សរកម្ពុជា
- ស្ថាបត្យកម្ម៖ ខ្មែរបានច្នៃប្រឌិតបែបផែនរចនាសម្ព័ន្ធសំណង់ ឱ្យមានលក្ខណៈវឌ្ឍនភាពដោយប្រើប្រាស់បណ្តុំនៃបទពិសោធន៍ពីការកសាងនៅជំនាន់ចាស់ ដើម្បីច្នៃប្រឌិតបង្កើតស្នាដៃថ្មី ដែលខុសពីស្នាដៃចាស់ ទៅតាមបែបផែនសំណង់និម្មាបនកម្ម ឬធ្វើសំណង់ថ្មីៗឱ្យមានលក្ខណៈសម្បត្តិខាងសិល្បៈកាន់តែល្អ, ឆើត និងអស្ចារ្យជាងមុន

# ២.(៩) សញ្ញាណទស្សនវិជ្ជាខ្មែរសម័យអង្គរ

- និម្មាបនកម្ម៖ស្នាដៃដ៏មហស្ចារ្យប្រៀបដូចទេពនិមិត្ត។ ឧទាហរណ៍៖ ស្ថាបត្យកម្មប្រាសាទអង្គរវត្ត គឺជា និម្មាបនកម្ម របស់ដូនតាខ្មែរ តែខ្មែរសម័យកណ្តាលមិនជឿថា នេះជាស្នាដៃសាងដោយមនុស្ស
- ក្បាច់ចម្លាក់៖ ក៏មានការអភិវឌ្ឍន៍ឱ្យកាន់តែឆើត និងពោរពេញដោយខ្លឹមសារដែលបង្កប់ដោយន័យត្រង់ និងន័យធៀបនៅក្នុងនោះ។ រហូតធ្វើឱ្យអ្នកស្រាវជ្រាវខាងសិល្បៈ, ស្ថាបត្យកម្ម, និងសំណង់សិក្សាបែងចែករចនាបថសិល្បៈ ជាក្រុម និងតាមកាលសម័យ ដែលជាការមួយ ធ្វើឱ្យអ្នកសិក្សាងាយចំណាំបានអំពីអាយុកាលនៃប្រាសាទណាមួយ ដែលមិនបានទុកសិលាចារឹក ឬពត៏មានជាលាយលក្ខណ៍អក្សរឱ្យគេបានដឹង

# ២.(៩) សញ្ញាណទស្សនវិជ្ជាខ្មែរសម័យអង្គរ

- មានចម្លាក់រឿងរ៉ាវជីវភាពធម្មតារបស់មនុស្ស និងសង្គ្រាមនៅប្រាសាទបាយ័ន និងបន្ទាយឆ្មារ
- អក្សរសិល្ប៍វីរកថា_ចម្លាក់តាមជញ្ជាំងរោងទង នៃប្រាសាទអង្គរវត្ត និងបាយ័នបង្ហាញនូវទស្សនវិជ្ជាពីរប្រភេទដែលខ្មែរនៅសម័យអង្គរមាន និងជាមូលធម៌នៃសង្គមខ្មែរនៃសម័យអង្គរ ហើយចម្លាក់នៅប្រាសាទអង្គរវត្ត អាចឱ្យយើងយល់បានអំពីគំនិតរបស់មេដឹកនាំសម័យនោះ តាមរយៈអក្សរសិល្ប៍។

# ២.(៩) សញ្ញាណទស្សនវិជ្ជាខ្មែរសម័យអង្គរ

- រាមាយណៈ (សម័យក្រោយយើងហៅថារឿងរាមកេរ្តិ៍) បង្ហាញឱ្យយើងដឹងយ៉ាងហោចណាស់អំពីវិធីនៃ «ការដោះស្រាយជម្លោះដណ្តើមរាជ្យសម្បត្តិគ្នារបស់រាជ្យវង្សានុវង្សដោយសន្តិវិធី ដូចគំរូនៃការលះបង់រាជ្យសម្បត្តិរបស់ព្រះរាម» និងតំលៃនៃសភាវៈល្អ និងសភាវៈអាក្រក់ ដែលតែងតែកើតមានចំពោះចិត្តគំនិតរបស់មនុស្សម្នាក់ៗ និង
- រឿងមហាភារតៈ បង្ហាញឱ្យឃើញអំពី«ភាពក្លៀវក្លារបស់តួអង្គយុវក្សត្រ»នៅក្នុងតួនាទីជាអ្នកប្រយុទ្ធ, វាតទីនិងការពារទឹកដី ដើម្បីជាគំរូដល់ក្សត្រាទាំងឡាយនៅជំនាន់អង្គរ

# ២.(៩) សញ្ញាណទស្សនវិជ្ជាខ្មែរសម័យអង្គរ

- ឆាកយក្ស និងទេវតាកូរសមុទ្រទឹកដោះ បង្ហាញអំពីការប្រជែងគ្នារបស់មនុស្សល្អ និងមនុស្សអាក្រក់ ដែលមានគោលដៅដូចគ្នាមួយ គឺយកទឹកអំម្រឹត ដែលនឹងផុះចេញអំពីការងារយ៉ាងលំបាក និងប្រកបដោយក្តីព្យាយាមមួយ៕
- យក្ស និងទេវតាអង្គុយទាញនាគយាមខ្លោងទ្វារក្រុងអង្គរ នេះជាការបង្ហាញពីការប្រើប្រាស់មនុស្សអាក្រក់ និងមនុស្សល្អឱ្យធ្វើការរួមគ្នា៕ ដោយសារការប្រឆាំងគ្នារបស់ក្រុមទាំងពីរ អ្នកដឹកនាំនឹងអាចទទួលបានតែការពិត ជាក់ស្តែង ដែលអាចនាំឱ្យងាយដោះស្រាយបញ្ហាអវិជ្ជមានទាំងឡាយ៕
- នេះជាសារផ្ទុះបញ្ចាំងពីការអាស្រ័យគ្នាទៅវិញទៅមករវាងមនុស្សល្អនិងអាក្រក់នៅក្នុងសង្គមមនុស្សពិត ដែលអ្នកដឹកនាំប្រទេស ត្រូវតែទាញយកផលប្រយោជន៍ មិនត្រូវបោះបង់ពួកគេចោលឡើយ៕



23 *Brahma on* hamsa, *holding the magic weapon* brahmastra. *Angkor Wat, N gallery, W wing.* (*Photo: J. Poncar*).



24 *Indra on Airavata with four tusks and holding an enemy. Angkor Wat, N gallery, W wing. (Photo: J. Poncar)*

# ២.(៩) សញ្ញាណទស្សនវិជ្ជាខ្មែរសម័យអង្គរ

- ព្រះរាជាសម័យអង្គរ មានព្រះរាជហឫទ័យសណ្ដោសប្រណីតែស្ដេចទាំងឡាយណា មកឱនកាយក្រាបថ្វាយបង្គំចុះចូល ថ្វាយកតញ្ញូភក្ដីចំពោះព្រះអង្គ មុនពេលព្រះអង្គចល័តកងទ័ពទៅបង្ក្រាបតែប៉ុណ្ណោះ ៕ ផ្ទុយទៅវិញ ព្រះអង្គមិនអនុគ្រោះឱ្យស្ដេចទាំងឡាយណា ដែលចុះចាញ់នៅពេលព្រះអង្គកម្រើកកងទ័ពឡើយ៕
- ព្រះមហាក្សត្រ គឺជាចក្រពត្តិ ដែលច្បាំងឈ្នះស្ដេចសឹកទាំងឡាយ៕
- គោលការណ៍របស់ព្រះរាជានៅសម័យអង្គរ ដែលជាអ្នកកាន់ និងគោរពព្រហ្មញ្ញសាសនានោះ ត្រូវតែប្រកាន់តួនាទីជាមហាក្សត្រសឹក ដែលចាំបាច់ត្រូវតែធ្វើសង្គ្រាមវាតទីទឹកដី ជាជាងការរង់ចាំឱ្យសត្រូវឈ្លានពានហើយទើបនាំទ័ពទៅទប់ទល់ជាក្រោយ ៕

# ២.(៩) សញ្ញាណទស្សនវិជ្ជាខ្មែរសម័យអង្គរ

- ពង្រឹងអំណាចកណ្តាលតាមរយៈការសាងបុណ្យ ឬក សាងប្រាសាទរួមគ្នា ជាមួយពួកមន្ត្រីនៅខេត្តក្រៅ ដើម្បីឧទ្ទិសចំពោះអ្នកគុណរបស់ខ្លួនរៀងៗខ្លួន
- សិលាចារឹកជាច្រើនបានអះអាងអំពីគោលការណ៍របស់ព្រះរាជាក្នុងការប្រមូលដែនដីបែកបាក់ និងប្រទេសតូចៗមកនៅក្រោមអំណាចរបស់ព្រះអង្គ





៩ - ប្រាសាទព្រះខ័ន

# ៣.១. សង្គ្រាមប្រឆាំងចាម្ប ដោយឈ្លានពាន

- តាមសិលាចារឹកខ្មែរ និងកំណត់ឯកសារប្រវត្តិសាស្ត្រ ចិន ជំនាន់ដើម
- ប្រទេសខ្មែរតែងតែជួបប្រទះសង្គ្រាមតទល់ជាមួយចាម្ប ជាញឹកញាប់
- ពីព្រោះនៅអាស៊ីអាគ្នេយ៍ក្នុងសម័យនោះ កម្លាំង ឬជាតិសាសន៍ដែលអាចប្រឈមមុខគ្នាបាន មានតែខ្មែរ និងចាម្ប
- សង្គ្រាមនោះជា សង្គ្រាមវាតទឹកដី_វាតអំណាច_សងសឹកគ្នា_ឆក់ប្លន់ទ្រព្យមានតម្លៃ ដែលចុងក្រោយ នាំមកនូវផលអាក្រក់មហន្តរាយយ៉ាងធ្ងន់ធ្ងរបំផុតដល់ជោគវាសនាប្រទេសចាម្ប ចាប់ពីសតវត្សរ៍ទី១៣មក ចាម្បឈប់ឈ្លានពានកម្ពុជទេសរហូត
- ពាក់កណ្តាលទី២នៃសតវត្សទី៨ ចាម្បទំនងជាចាប់ផ្តើមវាតអំណាចរបស់ខ្លួនមកលើផ្នែកខាងកើតនៃទឹកដីរបស់ខ្មែរ

# ៣.១. សង្គ្រាមប្រឆាំងចាម្ប ដោយឈ្នះពាន

- ក្រោយពេលនោះ ព្រះបាទជយវម៌្មទី២ បានលើកទ័ពទៅវាយប្រហារចាម្ប នៅរវាងឆ្នាំ៧៩០ ហើយ មហាសេនាបតីជាបុត្រាទ្រង់នាមឥន្ទ្រាយុធ ចាប់បានទាំងស្តេចចាម្ប១អង្គ
- ក្រោមរជ្ជកាលព្រះបាទឥន្ទ្រវម៌្មទី១ ព្រះអង្គបានវាយរុញច្រានកំចាត់កងទ័ពចាម្ប រហូតចូលលុកដល់ដណ្តើមយករាជធានី កៅថារៈ និងប្រាសាទពោធិ៍នគរ ព្រមទាំងបានរឹបអូសយកមកខ្មែរវិញនូវជ័យភ័ណ្ឌ ដែលចាម្បធ្លាប់យកពីខ្មែរទៅ៕
- នៅរាជ្យព្រះបាទហស៌វម៌្មទី២ក៏មានចម្បាំងប្រឆាំងនឹងចាម្បដែរ ដោយព្រះអង្គជាអ្នកដឹកនាំ
- ហើយក្នុងរាជ្យរបស់ព្រះបាទហស៌វម៌្មទី៣ សិលាចារឹកចាម្ប១អះអាងថា ពួកគេបានវាយលុកកម្ពុជា និងដណ្តើមយកបានសម្ពុបុរៈ ប្រហែលឆ្នាំ១០៧៥៕

# ៣.១. សង្គ្រាមប្រឆាំងចាម្បដោយឈ្នះពាន

- រជ្ជកាលព្រះបាទ សូរ្យវម៌្មទី២ ចាម្បបានបញ្ជូនកងទ័ពមករាតត្បាតលុកលុយ និងកាន់កាប់ត្រួតត្រាដែនដីខ្មែរ នៅដីសណ្តទន្លេមេគង្គ៕ ក្រោយពីព្រះបាទសូរ្យវម៌្មទី២ ពង្រឹងអំណាច និងរៀបចំទឹកដីឱ្យមានឯកភាពរួចស្រេចហើយ ព្រះអង្គក៏ចាប់ផ្តើមបើកការវាយប្រហារដេញកំចាត់ទ័ពចាម្បចេញពីប្រទេសវិញ៕
- ១១២៣ ព្រះអង្គដេញកងទ័ពចាម្បរហូតដល់ស្រុកយួន ដោយយួនគាំទ្រចាម្បព្រះអង្គបានលើកទ័ពទៅច្បាំងនឹងយួនទៀត៕
- ១១៣១ ដោយយល់ឃើញថា យួនជាសត្រូវមួយដ៏ធំ ដែលអាចនាំមកផលអាក្រក់គ្រប់បែបយ៉ាងដល់កម្ពុជា ព្រះអង្គក៏សម្រេចចិត្តលើកទ័ពវាយយួនម្តងទៀតឱ្យចប់
- ១១៤៥ ដណ្តើមបានស្រុកចាម្បត្រួតត្រាអស់កាល៥ឆ្នាំ ត្រូវចាម្បបះបោរដណ្តើមអំណាចវិញ៕

# ៣.១. សង្គ្រាមប្រឆាំងចាម្បដោយឈ្លានពាន

- ក្នុងរាជ្យព្រះបាទធរណីន្ទ្រវម៌ទី២ ប្រហែលជាព្រះអង្គបន្តវាយយកប្រទេសចាម្បម្តងទៀត ទើបមានការបញ្ជូនអនាគតព្រះបាទជយវម៌្មទី៧ ទៅប្រទេសនេះ រហូតដល់រាជ្យស្តេចបន្ទាប់នាមយសោវម៌ទី២
- ដោយសារព្រះបាទយសោវម៌ទី២ ប្រឈមមុខនឹងបះបោរដ៏ធំរបស់មន្ត្រីម្នាក់ ទើបព្រះបាទជយវម៌ទី៧វិលត្រឡប់ពីប្រទេសចាម្បវិញ តែយឺតពេល ទើបព្រះអង្គគង់នៅកម្ពុជាយ៉ាងស្ងៀមស្ងាត់រហូតពេលមានចាម្បបានវាយលុក និងដណ្តើមកាន់កាប់ក្រុងអង្គរក្នុងឆ្នាំ១១៧៧
- ព្រះបាទ ជយវម៌ទី៧បានកទ័ពវាយកំចាត់ចាម្បចេញពីអង្គរ និងច្បាំងដើម្បីរួបរួមខ្មែរទាំងអស់
- តាមលោក វិកឃើរី ថា កងទ័ពព្រះអង្គពេលនោះ ចម្រុះខ្មែរ_ចាម្ប ដោយព្រះអង្គមានជំនួយពីកងទ័ពចាម្ប ដែលអាចជាទ័ពដែលព្រះអង្គនាំមកពីចាម្ប ឬជាសម្ព័ន្ធមិត្តរបស់ព្រះអង្គ ដូចដែលមានរូបចម្លាក់នៅប្រាសាទបាយ័ន និងបន្ទាយឆ្មារ ដែលបង្ហាញពីកងទ័ពចម្រុះខ្មែរ_ចាម្ប ប្រយុទ្ធប្រឆាំងនឹងកងទ័ពចម្រុះខ្មែរចាម្បដូចគ្នា៕

# ៣.២. សង្គ្រាមប្រឆាំងចាម្ប និងមូលហេតុ

- រាជ្យព្រះបាទសូរ្យវម៌ទី២ ជួនពេលនឹងឆ្នាំដំបូងនៃរាជ្យវង្សសុង ខាងត្បូង ដែលមានការពឹងផ្អែកលើទំនាក់ទំនងផ្លូវសមុទ្រ បានជំរុញឱ្យគេបើកផ្លូវពាណិជ្ជកម្ម ជាមួយរដ្ឋអាស៊ីអាគ្នេយ៍ច្រើនជាងរាជ្យវង្សស្តេចមុនៗបានធ្វើឡើង។
- អំឡុងពេលនោះចាម្បមានកំពង់ផែល្អៗជាច្រើន ដែលមានទំនាក់ទំនងជាមួយឈ្មួញចិន
- ព្រះបាទសូរ្យវម៌ទី២ បានចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើវិស័យពាណិជ្ជកម្ម និងការវាតទីលើវិស័យនេះ ក្រោយពីការកាត់ផ្តាច់អស់ប៉ុន្មានរាជ្យវង្សមក។ ព្រះអង្គបានចាប់ផ្តើមទំនាក់ទំនងពាណិជ្ជកម្មនេះឡើងវិញ ដោយបានបញ្ជូនទូតពីអង្គរឱ្យទៅកាន់ប្រទេសចិន នៅឆ្នាំ១១១៦ និង១១២០។ ទន្ទឹមនោះ ព្រះអង្គរៀបចំវាយយកប្រទេសចាម្បក្រោមលេសសងសឹក។
- ការវាតទីលើផ្លូវសមុទ្រនោះ ស្របទៅនឹងទំនាក់ទំនងរវាងនយោបាយពាណិជ្ជកម្មចិន និងការរីកចម្រើន, ការធ្លាក់ចុះខ្សោយ និងការប្រែប្រួលរដ្ឋនៅអាស៊ីអាគ្នេយ៍។

# ៣.៣. សង្គ្រាមប្រឆាំងយួន

- ព្រះបាទសូរ្យវរ្ម័ទី២ បានចាប់ផ្ដើមវាយយកប្រទេសយួននៅទសវត្សរ៍១១២០ ដោយស្នើឱ្យចាម្បនៅអព្យាក្រឹត្យ និងបន្ទាប់មកសុំឱ្យចាម្បជួយរួមដៃ តែមិនសម្រេច
- តាមសិលាចារឹកព្រះខ័នឆ្នាំ១១៩១ បានឱ្យដឹងថា ស្ដេចយួនបានចុះចូលជាមួយព្រះបាទជយវរ្ម័ទី៧។ ដោយគេបានថ្វាយទឹកមន្តដល់ព្រះអង្គនៅចំពោះមុខស្ដេចចាម្ប និងជ្វាផងដែរ។
- តែប៉ុន្មានឆ្នាំក្រោយមក ប្រវត្តិសាស្ត្រចិន និងវៀតណាមថា កម្ពុជាបានវាយលុកទៅលើវៀតណាមក្នុងខេត្តង៉េអាន គឺនៅឆ្នាំ១២១៦,១២១៨ និងក្នុងឆ្នាំ១២២០។ នេះប្រហែលមកពីស្ដេចយួន បានដកខ្លួនឈប់នៅចំណុះខ្មែរ ទើបធ្វើឱ្យជយវរម័ទី៧បញ្ជាឱ្យវាយប្រហារ។

# ៣.៣. សង្គ្រាមប្រឆាំងយួន

- ទោះបីជាយ៉ាងណា ការឈ្លានពាននោះត្រូវបរាជ័យ៕ ព្រោះវៀតណាមមានភូមិសាស្ត្រស្មុគស្មាញ និងស្ថិតនៅក្នុងតំបន់ត្រជាក់បង្គួរ_ជាឧបសគ្គសម្រាប់កងទ័ពខ្មែរ៕
- ក្រោយឆ្នាំ១២២០ កម្ពុជាបានដកខ្លួនពីចម្ប៉ា(វិជ័យ) ហើយព្រះអង្គម្ចាស់ចាម្ប ដែលចម្រើនវ័យនៅកម្ពុជា ក្នុងរាជ្យព្រះបាទ ជយវរ្ម័ទី៧ បានឡើងជាស្ដេចនៅវិជ័យ មាននាម ជយបរមេស្វរវរ្ម័ទេព៕
- តាមរបាយការណ៍ចិននៅរវាងឆ្នាំ១២២០ ព្រំប្រទល់កម្ពុជារួមមានលវោ (តំបន់បាងកក,អយុធ្យា, សុផានបុរី) ចិនលីហ្វូ(ជិតចន្ទបុរីតាមឆ្នេរអាគ្នេយ៍ប្រទេសថៃ ទៅរហូតដល់បុខាន់«ប៉ាហ្កាន_ភូមា»)

# ៣.៤. សង្គ្រាមបែងចែក និងបង្រួបបង្រួម

សង្គ្រាមដណ្តើមរាជ្យគ្នានៅក្នុងស្រុក

•ហស៍វម្ម័ទី១ និងឥសានវម្ម័ទី២នៅអង្គរ និងជយវម្ម័ទី៤នៅកោះកេរ្តិ៍ (៩២១_៩២៨គ ស )

•ព្រះបាទជយវីរវម្ម័នៅអង្គរ និងសូរ្យវម្ម័ទី១នៅកំពង់ធំ_ក្រចេះ (១០០២_១០១០គ ស )

•ព្រះបាទហស៍វម្ម័ទី៣+ន្ទ្រុបតីន្ទ្រវម្ម័នៅអង្គរ និងជយវម្ម័ទី៦នៅមហីធរបុរ (១០៧៦_១១០៦គ.ស)

•ព្រះបាទជយវម្ម័ទី៨នៅអង្គរ និងស្តេចត្រាញ់ខ្មែរលវោទ័យ_អយុធ្យា ដែលខ្មែរហៅថា សៀម ពីទសវត្សរ៍១២៨០៕ ការបែកបាក់គ្នាចុងក្រោយនេះ មិនអាចរួបរួមគ្នាវិញបានទាំងស្រុង រហូតដល់ឆ្នាំ ១៥៦៩ ទើបរាជវង្សខ្មែរនៅអយុធ្យាត្រូវផុតពូជ ដោយសារការបំផ្លាញរបស់ស្តេចភូមាហង្សាវតី ហើយរាជវង្សថៃមកពីសុខោទ័យ ត្រូវដាក់បន្តុបឡើងរហូតមក៕

# ៣.៤. សង្គ្រាមបែងចែក និងបង្រួបបង្រួម

- ន្ទ្រុបតីន្ទ្រវម្ម័ ជាបុត្រាជយវម្ម័ទី៧ និងព្រះអគ្គមហេសី ជយរាជទេវី ត្រូវបានបញ្ជូនឱ្យទៅគ្រប់គ្រងអាណាចក្រនៅខាងជើងហៅថា លវោទ័យ គឺនៅតំបន់ល្វោ ដែលមេទ័ពធំនៅទីនោះ គួរតែមានឋានន្តរនាមជាជយសិង្ហវម្ម័ ដូចបង្ហាញលើជញ្ជាំងថែវប្រាសាទអង្គរវត្តជ្រុងខាងត្បូងភាគខាងលិច។
- អ្នកគ្រប់គ្រងតំបន់នេះនៅសតវត្សរ៍ទី១៣ និង១៤ ត្រូវតែជាខ្សែស្រឡាយរបស់ព្រះអង្គ និងជយវម្ម័ទី៧ ដែលខុសគ្នាពីព្រះបាទជយវម្ម័ទី៨នៅអង្គរ ដែលដណ្តើមរាជ្យពីបុត្រាព្រះបាទជយវម្ម័ទី៧
- មុនសតវត្សទី១០ តំបន់កណ្តាលភាគឦសាន និងភាគខាងត្បូងទឹកដីថៃតំបន់ទាំងនោះតាំងលំនៅដោយជនជាតិខ្មែរ និងមន និងពួកនិយាយភាសាមន—ខ្មែរផ្សេងទៀត ស្ថានការណ៍នៅខាងជើងទឹកដីថៃពុំមានលក្ខណៈច្បាស់លាស់ទេ៕ ប៉ុន្តែមានជនជាតិមននៅទីនោះដែរ ដោយមានទីក្រុងនិងស្តេចរហូតដល់សតវត្សទី១៣ ហើយក៏មានការតាំងលំនៅរបស់ជនជាតិមនខ្មែរផ្សេងទៀតដែរ ៕

# ៣.៤. សង្គ្រាមបែងចែក និងបង្រួបបង្រួម

- តាមរយៈកំណត់ហេតុចាស់ៗដែលនៅសេសសល់ឱ្យដឹងថា តំបន់នៅនគរស្រីធម្មរ៉ាត(ធម្មរាជ),សុរាតថានី, ប៉ាថាលុង គឺជាកន្លែងដែលប្រជាជនខ្មែរតាំងលំនៅរហូតដល់សតវត្សទី១៧មុនស វទី១៥សិលាចារឹកទាំងអស់នៅថៃ_កណ្តាល ភាគខាងត្បូង(អាយុធ្យា—បាងកក)ចារឹកជាភាសាមន ឬខ្មែរ៕ ប៉ុន្តែដែពុំមានច្រើនទេ ឯនៅភាគឦសានមានសិលាចារឹកទាំងភាសាមន និងខ្មែរ៕
- ចិនស្គាល់អយុធ្យាថា ជាសៀន ដែលលោកវិកឃើរី (១៩៩៩)ចាត់ទុកពួកនោះថា ជាខ្មែរមួយក្រុមទៀត ដែលមានប្រពៃណី ទំនៀមទម្លាប់ដូចខ្មែរដែរ៕
- រដ្ឋថៃពិតប្រាកដ ទំនងជាប្រកាសឯករាជ្យនៅចុងសតវត្សរ៍ទី១៣ ដែលមានរាជធានីនៅសុខោទ័យ

# ៤. ការប្រជែងគ្នាខាងសាសនានិងការផ្លាស់ប្តូរ

* សាសនា គឺជាមនោគមវិជ្ជានយោបាយរបស់ព្រះរាជា សម្រាប់ប្រមូលកម្លាំងគាំទ្រព្រះអង្គ

* ការផ្លាស់ប្តូរសាសនា គឺជាការផ្លាស់ប្តូរស្នៀតក្នុងការប្រមូលកម្លាំងគាំទ្រ

* ការផ្លាស់ប្តូរសាសនា អាចនាំឱ្យមានវិនាសកម្មលើជីវិតមនុស្ស និងស្នាដៃដែលមានស្រាប់

* ជាឧទាហរណ៍ ៖ ក្រោយការសោយទិវង្គតរបស់ព្រះបាទជយវម៌ទី៧ នគរខ្មែររងនូវវិនាសកម្មបំផ្លាញប្រាសាទដែលឧទ្ទិសថ្វាយពុទ្ធសាសនា

# ៤. ការប្រជែងគ្នាខាងសាសនានិងការផ្លាស់ប្តូរ

- ការវិភាគផ្នែកស្ថាបត្យកម្មបានឱ្យដឹងថា បណ្តាលពីមូលហេតុពីរ
- ការផ្លាស់ប្តូរសាសនារបស់ជ័យវរ្ម័ទី៨
- ការផ្លាស់ប្តូរពីពុទ្ធនិយមទៅព្រាហ្មណ៍និយម(ប្តូរព្រះពុទ្ធរូប ទៅជាសិវលិង្គ លើកលែងតែចម្លាក់ព្រះពោធិសត្វអវលោកេស្វរៈចេញ ដែលមានភាពស្រដៀងនឹងលទ្ធិព្រហ្មញ្ញសាសនា៕ មានប្រាសាទមួយចំនួនបានរួចពីការបំផ្លាញនោះ ដូចជាប្រាសាទព្រះខ័នកំពង់ស្វាយ ឬបាកាណ,តាព្រហ្ម_បាទីជាដើម
- ព្រះពុទ្ធអង្គតាមប្រាសាទទនានាត្រូវគេដាប់ចោល ឬឈូសចោលតែម្តង
- តាមការសង្កេតលើលក្ខណៈនៃការខូចខាតរបស់ប្រាសាទ ពិសេសចម្លាក់ប្រាសាទនាគព័ន្ធនិងប្រាសាទដទៃទៀត បានបង្ហាញឱ្យឃើញថា ប្រទេសកម្ពុជាបានទទួលនូវការផ្លាស់ប្តូរសាសនាក្នុងរយៈពេលដ៏ខ្លីនាសតវត្សទី១៣

# ៤. ការប្រជែងគ្នាខាងសាសនានិងការផ្លាស់ប្តូរ

- ទង្វើនេះពុំបានទទួលនៅជោគជ័យជាស្ថាពរឡើយ៕ ព្រហ្មញ្ញសាសនានៅសម័យក្រោយអង្គរ ឈប់ក្លាយជាសាសនារបស់រដ្ឋដូចសម័យមុនៗទៀត ៕
- ព្រះបាទស្រីន្ទ្រវរ្ម័បានប្តូរសាសនាផ្លូវការម្តងទៀតទៅពុទ្ធសាសនាថេរវាទ ដូចឃើញក្នុងសិលាចារឹក K.754 ឆ្នាំ១២៣១សកៈ ឬ១៣០៩គ ស
- ការផ្លាស់ប្តូរសាសនា នាំឱ្យគេលែងឃើញមានសំណង់ប្រាសាទធំៗ ដែលជាសន្ទស្សន៍នៃភស្តុតាងចម្រើនរុងរឿងរបស់ខ្មែរមួយផ្នែកដែរ ទើបគេមិនអាចស្ទង់បានពីសមត្ថភាព ឬសក្តានុពលចំណេះវិជ្ជា, សេដ្ឋកិច្ច និងនយោបាយរបស់ខ្មែរនៅពេលនោះ

# ៥. ការវាយលុករបស់សៀម

- ស្យាំ/ស្យាម/សៀម/ហៀ្សន/សៀន គឺជាឈ្មោះតំបន់ខាងជើងភ្នំដងរ៉ែក មិនមែនជាជាតិពន្ធុនាមទេ បើតាមលោក បេណិឌិក អានឌ័រសុន និងលោក រិកយើរី (២០០៤)
- ប្រភពចិនថា ប្រទេសអយុធ្យា ជារបស់ពួកសៀន ឬ សៀម ដែលខុសគ្នាពី សុកុតៃ នៅភាគខាងជើង
- តាមលោក រិកយើរី បានពន្យល់ដោយផ្អែកលើភស្តុតាងសំណេរថា អយុធ្យា ឬ សៀម តាំងពីសតវត្សរ៍ទី១៣ ដល់ឆ្នាំ១៥៦៩ មានមេដឹកនាំជាខ្មែរ ដែលបែកចេញពីរាជវង្សស្តេចសោយរាជ្យនៅតំបន់អង្គរ ។ ចំណែកកំណត់ត្រារបស់ពួកបរទេសដូចជា San Antonio (1603), Bradly (1792), Bowring (1855) ក៏បានឱ្យដឹងថា ស្តេចបង្កើតអយុធ្យា ជាសមាជិករាជវង្សស្តេចទៅពីរាជធានីអង្គរ។
- ប៉ុន្តែលោក Simon (1685), កត់ត្រាថា ព្រះបាទនារាយណ៍(សុគត១៦៨៨)ប្រាប់គាត់ថា ព្រះអង្គជាពូជពង្សក្សត្រខ្មែរដែលទៅពីអង្គរ ហើយព្រះអង្គម្ចាស់មន្ត្រីថ្នាក់ទី១ទី២ភាគច្រើនគឺជាខ្មែរ ។

# ៥. ការវាយលុករបស់សៀម

- ដំបូងបំផុត ជីវតាខ្វាន់ ថា ទីក្រុងអង្គរទើបតែទទួលការវាយប្រហារពីពួកសៀន (ឆ្នាំ១២៩៥)ដែលនៅទិសខាងលិច ទំនងជានៅមុនឆ្នាំ១២៩៦ ប្រហែលមួយ ឬពីរឆ្នាំប៉ុណ្ណោះ៕ ចំណែក
- សង្គ្រាមដែលសៀមវាយអង្គរនៅសតវត្សរ៍ទី១៤_១៥ សុទ្ធសឹងមានកាលបរិច្ឆេទខុសៗគ្នា ដោយខ្លះថា វាយនៅពាក់កណ្តាលស វ ១៤ម្តង ចុងស វ នេះម្តងទៀត តែខ្លះថានៅរវាងទសវត្សរ៍១៤២០ឬ៣០ទៅវិញ ដែលការនេះនាំដល់ភាពកាន់តែលែងច្បាស់លាស់អំពីកាលបរិច្ឆេទពិតនៃការមកតាំងទីក្រុងនៅចុតមុខរបស់ព្រះបាទពញាយ៉ាត៕
- ការរាតទីរបស់ប្រទេសសៀមដែលទើបបានបង្កើតឡើង នៅលើអាណាខេត្តនានារបស់អតីតទឹកដីព្រះរាជាណាចក្រកម្ពុជា

# ៥. ការវាយលុករបស់សៀម

- បើពិនិត្យផ្ទៀងផ្ទាត់ជាមួយប្រភពពង្សាវតារឡាវ ចម្បាំងដណ្ដើមយកអង្គររបស់អយុធ្យានៅឆ្នាំ១៣៥១(ក្នុងរាជ្យស្រីលំពង់រាជា) មិនអាចឱ្យជឿបានទេ៕ ពីព្រោះ
- អំឡុងឆ្នាំ១៣៥១_៥៣ ស្ដេចសៀមកំពុងជាប់ដែកសាងរាជធានីអយុធ្យា
- អំឡុងពេលដដែលនោះ ប្រហែលព្រះបាទជយវម្ម័ទេពទី៩ កំពុងគាំទ្រសង្គ្រាមបង្រួបបង្រួមប្រទេសឡាវ ដែលដំណើរការដោយហ្វាងុម ដែលជាកូនធម៌ និងជាកូនប្រសារបស់ព្រះអង្គ៕ ដោយការប្រើប្រាស់កងទ័ពខ្មែរ ហ្វាងុមសម្រេចការស្ថាបនារដ្ឋឡាវរួបរួម និងឥស្សរភាពនៅឆ្នាំ១៣៥៣៕ អាណាចក្ររបស់គាត់រួមបញ្ចូលទាំងរាជាណាចក្រសុខោទ័យរបស់ថៃ និងឆៀងម៉ៃផងដែរ៕ មកដល់ឆ្នាំ១៣៥៨ ពង្សាវតារឡាវនៅតែបង្ហាញពីការទាក់ទងគ្នារវាងព្រះថៅហ្វាងុម និងបិតាធម៌អង្គនេះដដែល។
- នាំឱ្យយើងយល់ថា គ្មានរឿងតាត្រសក់ផ្អែមសម្លាប់ព្រះបាទជយវម្ម័ទេពទី៩និងឡើងសោយរាជ្យនៅអង្គរទេ

# ៥. ការវាយលុករបស់សៀម

- បន្ទាប់មក គាត់ និងមហេសីបានស្នើសុំបិតានៅអង្គរឱ្យបញ្ជូនព្រះសង្ឃទៅផ្សាយពុទ្ធសាសនាថេរវាទនៅប្រទេសលានជាង_ឡានសាង៕ ស្ដេចខ្មែរក៏បញ្ជូនតាមសំណូម ជាមួយព្រះត្រៃបិដក និងព្រះពុទ្ធរូបមាស ហៅ ព្រះបង ឬព្រះបាង៕
- តាមឯកសារចិន ចាប់ពីឆ្នាំ១៣៧១រាជធានីកម្ពុជានៅប៉ាសានស្រីសន្ធរ គឺប្រហែលបន្ទាប់ពីតំបន់អង្គររងគ្រោះរាំងស្ងួតអស់ប្រមាណ១០ឆ្នាំមក(១៣៦០_៩០) និង(១៤០០_២០/១៤១៥-១៤៣៥)៕ ដូច្នេះការប្ដូររាជធានីមិនទាក់ទងនឹងការវាយប្រហាររបស់សៀមទេ៕
- លោក អូលីវើរ វ៉ូលធ័រ បានស្នើថា នៅរវាងឆ្នាំ១៣៨៩ ប្រហែលអយុធ្យាបានលើកទ័ពមកវាយយកអង្គរ នៅពេលខ្មែរតាំងរាជធានីបណ្ដោះអាសន្ននៅបាសាន និងមានសេដ្ឋកិច្ចទន់ខ្សោយ

# ៥. ការវាយលុករបស់សៀម

- បន្ទាប់ពីបណ្តេញទ័ពសៀមចេញពីតំបន់នេះរួច និងផុតគ្រោះរាំងស្ងួតនៅអង្គរលើកទី១ផង ព្រះរាជាខ្មែរប្រហែលជាបន្តគង់នៅតំបន់អង្គរឡើងវិញ
- អញ្ចឹងហើយទើបនៅឆ្នាំ១៤០៥ ទូតចិនថា រាជធានីខ្មែរស្ថិតនៅទីក្រុងអង្គរធំវិញ
- ប៉ុន្មានឆ្នាំក្រោយមក ទុរ្ភិក្សបានគ្របដណ្តប់លើតំបន់អង្គរម្តងទៀត ដោយសារគ្រោះរាំងស្ងួតប្រមាណ២០ឆ្នាំ បានចាប់ផ្តើមប្រហែលឆ្នាំ១៤០០-១៤២០ ឬឆ្នាំ១៤១៥-១៤៣៥៕
- ប្រហែលឆ្លៀតឱកាសសេដ្ឋកិច្ចធ្លាក់ចុះជាថ្មីទៀតនៅពេលនោះ ទើបអយុធ្យាហ៊ានវាយប្រហារអង្គរម្តងទៀត (ប្រហែលឆ្នាំ១៤១៩)ដែលកាលបរិច្ឆេទជាក់ស្តែងមិនអាចកំណត់បានច្បាស់៕ ពីព្រោះការសិក្សាប្រវត្តិសាស្ត្រចំណុចនេះ ជួបប្រទះការខ្វះខាតសំណៅឯកសារដើមសហសម័យ ដែលបន្សល់ទុកពីសម័យដើមយូរអង្វែងនោះ៕

# ៥. ការវាយលុករបស់សៀម

- ការវាយប្រហារកាន់កាប់អង្គរលើកនេះហើយ ដែលនាំឱ្យលេចចេញព្រះបាទពញាយ៉ាតរំដោះទីក្រុង ហើយក្រោយមកទ្រង់បានប្តូររាជធានីចេញពីអង្គរនៅឆ្នាំ១៤៣១៕
- រឿងនេះអាចជាការពិត ដែលវិវត្តន៍ចេញពីរឿងចាស់ពិតមួយដែលអយុធ្យាដណ្តើមកាន់កាប់អង្គរក្នុងឆ្នាំ១៤៣១ និងកាន់កាប់អស់រយៈពេល១៥ឆ្នាំ រហូតដល់ឆ្នាំ១៤៤៥(តាមពង្សាវតារអយុធ្យា)៕
- ហេតុអ្វីបានជាពង្សាវតារដែលកាលបរិច្ឆេទ និងរឿងរ៉ាវមិនពិតទាំងនោះកើតមានឡើង?
- នោះអាចមកពីគេទើបតែតាក់តែងរឿងនេះឡើងវិញ តាមការចងចាំខ្លះ នៅសតវត្សរ៍ទី១៩៕ ម្យ៉ាងទៀត ដោយសារពេលនោះ ខ្មែរនៅក្រោមអំណាច និងឥទ្ធិពលរបស់សៀម ម្ល៉ោះហើយ ទើបមិនហ៊ាននិយាយការពិតជាក់ស្តែងនៃប្រវត្តិសាស្ត្រ និងអាចមកពីខ្វះសំណៅឯកសារដើម ដែលបន្សល់ទុកពីសម័យដើមយូរអង្វែងនោះ៕

# សេចក្ដីសន្និដ្ឋាន

- ចំណុចជាច្រើនចុងក្រោយនេះ មិនមែនជាបុព្វហេតុ នាំឱ្យអារ្យធម៌អង្គរធ្លាក់ចុះនោះទេ!!!
- លោក សឺដេស ហាក់ដូចជាទម្លាក់កំហុសនៃភាពចុះខ្សោយរបស់ខ្មែរសម័យអង្គរដោយសារការមិនសំចៃកម្លាំងកាយ ចិត្ត ស្មារតី និងទ្រព្យសម្បត្តិប្រជារាស្ត្ររបស់ព្រះបាទជយវម៌ទី៧ (ផ្ទុះតាមបរិមាណប្រាសាទ និងតង្វាយចំពោះព្រះទាំងនោះ)
- ហេតុផលថា មកពីសង្គ្រាមញឹកញាប់សម្លាប់មនុស្សនៅតំបន់នោះច្រើនពេក, ការគម្រាមកំហែងដោយរដ្ឋថ្មីនៅអយុធ្យាដែលតាំងខ្លួនទាយាទនៃចក្រភពអង្គរដែរនោះ គឺជាមូលហេតុមិនគួរឱ្យជឿបាន



សេចក្ដីសន្និដ្ឋាន

- ការធ្លាក់ចុះរបស់អង្គរ ដោយសារធម្មជាតិលែងអំណោយផលដល់កសិកម្មប្រពលវប្បកម្ម(ព្រោះបាយសម្រាប់មនុស្សនៅអង្គរត្រូវពឹងលើនយោបាយទឹក)
- ការរីកចម្រើនសកម្មភាពសេដ្ឋកិច្ចតាមដងទន្លេមេគង្គ នាំឱ្យព្រះរាជាចាប់អារម្មណ៍ឡើងវិញអំពីតួនាទីជំនួញតាមដងទន្លេ សម្រាប់ទ្រទ្រង់សេដ្ឋកិច្ចប្រទេសរួមផ្សំជាមួយកសិកម្មដែលជាខឿនសេដ្ឋកិច្ចប្រពៃណី ទើបនាំឱ្យកើតបាតុភូតចាកចោលរាជធានីអង្គរ
- ការប្រើពាក្យ «ការដួលរលំនៃអារ្យធម៌អង្គរ» ព្រោះអង្គរលែងនៅជារាជធានីធំដ៏អស្ចារ្យមានទាំងអំណាចសេដ្ឋកិច្ច, នយោបាយ និងយោធាតទៅទៀត ចាប់ពីពេលព្រះបាទពញាយ៉ាតរំដោះទីក្រុងនេះបានពីការកាន់កាប់របស់អយុធ្យា ៕

# ការដួលរលំនៃអាណាចក្រអង្គរ???

- តាមពង្សាវតារ បានពន្យល់ពីការចាកចោលទីកន្លែងនេះ ថាមកពីបញ្ហាមួយចំនួនដូចជា ៖
- ?_ស្ថិតនៅជិតរាជធានីអយុធ្យាពេក_ប្រមាណ៤០០គ ម ពីគ្នា ទើបងាយទទួលរងការគំរាមខាងសន្តិសុខ
- ?_ខូចខាតហេដ្ឋារចនាសម្ព័ន្ធទីក្រុងមានមានចម្បាំង មនុស្សច្រើនពេកលើសចំណុះត្រូវបង្ខំឱ្យរស់នៅក្នុងបរិវេណតូចនេះ
- ?_ប្រជារាស្ត្រស្លាប់អស់ច្រើននៅពេលសង្គ្រាម ទីក្រុងមិនសូវមានមនុស្សកុះករដូចមុន

# ការដួលរលំនៃអាណាចក្រអង្គរ

- អាកាសធាតុរាំងស្ងួត—ខូចហេដ្ឋារចនាសម្ព័ន្ធកសិកម្ម (មនុស្សមិនសូវចាប់អារម្មណ៍ចូលទៅរស់នៅទីនោះទៀត ព្រោះដូចតែកន្លែងដទៃទៀតដែរ) គ្រោះរាំងស្ងួតពីរលើក
- _លើកទី១៖ ១៣៦០_១៣៨០
- _លើកទី២៖ ១៤០០_១៤២០ ឬ១៤១៥_១៤៣៥
- អង្គរលែងនៅជាតំបន់ឆ្លងកាត់នៃពាណិជ្ជកម្មអន្តរជាតិ ព្រោះចិនបើកផ្លូវជំនួញផ្ទាល់មុខជាមួយម៉ាឡាក្កា ចាប់ពីឆ្នាំ១៤០៣_៤
- សក្តានុពលសេដ្ឋកិច្ចថ្មី—ពាណិជ្ជកម្មតាមដងទន្លេមេគង្គ និង
- ពញាយ៉ាតគួរតែជាមន្ត្រីថ្នាក់មធ្យម នៅភាគខាងត្បូងគ្រប់គ្រងដែនដីនៅជាប់តាមមាត់ទន្លេស្រាប់ មិនមានទម្លាប់នៅតំបន់អង្គរ និងស្គាល់ច្បាស់អំពីស្ថានភាពសេដ្ឋកិច្ចនៅតំបន់នេះ

# ប្រវត្តិសាស្ត្រកម្ពុជាសម័យក្រោយអង្គរ

# មេរៀនទី៣, ៤, ៥

**ដោយ វង់ សុធារ៉ា**

**ដេប៉ាតឺម៉ង់ប្រវត្តិវិទ្យា**

**សាកលវិទ្យាល័យភូមិន្ទភ្នំពេញ**

# មេរៀនទី៣ ៖ សម័យចតុមុខ ១៤៣៤-១៥២៥

## សេចក្តីសន្និដ្ឋាន

- ការធ្លាក់ចុះរបស់អង្គរ ដោយសារធម្មជាតិលែងអំណោយផលដល់កសិកម្មប្រពលវប្បកម្ម(ព្រោះបាយសម្រាប់មនុស្សនៅអង្គរត្រូវពឹងលើនយោបាយទឹក) មហន្តរាយសង្គ្រាម និងគ្រោះរាំងស្ងួត មានការសិក្សាស្រទាប់ឈើពាន់ឆ្នាំបញ្ជាក់អំពីគ្រោះរាំងស្ងួតរយៈពេលយូរចំនួនពីរលើក ទី១ អស់ពេល៣០ឆ្នាំពី១៣៦៩ដល់១៣៩០ និងទី២ អស់ពេល២០ឆ្នាំ ពី១៤១៥ដល់១៤៣៥
- ការរីកចម្រើនសកម្មភាពសេដ្ឋកិច្ចតាមដងទន្លេមេគង្គ នាំឱ្យព្រះរាជាចាប់អារម្មណ៍ឡើងវិញ អំពីតួនាទីជំនួញតាមដងទន្លេ សម្រាប់ទ្រទ្រង់សេដ្ឋកិច្ចប្រទេសរួមផ្សំជាមួយកសិកម្មដែលជាខឿនសេដ្ឋកិច្ចប្រពៃណី ទើបនាំឱ្យកើតបាតុភូតចាកចោលរាជធានីអង្គរ
- វាជាបាតុភូតនៃការប្រែប្រួលដោយធម្មជាតិ និងការបង្កើតឡើងរបស់មនុស្ស ជាពិសេស ចរន្តប្រែប្រួលនៃដំណើរពាណិជ្ជកម្មក្នុងតំបន់ទាំងមូល

# ទស្សនៈអ្នកប្រាជ្ញធំអំពីសម័យអង្គរនិងចតុមុខ

- លោក Michael Vickery លោក Claude Jacques និង លោក Oliver Wolters បានគូសបញ្ជាក់ថា ការផ្លាស់ប្តូរនេះមិនគប្បីគេបកស្រាយថា ជាសញ្ញាណនៃ«ការធ្លាក់ចុះដុនដាប»ទេ៕
- ពីព្រោះលោក អូលីវ័រ វ៉ូលធ័រ បានកត់សម្គាល់ថា «ក្នុងការចាត់ទុកការដុនដាបនៃអង្គរនាសតវត្សរ៍ទី១៤ និង១៥ថា ជាគ្រោះមហន្តរាយដ៏មហិមានោះ ជាការប្រញាប់សន្និតលឿនពេកហើយ» ព្រោះថា វាមកពីការប្រែប្រួលខាងសក្តានុពលសេដ្ឋកិច្ចទៅវិញទេ៕
- ការប្រើពាក្យ «ការដួលរលំនៃអារ្យធម៌អង្គរ» ព្រោះអង្គរលែងនៅជារាជធានីធំដ៏អស្ចារ្យ មានទាំងអំណាចសេដ្ឋកិច្ច, នយោបាយ និងយោធាតទៅទៀត ចាប់ពីពេលព្រះបាទពញាយ៉ាតរំដោះទីក្រុងនេះបានពីការកាន់កាប់របស់អយុធ្យា។

# ការដួលរលំនៃអាណាចក្រអង្គរ???

តាមពង្សាវតារ បានពន្យល់ពីការចាកចោលទីកន្លែងនេះ ថាមកពីបញ្ហាមួយចំនួនដូចជា៖

•?_ស្ថិតនៅជិតរាជធានីអយុធ្យាពេក_ប្រមាណ៤០០គម ពីគ្នា ទើបងាយទទួលរងការគំរាមខាងសន្តិសុខ និងនយោបាយ (អយុធ្យាវាយអង្គរ២លើក ឆ្នាំ១៣៨៩ និង១៤៣១)

•?_ខូចខាតហេដ្ឋារចនាសម្ព័ន្ធទីក្រុង ពេលមានចម្បាំងច្រើនលើក

•?មនុស្សជាច្រើនត្រូវបង្ខំឱ្យរស់នៅក្នុងបរិវេណតូចក្នុងកំផែងរាជវាំងនេះ មនុស្សលើសចំណុះ នាំឱ្យខូចបរិស្ថានក្នុងរាជវាំង

•?_ប្រជារាស្ត្រស្លាប់អស់ច្រើននៅពេលសង្គ្រាម ទីក្រុងមិនសូវមានមនុស្សកុះករដូចមុន

•?-លោក ទុស័យ ធ្លាប់ស្មានថា តំបន់អង្គរនៅក្នុងសតវត្សរ៍ទី១៤ និង១៥ ប្រហែលបានជួបគ្រោះរាំងស្ងួត បើតាមការសង្កេតលើស្លាកស្នាមសណ្ឋានដីនៅទីនោះ (១៣៧១-៨៩ស្តេចខ្មែរនៅប៉ាសាន)

# ការដួលរលំនៃអាណាចក្រអង្គរ???

- អាកាសធាតុរាំងស្ងួត—ខូចហេដ្ឋារចនាសម្ព័ន្ធកសិកម្ម(មនុស្សមិនសូវចាប់អារម្មណ៍ចូលទៅរស់នៅទីនោះទៀតព្រោះដូចតែកន្លែងដទៃទៀតដែរ)។ តាមការសិក្សារង្វង់ស្រទាប់ឈើ ពីឆ្នាំ២០០៧-៩ អង្គរ គួរតែជួបគ្រោះរាំងស្ងួតរយៈពេលយូរ ពីរលើក៖
- លើកទី១៖ ១៣៦០_១៣៩០ និងលើកទី២៖ ១៤០០_១៤២០ឬ១៤១៥_១៤៣៥
- អង្គរលែងនៅជាតំបន់ឆ្លងកាត់នៃពាណិជ្ជកម្មអន្តរជាតិព្រោះចិនបើកផ្លូវជំនួញផ្ទាល់មុខជាមួយម៉ាឡាកាចាប់ពីឆ្នាំ១៤០៣_៤
- សក្តានុពលសេដ្ឋកិច្ចថ្មី—ពាណិជ្ជកម្មតាមដងទន្លេមេគង្គនិង
- ពញាយ៉ាតគួរតែជាមន្ត្រីថ្នាក់មធ្យមនៅភាគខាងត្បូងគ្រប់គ្រងដែនដីនៅជាប់តាមមាត់ទន្លេស្រាប់មិនមានទម្លាប់នៅតំបន់អង្គរនិងស្គាល់ច្បាស់អំពីស្ថានភាពសេដ្ឋកិច្ចនៅតំបន់នេះ

# បុច្ឆនសិក្សា

- ១- តើទីក្រុងនៅទួលបាសាន មានស្ថានភាពដូចម្ដេច សម្រាប់ភូមិសាស្ត្រ, សេដ្ឋកិច្ច និងនយោបាយនៅពេលនោះ?
- ២- តើមូលហេតុដូចម្ដេច ទើបព្រះបាទពញាយ៉ាត មកតាំងរាជធានីនៅចតុមុខ?
- ៣- តើនិរន្តរភាពវប្បធម៌អង្គរ នៅសម័យចតុមុខស្ដែងចេញជាភស្តុតាងដូចម្ដេចខ្លះ?
- ៤- តើការវាយប្រហារអយុធ្យាដោយព្រះបាទស្រីរាជាក្រោមហេតុផលដូចម្ដេចខ្លះ?
- ៥- តើជម្លោះផ្ទៃក្នុងនៅទសវត្សរ៍១៤៧០ដល់១៤៨០នៅចតុមុខ ដោយសារហេតុផលដូចម្ដេចខ្លះ?
- ៦- ហេតុដូចម្ដេចទើបមានអន្តរាគមន៍របស់សៀមបញ្ចប់ជម្លោះនោះនៅទសវត្សរ៍ឆ្នាំ១៤៨០?
- ៧- តើជម្លោះផ្ទៃក្នុងរវាងព្រះបាទស្រីសុគន្ធបទ និងស្ដេចកន មានបុព្វហេតុ និងលទ្ធផលដូចម្ដេច?
- ៨- តើគេប្រើយុទ្ធសាស្ត្រដូចម្ដេចខ្លះ ក្នុងការដណ្ដើមអំណាចគ្នារវាងព្រះចន្ទរាជា និងហ្លួងព្រះស្ដេចកន? ហើយមានលទ្ធផលដូចម្ដេច?

១.តើទួលបាសានជាទីតាំងដូចម្ដេចបានជាព្រះបាទពញាយ៉ាតជ្រើសយកទីនោះ មុនទៅតាំងនៅចតុមុខ?

- ជាអតីតរាជធានីជម្រើសមួយតាំងពីភាគទី២នៃសតវត្សរ៍ទី១៤(១៣៧១-១៣៨៩គ.ស.) បើតាមកំណត់ត្រារបស់ទូតចិន សិក្សាដោយលោក អូលីវ័រ វ៉លធ័រ។
- ពញាយ៉ាតជាពូជពង្សស្ដេចខ្មែរមកពីខាងអយុធ្យា។ បិតារបស់ព្រះអង្គជាញាតិវង្សយ៉ាងជិតជាមួយស្ដេចអយុធ្យា និងត្រូវបានតាំងជាស្ដេចត្រាញ់នៅចតុមុខ ពេលឥន្ទ្ររាជាជាបុត្រាស្ដេចសៀមសោយរាជ្យនៅអង្គរ១៥ឆ្នាំ(១៤៣១-១៤៤៥គ.ស.) បើតាមលោកវិកឃើរី(២០០១)
- ដោយសារពញាយ៉ាតបះបោរផ្ដួលរំលំឥន្ទ្ររាជាដោយជោគជ័យ ទើបបារម្ភស្ដេចអយុធ្យាលើកទ័ពធំមកសងសឹក និងដកថយចេញពីអង្គរ
- នៅទួលបាសាន ជាទីតាំងមានភូមិសាស្ត្រល្អ ជាយុទ្ធសាស្ត្រងាយស្រួលការពារ មានបឹង និងដងទន្លេព័ទ្ធជុំវិញ។ កញ្ញាម៉ាដឺឡែនហ្សិត្តូ ទួលបាសានប្រៀបដូចជាកោះធំមួយ។

# Angkor => Mahānagaraindrapraṣṭa

# មហានគរឥន្ទ្រប្រស្ត





# ទីតាំងទួលបាសាននៅប្រាសាទព្រះធាតុបារាយណ៍ស្រីសន្ធរ ដែលគេបានយល់ច្រឡំថា អតីតរាជធានី









# ការតាំងរាជធានីនៅស្រីសន្ធរ(ច្រើនលើក)

- រាជធានីឈ្មោះ ស្រីសន្ធរ នៅទួលបាសាន មិនមែនចាប់ផ្តើមនៅឆ្នាំ១៤៣១ ឬ ១៤៣២នេះទេ
- ឈ្មោះខេត្តស្រីសឈរ (ជាឈ្មោះកើតក្រោយ ក្នុងរាជ្យស្រីសុគន្ធបទ បើតាមពង្សាវតារ) មិនអាចថាពាក្យនេះ នាំឱ្យហៅក្លាយជា ស្រីសន្ធរ នោះទេ
- ស្រីសន្ធរ ស្រីយសោធរ(បុរៈ), ឈ្មោះអនុស្សាវរីយ៍នៃរាជធានីចាស់ដ៏ល្បីល្បាញរបស់កម្ពុជាសម័យអង្គរ សូម្បីតែអយុធ្យាក៏រក្សាឈ្មោះនេះទុកដែរ (ហៅតែ ព្យាង្គ២ម៉ាត់នៅខាងចុង____សន្ធរ ឬស៊ីធរ__វត្តស៊ីធរ, ស៊ីធរកណ្ដាល, ស៊ីធរពារាំង)
- ខ្មែរមិនចោលដើមដានរបស់ដូនតាឡើយ ហើយមានទំនៀមប្រើឈ្មោះតែពីរព្យាង្គ
- ពីឆ្នាំ១៤៣៤__មកតាំងនៅចតុមុខ (បើទោះបីពង្សាវតារអយុធ្យាថា គេបានកាន់កាប់ទីក្រុងអង្គរយសោធរបុរៈពីឆ្នាំ១៤៣១__៤៥ក្ដី ក៏យើងនៅតែថា តាមឯកសារខ្មែរសិន)

## ២- តើមូលហេតុដូចម្តេច ទើបព្រះបាទពញាយ៉ាត មកតាំងរាជធានីនៅចតុមុខ?

បើតាមពង្សាវតារជាប្រពៃណី បានផ្តល់ហេតុផលដូចជា៖

●នៅស្រីសន្ធរ លើកទី១ បានពីរឆ្នាំ ព្រោះទឹកលិចខ្លាំង ទើបលើកចេញទៅចតុមុខ

●នៅស្រីសន្ធរ លើកទី២ បានប្រមាណ៣ឆ្នាំ ព្រោះស្តេចកនបះបោរបណ្តេញព្រះបាទស្រីសុគន្ធបទ ចុះចេញពីរាជបល្ល័ង្ក ប្រហែលនៅឆ្នាំ១៥០៨

●ដូច្នេះមូលហេតុនៃការលើករាជធានីលើកទី១ គឺជាលេសមិនសមហេតុផល៕

●បើលិចទឹកជំនន់ខ្លាំងនៅរដូវវស្សា ហេតុអ្វីក៏ស្រីសុគន្ធបទត្រឡប់ទៅនៅទីនោះទៀត?

●តំបន់ចតុមុខជាប់មាត់ទន្លេធំ រងទឹកជំនន់រដូវវស្សាដូចគ្នានឹងស្រីសន្ធរដែរ រឹតតែជាលេសមិនសមស្រប

ភស្តុតាងទំនាក់ទំនងជាមួយចិន

- ខ្មែរបានបញ្ជូនបេសកទូតនាំសួយសារអាករចំនួន២១លើក ទៅកាន់រាជវាំងមិងរបស់ចិននៅចន្លោះឆ្នាំ ១៣៧១ និង១៤១៩
- បេសកកម្មភាគច្រើន គឺដើម្បីធ្វើពាណិជ្ជកម្ម ឬដើម្បីរៀបចំទំនាក់ទំនងខាងពាណិជ្ជកម្ម ហើយក៏ប្រហែលជាក្នុងបំណងស្នើសុំជំនួយគាំទ្រពីចិន ដើម្បីប្រឆាំងនឹងការប្លន់កំទេចនាវាជារឿយៗពីសំណាក់ពួកសៀមផងដែរ៕ បានន័យថា ខ្មែរក៏ធ្វើជំនួញយ៉ាងសកម្មដែរ៕
- ដូច្នេះ សារៈសំខាន់ពាណិជ្ជកម្មអន្តរជាតិតាមដងទន្លេធំទាំង៤ ទើបជាមូលហេតុសមរម្យជាងគេ សម្រាប់ព្រះបាទពញាយ៉ាត ចេញពីទួលបាសាទដែលជាជម្រកលាក់ខ្លួនបណ្តោះអាសន្ន។
- ព្រះអង្គគួរតែត្រូវការដកហូតពន្ធ និងរកស៊ីជាមួយឈ្មួញបរទេសទាំងនោះ

# ការតាំងរាជធានីនៅចតុមុខ

- សារៈសំខាន់ខាងសាសនា ៖ ទន្លេ៤ប្រសព្វគ្នា គឺជាទីតាំងពិសិដ្ឋ ឬ ទីថ៌ៈដ៏ប្រសើរក្នុងព្រហ្មញ្ញសាសនា និងជាទីប្រជុំជនបុរាណស្រាប់ ដោយសារមានភស្តុតាងប្រាសាទឥដ្ឋកាលពីសតវត្សរ៍ទី៦, និងទី៧ ជាច្រើនបន្សល់ទុកនៅក្នុងតំបន់នេះ។
- ជាចំណុចកណ្តាលនៃប្រទេសនៅពេលនោះ
- សារៈសំខាន់នៃបណ្តុំប្រជាជន ដោយទីតាំងនេះនៅជាប់មាត់ទន្លេ មានបឹងច្រើន និងវាលទំនាបសម្រាប់ធ្វើកសិកម្ម។ នៅតំបន់នេះមានប្រជាកសិករ និងអ្នកជំនួញច្រើន ប្រជាជនមានដង់ស៊ីតេខ្ពស់ជាងកន្លែងផ្សេង
- ទឹកដីកំណើតរបស់ព្រះបាទពញាយ៉ាត ឬជាទីកន្លែងដែលព្រះអង្គបានចម្រើនវ័យនៅទីនេះ

## ៣.តើសម័យចតុមុខបានបន្សល់ទុកនូវវប្បធម៌ខ្មែរសម័យអង្គរដូចម្តេចខ្លះ?

1. ការកសាងវត្តភ្នំ ធ្វើជាមជ្ឈមណ្ឌល ឬ ស្នូលនៃរាជធានីថ្មី, ស្នូលរបស់កម្ពុជា, និងចក្រវាឡតាមទ្រឹស្តីលោកធាតុ ព្រោះជានិមិត្តរូបភ្នំព្រះសុមេរុ ឬភ្នំកៃលាស់ ដូចប្រាសាទបាគង, ប្រាសាទភ្នំបាខែង, ប្រាសាទធំខឿន៧ជាន់នៅកោះកេរ្តិ៍, ប្រាសាទតាកែវស្នូលនៃជយេន្ទ្រនគរី, ប្រាសាទបាពួន, ប្រាសាទអង្គរវត្ត, ប្រាសាទបាយ័ន ជាដើម។
2. ឈ្មោះរាជធានីជា«ចតុមុខ» ឬ «ចតុម៌ុខ» ត្រូវបានដាក់តាមជាឈ្មោះវិមានប្រពៃណីនៃទីតាំងគង់ប្រថាប់នៅជាអចិន្ត្រៃយ៍របស់ស្តេចសម័យអង្គរ ឬ មុនសម័យអង្គរ
3. ព្រះពុទ្ធមានព្រះភ័ក្ត្រ៤ ឬព្រះចតុមុខ ដែលត្រូវបានដាក់តម្កល់សម្រាប់សក្ការបូជាក្នុងវិហារវត្តភ្នំ ជារចនាបថទេវរូប ឬ ព្រះរូបគោល ដែលយកតាមគោលគំនិតប្រាង្គប្រាសាទបាយ័ន ដែលមានពោធិសត្វ ឬ ព្រះព្រហ្មមានព្រះភ័ក្ត្រ៤ បែរទៅកាន់ទិសទាំងបួន។ គេថែមទាំងប្រឌិតថា ព្រះនេះបានពីរន្ធគគីរអណ្តែតទឹកដែលដួនពេញផឹសបាន។ នៅលើស្វេតច្ឆត្រ និងរាជបល្ល័ង្កសព្វថ្ងៃ ក៏កំពូលវិមានមានរចនាព្រហ្មមុខ៤ដែរ។

# ពោធិសត្វលោកេស្វរៈ ឬ ព្រះព្រហ្មមុខ៤





## ប្រហែលជាព្រះមុខ៤ ដែលរឿងព្រេងថា ដូនពេញ យកពីរន្ធគគរមកតម្កល់នៅវត្តភ្នំ



# ស្តូបព្រះចតុមុខនៅក្នុងវិហារវត្តភ្នំ ដែលស្ថួលនៃរាជធានី, ប្រទេសកម្ពុជា និងចក្រវាឡលោកធាតុខ្មែរ







ព្រហ្មមុខ៤ ឬ លោកេស្វរមុខ៤នៅលើកំពូលប្រាសាទទេវាវិនិច្ឆ័យ និងលើស្វេតឆ័ត្រ ជានិមិត្តរូបព្រះភ័ក្ត្រពោធិសត្វលោកេស្វរនៃប្រាសាទបាយ័ន ដែលជារចនាបថចុងក្រោយនៃប្រាសាទអង្គរ



## តើសម័យចតុមុខបានបន្សល់ទុកនូវវប្បធម៌ខ្មែរសម័យអង្គរដូចម្ដេចខ្លះ?

4. «ស្រីធរ» ជាធាតុនៃបរមនាមរាជធានីចតុមុខមង្គល គឺជាភស្តុតាងនៃការចងចាំឈ្មោះរាជធានីអង្គរជាប្រពៃណីថា ស្រីយសោធរ(បុរ/បុរី) ដែលត្រូវបានយកមកដាក់នៅទួលបាសាន និងចតុមុខ ព្រមទាំងរាជធានីបន្តបន្ទាប់មកទៀត។ បើផ្អែកលើភស្តុតាងសហសម័យ ខ្មែរនៅចងចាំឈ្មោះរាជធានីអង្គរថា «ស្រីយសោធរ» និងភាពជាអ្នកស្នងពីអធិរាជ និងទីក្រុងអង្គរ។
5. ការចងចាំអំពីដីខ្មែរកម្ពុជទេសដ៏ធំនៅភាគខាងជើង និងរក្សាទុកមហិច្ឆតាមហាអំណាចរបស់ព្រះអធិរាជអង្គរ ដូចជា ព្រះបាទស្រីរាជាបានធ្វើសង្គ្រាមវាយប្រហារដណ្ដើមយកអយុធ្យា។
6. ជំនឿសាសនា ព្រាហ្មណ៍ និងព្រះពុទ្ធថេរវាទ ក្នុងប្រពៃណីនៃការអនុវត្តក្នុងពិធីផ្លូវការ ក្នុងរាជការ និងក្នុងសង្គមខ្មែរទូទៅ
7. បែបផែនរាជានិយម, រាជាធិរាជ, ឬមហារាជនិយម និងបច្ចេកពាក្យបរមនាម ឋានន្តរនាម និងធាតុទាំងឡាយនៃបរមនាម និងឋានន្តរនាមសម័យអង្គរនៅតែបន្តអនុវត្ត ឬប្រើនៅពេលនេះ

(១)សំតេចព្រះរាជឱង្ការបរមបពិត្រ ក្រុងកម្ពុជាធិបតី **ត្រីយសោធរ**ត្រងមហា(ន)
(២)នគរឥន្ទ្រប្រស្ថរត្នរាជធានី មេត្រីស្រលេញមោកញីប៉ុន ....នាញីបុន...



សំបុត្រស្តេចខ្មែរនៅសតវត្សរ៍ទី១៧




# ទីក្រុងចតុមុខមង្គល

- «វត្តភ្នំ» គឺជាបេះដូង ឬប្ញូជនីយដ្ឋានស្នូលនៃរាជធានីចតុមុខមង្គល ដូចភ្នំបាខែង, បាពួន, បាយ័ន, វត្តត្រឡែងកែង និងភ្នំព្រះរាជទ្រព្យដូច្នោះដែរ។
- «ភ្នំពេញ» គួរតែមានឈ្មោះថា «ពុំបិង_ភ្នំបិង» < Ponom Beng ឯកសារសហសម័យរបស់ប៉រទុយហ្កាល់, អេស្ប៉ាញ និងហូឡង់ឆ្នាំ១៦៤៤ Ponum Pingh, ពុំពិញ សតវត្សរ៍ទី១៩
- ប្រហែលឈ្មោះនេះជារឿងពិត ព្រោះស្ថានភាពភូមិសាស្ត្រនៅភ្នំពេញភាគច្រើនគ្របដណ្តប់ដោយបឹង នៅជុំវិញវត្តភ្នំ ដូចជានៅខាងត្បូងមានបឹងតេជោ, បឹងរាំង, បឹងព្រលឹត, បឹងកេងកង, បឹងត្របែក, បឹងទំពុន,បឹងសាឡាង ហើយនៅខាងលិចភ្នំគឺបឹងកក់,បឹងប្រយ៉ាប និងបឹងពោងពាយ

**ផែនទីប្រទេសកម្ពុជា នៅឆ្នាំ១៧៦០ គូរដោយពួកហូឡង់**




# ទីក្រុងចតុមុខមង្គល

- ដោយសារនៅសម័យបុរាណ តួព្យញ្ជនៈ «ព»មានសូរជា«ប», ព្យញ្ជនៈ«ប» មានសូរបីប្រភេទជា «ប៉, ប, ប៊», រីឯព្យញ្ជនៈ «ង»វិញ តែងប្រែប្រួលជំនួសគ្នាទៅវិញទៅមកជាមួយព្យញ្ជនៈ«ញ» ហេតុនេះ ពុំ_ភ្នំបិង អាចក្លាយជា ពុំពិង ឬ ពុំពិញ បាន។ គេមិនគួរជឿលើរឿងនិទានប្រឌិតនៅសតវត្សរ៍ទី១៩ ដែលថា ភ្នំពេញ មកពី ភ្នំដូនពេញ នោះទេ។ ព្រោះភ្នំនេះ គឺជាផលិតផលរបស់ព្រះបាទពញាយ៉ាត សម្រាប់ធ្វើស្ទូលនៃរាជធានីរបស់ព្រះអង្គ តាមគំនិតឬទស្សនៈនៃការសាងទីក្រុងពីសម័យដើម ដូចរៀបរាប់ខាងលើ។
- មានឧទាហរណ៍ ភ្នំតូចមួយនៅក្បែរភ្នំប្រសិទ្ធិ ដោយសារមានស្រែត្រពាំងពីរ_បីនៅក្បែរជើងភ្នំនោះ ទើបអ្នកស្រុកហៅឈ្មោះភ្នំនេះថា ភ្នំត្រពាំង ។







# រាជធានីចតុមុខនៅថ្ងៃទី១២ខែមិថុនាឆ្នាំ១៦៤៤




PLATE 3. Map drawn by an unknown Dutch participant in the expedition to Cambodia depicting the battle at Punompingh (Phnom Penh) on 12 June 1644. Drawn on Japanese rice pa Courtesy National Archives, The Hague.

## ៤- តើការវាយប្រហារអយុធ្យាដោយស្រីរាជាក្រោមហេតុផលដូចម្តេចខ្លះ?

- ព្រះបាទស្រីរាជា នៅចងចាំអំពីទឹកដីខ្មែរជាប្រពៃណីដែលលាតសន្ធឹងទៅខាងជើងឯនាយភ្នំដងរែក
- ព្រះអង្គបានសម្រេចព្រះទ័យ បើកការវាយលុកដណ្តើមយកអតីតអាណាខេត្តរបស់ខ្មែរវិញ
- រាជបល្ល័ង្ក និងក្រុមគ្រួសារ ព្រះអង្គទុកឱ្យព្រះអនុជធម្មរាជា មើលការខុសត្រូវ
- ការប្រមូលស្បៀងគាំទ្រសមរភូមិមុខ ទុកឱ្យក្មួយ(ភាគិនេយ្យោ)ព្រះនាមស្រីសុរិយោទ័យ
- ព្រះអង្គជំរុលកងទ័ពទៅវាយដណ្តើមកាន់កាប់អយុធ្យា តែមិនបានសម្រេច ដោយសារការទប់ទល់ស្វិតស្វាញរបស់កងទ័ពសៀម
- តាមប្រវត្តិសាស្ត្រ ទឹកដីអយុធ្យាជាផ្នែកមួយនៃចក្រភពអង្គរតរៀងមក ដូចសុខោទ័យ និងចន្ទបុរ(រៀងចន្ទ)ដែរ។ ដូច្នេះ សង្គ្រាមរបស់ព្រះអង្គ គឺជាការបង្រួបបង្រួមគ្នាឡើងវិញ

## ៥- តើជម្លោះផ្ទៃក្នុងនៅនសតវត្សរ៍១៤៧០ នៅចតុមុខ ដោយសារហេតុផលដូចម្តេចខ្លះ?

- នៅពេលព្រះមហាក្សត្រព្យាយាមវាយកាន់កាប់អយុធ្យា ក្មួយប្រុសនាមស្រីសុរិយោទ័យបែរជាក្បត់បំបែករដ្ឋ ដោយឆ្លៀតធ្វើនៅពេលមានឱកាសដើរកែនប្រមូលស្បៀងដើម្បីបញ្ជូនទៅសមរភូមិមុខ
- នៅពេលស្រីរាជា នាំកងទ័ពថយក្រោយវិញ ព្រះអនុជធម្មរាជា ប្រែចិត្តក្បត់ប្រឆាំងនឹងព្រះជេដ្ឋារបស់ខ្លួនដែរ។
- តាមពិតក្សត្រទាំងបី បានប្រកាសនូវភាពស្របច្បាប់នៃសិទ្ធិឡើងសោយរាជ្យសម្បត្តិដូចៗគ្នា រៀងៗខ្លួន។ ដោយសារ ស្រីរាជា បានស្នងពីព្រះជេដ្ឋា និងឱ្យធម្មរាជាជាអនុជចង់យកជាគម្រូតាម ចំណែកព្រះស្រីសុរិយោទ័យគឺជាអតីតបុត្រាស្តេចមុនស្រីរាជា។
- ក្សត្រទាំងបីគ្មានធម៌សាមគ្គីគ្នា បានធ្វើឱ្យនយោបាយរបស់ប្រទេសចុះខ្សោយ

# ជម្លោះផ្ទៃក្នុងដើម្បីរាជសម្បត្តិ (២លើក)




*ប្រវត្តិវិទូ Dauphin Meunier*



បរមរាជាទី ២ចៅពញាយ៉ាត។(១៣៩២_១៤៦៣ )

យសោធរបុរៈ_ _ទួលបាសាន_ _ចតុមុខ

**នរាយណ៍រាជាទី១**(១៤៦៣_១៤៦៩)។។**ស្រី រាជា**(១៤៦៩_១៤៨៥ )។។។។។។**ស្រី ធម្មរាជ**(១៤៨៦_១៥០៤)

ចតុមុខ ។។។ចតុមុខ_កំពង់សៀម ។។។។។ចតុមុខ

**ស្រី សុរិយោទ័យ**(១៤៧៥_១៤៨៥) **ចៅ ញា នុ**

។។។។។។ទួលបាសាន

**ស្រី សុគន្ធបទ**(១៥០៤_១៥១២ )«មានបុត្រយសរាជា»។។។។។ បរមរាជាទី (១៥១៦_១៥៦៦)។

**ចៅ ញា យ៉ោត រាជា**(ចតុមុខ_ទួលបាសាន ) ។។។។។ចៅពញា**ច័ន្ទរាជា**។«ពោធិសាត់_លង្វែក»

**ស្ដេច កន**។«**ស្រី ជេដ្ឋា ធិរាជ**»(១៥១២_១៥២៥ )

ជ្រែករាជ្យ «ទួលបាសាន_សន្ធប់ ដូនតី ឬស្រឡប់ ពិជ័យ»

# វិបត្តិរាជវង្សានុវង្សខ្មែរលើកទី១៖ ១៤៧៥_១៤៨៥

ពេលដែល ព្រះបាទស្រីរាជា វាយអយុធ្យាឆ្នាំ១៤៧៥ = ជាប់ដៃវាយយកអាណាខេត្តភាគខាងលិច ឬ បង្រួបបង្រួមដែនដីខ្មែរសារជាថ្មីឡើងវិញ?

• ស្រីសុរិយោទ័យ ដែលត្រូវប្រមូលស្បៀង, វាយខេត្តខាងកើត (ត្បូងឃ្មុំ,បាភ្នំ,ដូនណាយ,កំពង់សៀម, ស្ទឹងត្រង់ជើងព្រៃ–តាំងខ្លួនជាព្រះមហាក្សត្រ+បង្កើតរាជាណាចក្រខាងកើត

• ស្រីធម្មរាជា (ការពារក្រុងចតុមុខ)–ប្រមូលព្រះខ័ន,លំពែងរាជ្យ–បង្កើតរាជាណាចក្រខាងលិច បិទផ្លូវ ស្រីរាជាមិនឱ្យត្រឡប់វិញ

• ស្រីរាជា –តាំងរាជធានីកំពង់សៀម (កំ—ចាម)–រាជាណាចក្រខាងជើង

• រាស្ត្ររស់មិនបានសុខសាន្ត ទុរ្ភិក្ស, ចោរកម្ម

## ៦- ហេតុដូចម្ដេចនើបមានអន្តរាគមន៍របស់សៀមបញ្ចប់ជម្លោះនោះនៅឆ្នាំ១៤៨០?

- ព្រះធម្មរាជា លួចចងសម្ពន្ធមិត្តជាមួយស្ដេចសៀមដែលជាបងប្អូនជីដូន១ជាមួយព្រះអង្គ
- ជាទ្រឹស្ដីត្រូវមានថ្នូរ ឬ ការចុះចូលក្រោមការការពាររបស់អ្នកជួយ, ត្រូវចំណុះស្ដេចអយុធ្យា
- ឆ្នាំ១៤៨៥ សៀមប្រើល្បិចកលចាប់ព្រះបាទស្រីរាជា និងស្រីសុរិយោទ័យបានដោយជោគជ័យនាំឲ្យរាជបល្លង្កខ្មែរបានទៅព្រះធម្មរាជា តែមួយអង្គឯង។
- ជាតុរង្វាន់ ទឹកដីខ្មែរ និងឈ្លើយសឹកទាំងប៉ុន្មានដែលព្រះបាទស្រីរាជាដណ្ដើមបានពីសៀម ត្រូវប្រគល់ឲ្យសៀមវិញ ដោយស្វ័យប្រវត្តិ
- ដើម្បីស្ដារមុខមាត់ក្សត្រឡើងវិញ ព្រះបាទធម្មរាជា បានព្យាយាមបំពេញសីលទាន ប្រតិបត្តិធម៌តាមគន្លងពុទ្ធសាសនាយ៉ាងខ្ជាប់ខ្ជួន និងរក្សាសុខសន្តិភាពផ្ទៃក្នុងបាន១រយៈពេល ជាពិសេសការធ្វើបុណ្យបញ្ចុះព្រះសារីរិកធាតុនៅវត្តព្រះធាតុខ្វាវ ខេត្តសន្ទុក រួមមានស្រុកជីក្រែងសព្វថ្ងៃ

## ៧- តើជម្លោះផ្ទៃក្នុងរវាងព្រះបាទស្រីសុគន្ធបទ និងស្ដេចកន មានបុព្វហេតុ និងលទ្ធផលដូចម្ដេច?

វិបត្តិរាជវង្សជាលើកទី២ ពីឆ្នាំ១៥០៨-១៥១២

- ស្រីសុគន្ធបទ ឬពញាតាំខាត់រាជា ជាបុត្រាច្បង បានស្នងរាជ្យ និងតាំងរាជវាំងនៅស្រីសន្ធរ
- ពញាចន្ទរាជា ជាបុត្រាបន្ទាប់ ជាមហាឧបរាជ គ្រប់គ្រងនៅរាជវាំងចតុមុខ
- ស្រីសុគន្ធបទ តាមពង្សាវតារថា យកនាងស (ស្រីស ឈរ?)ជាពលព្រះនៅវត្តព្រៃបាំងធ្វើជាស្នំ
- ទើបលើកប្អូនប្រុសនាងស ឈ្មោះនាយកនជាមេទ័ព
- ដោយសារមានថ្វីដៃល្អ និងបានសាងគុណសម្បត្តិច្រើន ស្ដេចតំឡើងជា«ហ្លួងព្រះស្ដេចកន»

ផែនទីពេលបែងចែកជាបីអាណាចក្រ




# ខណ្ឌរាជវង្សលើកទី២ (១៥០៨-១៥១២គ.ស.)

- ទំនាស់ចាប់ផ្ដើមពីការប៉ងធ្វើឃាតហ្លួងព្រះស្ដេចកនដោយស្រីសុគន្ធបទ មិនបានសម្រេច
- ស្រីសុគន្ធបទ—ស្ដេចកន—ពញាចន្ទរាជា
- នាយកន ក៏ចាប់ផ្ដើមធ្វើសង្គ្រាមប្រឆាំងស្រីសុគន្ធបទឆ្នាំ១៥០៨ រហូតបានធ្វើគតព្រះអង្គនៅឆ្នាំ ១៥១២ ហើយប្រកាសខ្លួនជាស្ដេចគ្រប់គ្រងនៅស្រីសន្ធរ និងនៅស្រឡប់ពិជ័យ
- ក្រោយដឹងថា ព្រះរៀមសុគតដោយដៃស្ដេចកនហើយនោះ ព្រះអង្គច័ន្ទរាជា ទ្រង់រកឧបាយកល បញ្ឆោតស្ដេចសៀម ដើម្បីបានត្រឡប់មកទឹកដីខ្មែរវិញ។ សង្គ្រាម រវាងហ្លួងព្រះស្ដេចកន និងព្រះអង្គច័ន្ទរាជា ចាប់ផ្ដើមពី១៥១៦ដល់ឆ្នាំ១៥២៥
- ធ្វើសង្គ្រាមអស់១០ឆ្នាំ ទើបទ័ពព្រះច័ន្ទរាជា យកជ័យជម្នះលើស្ដេចកនបានវិញ

## ទីក្រុងរបស់ព្រះអង្គចន្ទ(ពោធិសាត់) និងស្តេចកន(បន្ទាយព្រៃនគរ)




# ទីក្រុងរបស់ព្រះអង្គចន្ទ ឬចន្ទរាជា

- នៅពោធិសាត់ ក្បែរមាត់បឹងទន្លេសាបដែលសំបូរដោយត្រីសម្រាប់ធ្វើស្បៀង
- នៅបរិបូរណ៍ ត្រង់បន្ទាយនៅជិតផ្នូកទ្រូដែលជាតំបន់សំបូរស្បៀង
- មានរៀបចំធ្វើពាណិជ្ជកម្មជាមួយប្រទេសម៉ាឡាយូ នៅអំឡុងពេលធ្វើចម្បាំងជាមួយស្តេចកន
- មានការទារពន្ធដារទៀងទាត់ និងតឹងរឹងពីឈ្មួញតាមដងទន្លេមេគង្គ និងប្រជារាស្ត្រជាកសិករ
- នាំឱ្យមានសក្តានុពលខាងសេដ្ឋកិច្ច មានប្រៀបជាងស្តេចកន ខាងសេដ្ឋកិច្ច
- គ្រប់គ្រងដែនដី/អាណាចក្រដោយប្រកាន់ច្បាប់តឹងរឹង (មនុស្សមានអារ្យធម៌ ត្រូវប្រកាន់ច្បាប់ជាធំ/ប្រទេសរុងរឿងមានអរ្យធម៌ ជាប្រទេសប្រកាន់ច្បាប់ជាធំ)

## ទីតាំងអ្នកតាឃ្លាំងមឿង ដែលជារណ្ដៅក្នុងបន្ទាយព្រះអង្គចន្ទរាជា ភ្សែរក្រុងពោធិ សាត់បច្ចុប្បន្ន




# រាជធានីរបស់ស្ដេចកន ព្រះស្រីជេដ្ឋាធិរាជ

- ទំនងនៅលើមូលដ្ឋានទីតាំងចាស់របស់ឥន្ទ្របុរៈ របស់ព្រះបាទជយវម៌ទី២(មានសំណង់ប្រាសាទសម័យមុនអង្គរ ជីកគូទឹកព័ទ្ធជុំវិញ,លើកពូនដីពូនកំពែងយ៉ាងខ្ពស់)
- ទំនងជាបានលើកផ្លូវមួយភ្ជាប់ទីក្រុងនេះជាមួយវត្តព្រះធាតុប្រស្រី (ដែលស្ដេចកនបានបញ្ចេញថ្វីដៃសងពួកលួចធ្វើឃាតព្រះអង្គ ក្នុងដំណើរមកសំពះព្រះ, សម្លាប់ម្ដង៥នាក់)
- នៅស្រុកពញាក្រែកត្រង់ព្រំដែនជាមួយស្រុកត្បូងឃ្មុំ ព័ទ្ធជុំវិញសុទ្ធសឹងជាវាលស្រែ
- គ្មានសក្ដានុពលភាពខាងពាណិជ្ជកម្ម
- ថ្វីបើព្រះអង្គចេះបង្កើតប្រាក់ស្លឹងសម្រាប់ចាយ តែមិនមានឯកសារកត់ត្រាថា ទ្រង់បានអភិវឌ្ឍន៍ពាណិជ្ជឡើយ ហើយការប្រមូលពន្ធដារក៏មិនបានធ្វើឱ្យគត់មត់ និងទៀងទាត់ ហើយប្រហែលទ្រង់កើតមានបញ្ហាវិបត្តិសេដ្ឋកិច្ចទៀតផង ទើបនាំឱ្យច្បាំងចាញ់គេ

បន្ទាយព្រៃនគរនៅស្រុកស្រឡប់ពិជ័យដូនតី, អតីតរាជធានីឥន្ទ្របុរៈរបស់ព្រះបាទជយវម៌្មទី២




## ខបត្តរាជវង្សលើកទី២ (១៥០៨-១៥១២គ.ស.)

បើតាមប្រភពឯកសារសហសម័យ គឺកំណត់ត្រាបុព្វជិតប៉រទុយហ្គាល់ និងសិលាចារឹកK.82

- ហ្គាស្ប៉ាដាគ្រុស១៥៥៥-៥៧ថា៖ ព្រះមហាក្សត្រពេលនោះ(ចន្ទរាជា)ឡើងសោយរាជ្យបានដោយការបះបោរដ៏ធំមួយ បង្ខំឱ្យព្រះរៀមរបស់ព្រះអង្គចុះចេញពីរាជបល្ល័ង្ក។ ក្រោយមកព្រះអង្គបានបង្ក្រាបការបះបោរបានជោគជ័យទើបបងប្រុសរបស់ព្រះអង្គ ប្រគល់ព្រះរាជាណាចក្រនេះ ឱ្យព្រះអង្គគ្រប់គ្រងជំនួសវិញ។ ចំណុចនេះមានន័យថា «អ្នកបះបោរមិនបានសម្លាប់ព្រះមហាក្សត្រនោះទេ»
- សិលាចារឹកវត្តនគរបាជ័យK.82 ឆ្នាំ១៥៦៦ ផ្នែកភាសាបាលីបានឱ្យដឹងថា ព្រះបរមនាមដ៏ខ្ពង់ខ្ពស់ថា «សិរីសោគន្ធបទ (=ស្រីសុគន្ធបទ) គឺជាអតីតព្រះមហាក្សត្រ» ចំណែកខាងភាសាខ្មែរថា «សំតេចឱកញ្ញាយស្ស ស្រីសៅគន្ធបទ(=ស្រីសុគន្ធបទ)» បានកសាងចៃតីយបញ្ចុះព្រះសារីរិកធាតុ និងកសាងវិហារនៅកណ្ដាលប្រាសាទនៃនគរជ័យវីរសក្ដិនេះនៅខែអាសាឍឆ្នាំ១៥៦៦នោះ ដើម្បីប្រគេនព្រះអរិយសង្ឃនាម មហានាគសេនបពិត្រ។ នេះបានន័យថា ស្រីសុគន្ធបទនៅមានព្រះជន្មដល់ឆ្នាំ១៥៦៦។





អត្ថបទជាភាសាខ្មែរ ៖ (ប៧-៨) សំតេចឱកញ្ញាយស្បគ្រីគៅគន្ធបទ (គឺជា.មន្ត្រីដ៏ខ្ពង់ខ្ពស់មួយរូប .នាម.ស្រីសៅគន្ធបទ)

អត្ថបទភាសាបាលី៖ .(ប១-២) សិរីសោគន្ធបទធិនាមោ បត្ថារញ្ញោ .(គឺមានន័យថា៖ .អ្នកមានអធិនាមជា .សិរីសោគន្ធបទ ).

គ្រីគៅគន្ធបទ = សិរីសោគន្ធបទ = ស្រីសុគន្ធបទ

# មេរៀនទី៤៖ រាជធានីលង្វែក និងការស្តារឡើងវិញ

# មាតិកាមេរៀនទី៦

១. បន្ទាយលង្វែក

២. ព្រះពុទ្ធ និងវត្តត្រឡែងកែង

៣. ការប្រែប្រួលខាងជំនឿសាសនា

៤. ការរៀបចំក្បួនច្បាប់ឡើងវិញ

៥. អង្គរ និងការថែរក្សាឡើងវិញ

៦. ការពង្រស់ទេវស្ថានការពារ

៧. មជ្ឈមណ្ឌលពាណិជ្ជកម្មលង្វែក

# បញ្ញត្តិសិក្សាមេរៀនទី៦

- ដុំថ្មលើមែកគគីរ,
- កំពែងឫស្សី,
- ពុទ្ធរូបត្រឡែងកែង,
- ព្រះពុទ្ធរូបធំៗ,
- ក្បួនខ្នាត,
- ចម្លាក់បង្អើយ, អភិរក្ស,
- អ្នកតានិងទេពរក្ស,
- ពាណិជ្ជកម្ម

## បុច្ឆនសិក្សាមេរៀនទី៦

- តើទីតាំងបន្ទាយលង្វែកមានសារៈសំខាន់ដូចម្តេច ក្នុងន័យសាសនានិងវប្បធម៌?
- (តើហេតុផលដូចម្តេចខ្លះ ដែលនាំឱ្យព្រះអង្គចន្ទកសាងរាជវាំង-ធានីនៅលង្វែក?)
- តើព្រះបាទចន្ទរាជាអភិវឌ្ឍន៍វប្បធម៌ខ្មែរដូចម្តេចនៅដើមរជ្ជកាលរបស់ព្រះអង្គ?
- តើព្រះបាទចន្ទរាជាមានជំនឿដូចម្តេចចំពោះអ្នកតា និងទេពរក្សការពារប្រទេស?
- តើតំបន់លង្វែកមានសក្តានុពលសេដ្ឋកិច្ចដូចម្តេច?
- តើសម័យលង្វែកមានសង្គ្រាមប្រឆាំងសៀមដូចម្តេចខ្លះ?
- តើនៅសម័យលង្វែកនេះមានសង្គ្រាមប្រឆាំងឡាវដូចម្តេច?
- តើនៅសម័យលង្វែកនេះ ស្តេចខ្មែរមានទំនាក់ទំនងដូចម្តេចជាមួយពួកអឺរ៉ុប?
- មូលហេតុដូចម្តេចខ្លះ នាំឱ្យលង្វែកដួលរលំដោយសារសៀម?
- តើវិបត្តិនយោបាយខ្មែរក្រោយបែកបាក់លង្វែក មានស្ថានភាពដូចម្តេច ?

## ព្រះរាជាសម័យលង្វែក



* មុនសម័យលង្វែក

(Michael Vickery)

- អង្គច័ន្ទភៀស-អយុធ្យា ដោយខ្លាចព្រះរៀមសម្លាប់ចោលមែន រួចទើបវិលវិញ
- សង្គ្រាមមានរយៈពេល១០ឆ្នាំ (១៥១៦-១៥២៥)

  -ស្តេចកនត្រូវព្រះបាទច័ន្ទរាជាបង្ក្រាប
- ក្រោយការយាងត្រឡប់៖ ដំបូងអង្គច័ន្ទតាំងរាជធានីបណ្តោះអាសន្ន

  -នៅពោធិសាត់ និង

  -ពន្លៃខេត្តអម្រិន្ទបូរ=បរិបូរ -កំពង់ឆ្នាំង

  -ចុងក្រោយប្តូរទៅទីក្រុងបន្ទាយលង្វែកវិញ



# ហេតុអ្វីបានជាព្រះអង្គចន្ទជ្រើសរើសលង្វែកធ្វើរាជវាំង ឬរាជធានីរបស់ព្រះអង្គ?

- ជួបអព្ភូតហេតុអស្ចារ្យ-ដុំថ្មមួយដុំធំនៅលើមែកគរគីរមួយដើមធំខ្ពស់=ជយភូមិ
- មានប្រាសាទបុរាណកាលពីសតវត្សរ៍ទី៧ និងសិលាចារឹកសតវត្សរ៍ទី១១ស្តីពីអំណោយដល់ទេវស្ថានដទៃ
- ទីក្រុងនេះ នៅជិតមណ្ឌលពាណិជ្ជកម្មលើដងទន្លេសាបចាប់កំពង់ហ្លួងដល់ពាមសត្វាដែលជាអតីតព្រែកជប៉ុន។ លោក ម៉ៃឃើលវិកឃើរី ថា មកពីទីក្រុងនេះរកស៊ីប្រជែងជាមួយអយុធ្យាទើបស្តេចនរេសួនវាយប្រហារបំបែកបណ្តាញនេះ និងត្រួតត្រាសក្តានុពលនេះដោយផ្ទាល់តែម្តងនៅចុងសតវត្សរ៍ទី១៦។

ការកសាងបន្ទាយលង្វែក

- ព្រះបាទច័ន្ទរាជាកសាង៣ឆ្នាំ(ពី១៥២៧-ផ្លាស់មករាជវាំងលង្វែកនៅឆ្នាំ១៥២៩)
- មានទំនប់ដីជាកំពែង, ប្រឡាយទឹក-គូទឹក-អូរ-ទន្លេ និងបឹងពីធម្មជាតិនៅជ្រុងខាងកើត, និងសង់សើនខ្ពស់ ច្រើនកន្លែងសម្រាប់ការពារ
- មានរាងបួនជ្រុងទ្រវែងបណ្តោយ៣គ.ម.ទទឹង២គ.ម. ដោយមានដាំរបងឫស្សីក្រម្រាស់ប្រមាណ១៥០មព័ទ្ធបីជ្រុង ដែលជា«បន្ទាយប្រាការ»ចុងក្រោយរបស់ខ្មែរ

# ការកសាងបន្ទាយលង្វែក

- មានវត្តត្រឡែងកែងនៅចំកណ្តាលបន្ទាយ
- ព្រះពុទ្ធរូបបួនអង្គទ្រង់ឈរទល់ខ្នងដែលឆ្លាក់ពីឈើខ្លឹមគរគីមួយដើមធំ
- ព្រះពុទ្ធបញ្ឈរលើព្រះបាទបួនគូធ្វើពីថ្ម ដែលធ្លាប់ជាប់នៅលើដើមឈើធំដែលស្តេចឱ្យគេឆ្លាក់ធ្វើព្រះ
- សាងរូបបដិមាព្រះកែវ និងព្រះគោសម្រាប់លាក់ទុកវត្ថុស័ក្តិសិទ្ធ-ទុកក្បួនក្នុងពោះព្រះគោ ដាក់ក្នុងវិហារមួយផ្សេងទៀត ហៅវិហារព្រះគោព្រះកែវ ដែលក្រោយពេលបែកទីក្រុង រតនវត្ថុទាំងនោះត្រូវសៀមរឹបយកជាជយភ័ណ្ឌ
- ព្រះបដិមាទាំងនេះ គេមានជំនឿថា មានបារមី និងឫទ្ធិអំណាចស័ក្តិសិទ្ធិ




© 2009 Mapabc.com
© 2009 Cnes/Spot Image
© 2009 Europa Technologies
Image © 2009 DigitalGlobe


© 2009 Mapabc.com
© 2009 Google
© 2009 Europa Technologies
Image © 2009 DigitalGlobe
104°45'17.40" E
elev 51 ft
Eye alt 14156 ft


© 2009 Mapabc.com
© 2009 Google
© 2009 Europa Technologies
Image © 2009 DigitalGlobe
Google
1'51.19" N 104°45'49.27" E
elev 54 ft
Eye alt 4939 ft


© 2009 Mapabc.com
© 2009 Google
© 2009 Europa Technologies
Image © 2009 DigitalGlobe
Google
1'59.05" N 104°45'35.96" E
elev 54 ft
Nov 23, 2002
Eye alt 1609 ft



ឫស្សីដែលដុះនៅកំពែងបន្ទាយលង្វែក



ទិហារត្រៃឡខកែខ



ពុធ ៩ រូបត្រ័ឡែងកែង



ពុធ ៩ រូបត្រ័ឡែងកែង

## ព្រះពុទ្ធបាទ៤គូធ្វើពីដុំថ្មទើរលើមែកគគីរ





## គំនូររឿងព្រះគោព្រះកែវនៅវិហារព្រះគោព្រះកែវ





## គំនូររឿងព្រះគោព្រះកែវនៅវិហារព្រះគោព្រះកែវ






## គំនូររឿងព្រះគោព្រះកែវនៅវិហារព្រះគោព្រះកែវ






រោងអ្នកតាលើដំណែលប្រាសាទឥដ្ឋបាក់មែបកកាលពីសតវត្សរ៍ទី៧ នៅក្បែរកំពែងខាងក្នុង




# ការអភិវឌ្ឍន៍វប្បធម៌

- ទស្សនៈហិណ្ឌូនិយម«គោ»_តំណាង(ច្បាប់)+និមិត្តរូបតំណាងឱ្យ (ធម៌)
- ដើម្បីនិរន្តរភាពនៃជាតិសាសន៍ខ្មែរ ព្រះអង្គបានរក្សាឃ្លាំងវប្បធម៌ជាតិដ៏ធំបន្ទាប់ពីអង្គរ
- ព្រះបាទចន្ទរាជា បានប្រមូលអ្នកចេះដឹងក្នុងស្រុកដែលនៅសល់ពីការស្លាប់ ដើម្បីរួមគ្នាចងក្រងក្បួនខ្នាត ទុកឡើងវិញ
- តាមសិលាចារឹកនៅឆ្នាំ១៥៤៦ និង១៥៦៤ បង្ហាញថា ខ្មែរនៅដឹងរឿងរ៉ាវពិតកាលពីសម័យអង្គរនៅឡើយ
- ក្បួនខ្នាតបង្កប់នូវតម្លៃខាងវប្បធម៌, បច្ចេកទេស, អក្សរសិល្ប៍, យុទ្ធសាស្ត្រ(តាមជំនឿ) សម្រាប់អប់រំចំណេះដឹងមូលដ្ឋាន និងយុទ្ធសាស្ត្រ

# ការអភិវឌ្ឍន៍វប្បធម៌

- គម្ពីរ ឬសាស្ត្រាជាវត្ថុមង្គល និងមានតម្លៃដល់កូនចៅខ្មែរ ដែលអាចនាំឱ្យគេមានអានុភាពខ្លាំងពូកែ
- សៀមដឹងច្បាស់រឿងនេះ ទើបខំវាយប្រហារដណ្តើមយកទុកជាសម្បត្តិផ្ទាល់ខ្លួន ឬបំផ្លាញចោល
- ខ្មែរជឿថា ដោយសារសៀមវាយបែកទីក្រុងលង្វែក នាំឱ្យគម្ពីរ+ក្បួនខ្នាតដែលនាំឱ្យខ្មែរចេះដឹងត្រូវគេរឹបអូសយកទៅអស់ ទើបចាប់ពីត្រឹមនេះ ខ្មែរចុះខ្សោយ ហើយលែងដឹងរឿងរ៉ាវពិតពីសម័យអង្គរ

# ការអភិវឌ្ឍន៍វប្បធម៌

- តាមសិលាចារឹកនគរវត្ត៥ផ្ទាំង និងភ្នំបាខែង នាំឱ្យគេដឹងថា៖
- ព្រះបាទចន្ទរាជា បានទទួលឥទ្ធិពលពីសៀមអយុធ្យា ៕ ដោយមានព្រះនាមផ្លូវការថា ព្រះបាទសំតេចព្រះរាជឱង្ការបរមរាជាធិរាជ រាមាធិបតី បរមចក្រពត្តិរាជ, បានបញ្ជាឱ្យជាងឆ្លាក់បង្ហើយលើជញ្ជាំងថៃវជាប់មុំឥសាននៃប្រាសាទអង្គរវត្តពីឆ្នាំ១៥៤៦ដល់១៥៦៤
- ព្រះអង្គជាព្រះមហាក្សត្រជឿជាក់មុតមាំលើព្រះពុទ្ធសាសនា ដោយការស្ថាបនាព្រះពុទ្ធរូបធំៗ ដូចជា នៅវត្តត្រឡែងកែង,លើភ្នំព្រះរាជទ្រព្យ,ប្រាសាទបាពួន,ព្រះពុទ្ធរូបគង់នៅមុខប្រាសាទព្រះបាលិល័យ, ព្រះអង្គធំនៅភ្នំគូលេនជាដើម
- មានការបះបោរដ៏ធំមួយរបស់ឧកញ៉ាឱង ដែលជាចៅហ្វាយខេត្តពោធិសាត់ក្នុងទសវត្សរ៍ឆ្នាំ១៥៥០ ដោយបានកាន់កាប់អាណាខេត្តភាគខាងជើងរួមទាំងសៀមរាបផង

សិលាចារឹករបស់ ព្រះបាទចន្ទរាជានៅអង្គរវត្ត។ឆ្នាំ១៥៤៦_១៥៦៤



K. 296



K. 297

**អតិថខ្លាន័ចប្បធមីនរមនាមយ៉ាងថែង**

**តាមស្ដេចអយុធ្យា**



ព្រះពុទ្ធសយនា(ព្រះភ្នំព្រះរាជទ្រព្យ)



ព្រះពុទ្ធសយនា(ព្រះភ្នំព្រះរាជទ្រព្យ)



ព្រះពុទ្ធសយនា(ព្រះភ្នំព្រះរាជទ្រព្យ)



ព្រះពុទ្ធរូបប្រាសាទបាពួន



ព្រះពុទ្ធរូបប្រាសាទបាពួន



ព្រះពុទ្ធរូបប្រាសាទបាពួន



## ព្រះពុទ្ធរូបនៅប្រាសាទវត្តមហាធាតុ នៅអយុធ្យា



## ព្រះពុទ្ធរូបនៅមុខប្រាសាទព្រះបាលិល័យតាមរបៀបពុទ្ធរូបនៅអយុធ្យា ដែលឆ្លាក់លើដុំថ្មផ្សុំ





กัมพูชา

ព្រះអង្គធំ(ព្រះខ្ពង់)



ព្រះអង្គធំ(ព្រះខ្ពង់)



# ព្រះពុទ្ធរូបបរិនិព្វាននៅវត្តលោកាយសុត្រ នៅអយុធ្យា ដែលធ្វើពីថ្មផ្សំជាច្រើនដុំ ដែលព្រះបានចន្ទរាជាយកតំរូតាមក្នុងរង្គភាលរបស់ព្រះអង្គ




ព្រះអង្គធំ(ព្រះខ្ពង់)



ព្រះអង្គធំ(ព្រះខ្ពង់)



ចៃតិយបន្ថែមលើប្រាសាទជ័យវីរសក្តិ



# ការអភិវឌ្ឍន៍វប្បធម៌

- ក្រោយពីព្រះអង្គចូលទិវង្គតនៅឆ្នាំ១៥៦៦ មានបច្ឆាមរណនាមថា មហាបរមនិព្វានបទ
- បន្ទាប់មកនៅក្នុងរាជ្យព្រះបាទសត្ថាទី១ ឬជយជេដ្ឋាទី១ និងព្រះរាជមាតារបស់ព្រះអង្គ បានចំណាយពេលជាច្រើនឆ្នាំ នៅតំបន់អង្គរ ដើម្បីបំបួសព្រះរាជទាយាទ និងព្រះមាតា និងធ្វើការជួសជុលប្រាសាទអង្គរវត្ត នៅរវាងចុងទសវត្សរ៍១៥៧០ និងដើម១៥៨០
- ព្រះអង្គជួសជុលប្រាសាទអង្គរវត្តឱ្យទៅជាប្រាសាទកំពូល៩ និងទីបទឹកមាសស្រោបប្រាសាទឱ្យល្អវិចិត្រ ដូចពីសម័យដើមឡើងវិញ
- អំឡុងឆ្នាំ១៥៨៣មានព្រះសង្ឃជាន់ខ្ពស់មួយអង្គមកពីអយុធ្យា បានដើរធ្វើបុណ្យសាង និងជួសជុលព្រះពុទ្ធរូបនៅភ្នំព្រះរាជទ្រព្យ, ភ្នំបាខែង, អង្គរវត្ត និងភ្នំគូលេន

## ជំនឿលើទេវស្ថានព្រាហ្មណ៍

- ព្រះច័ន្ទរាជា(អង្គច័ន្ទទី១)_ជំនឿលើពុទ្ធសាសនា—
- ឱ្យគេកសាងវត្តអារាមជាច្រើន—ឱ្យគេកសាងនៅពោធិ៍សាត់_បរិបូណ៌_
- ជួសជុលនៅឧដុង្គវត្តលើភ្នំព្រះរាជទ្រព្យ(ពុទ្ធរូបចូលនិព្វាន)_
- វត្តត្រឡែងកែងនៅបន្ទាយលង្វែក—ក្នុងវិហារតម្កល់ពុទ្ធរូបត្រឡែងកែង ពុទ្ធរូប៤អង្គឈរទល់ព្រះប្រឹស្ឋ(ខ្នង)ទល់គ្នា បែរព្រះភក្រទៅទិសទាំងបួន_សម័យនោះខ្មែរចាត់ទុកពុទ្ធរូបត្រឡែងកែងនេះជាវត្ថុសក្ដិសិទ្ធិមួយ
- មានទេវរក្ស១៣អង្គ និងអ្នកតាមួយអង្គ

## ជំនឿ _ _ ទេវរក្សរក្សានគរមាន១៣អង្គ

- ភ្នំពេញ.(ពុំបិង/ពុំពិញ)
- នៅភ្នំព្រះរាជទ្រព្យ១
- នៅវត្តស្លាកែត.វត្តជ្រោយអំពិល១
- នៅវត្តកៀនស្វាយក្នុង១
- នៅវត្តភ្នក្រោកមាស១.(នៅថឡាបរិវ៉ាត់)
- នៅព្រៃកបង្គង១
- នៅវិហាសួគ៌១.ជាទ្វារព្រះនគរ
- ឃ្លាំងមឿង.នៅខេត្តពោធិសាត់១
- ព្រះអដ្ធរស្សនៅវត្តត្រឡែងកែង១
- នៅភ្នំព្រះរាជទ្រព្យ១.(មានព្រះកែវនាគនិង តាដំបងដែក)
- នៅភ្នំជីសូរ១
- នៅភ្នស្រង់១
- នៅវាលស្បូវ១
- អ្នកតាមេសរ.នៅបាភ្នំ១

# ពាណិជ្ជកម្ម

- ភស្តុតាងបុរាណវិទ្យា មានមជ្ឈមណ្ឌល ពាណិជ្ជកម្មនៅក្បែររាជវាំងលង្វែក
- បំណែកផលិតផល/ទំនិញមកពីជុំវិញ ពិភពលោក
- ប្រជុំជនកំពង់ហ្លួង ជាទីផ្សារយូរយារមក ហើយនៅលើដងទន្លេសាបត្រើយស្តាំ




## ភស្តុតាងមណ្ឌលពាណិជ្ជកម្មសកលលោកនៅលង្វែក



Ceramic fragments are washed using water and toothbrushes by villagers hired by the archaeological team excavating the royal city of Longvek. Despite prevailing notions of the Longvek period as a dark age, new research is shedding light on its place as a centre of global trade. Alessandro Marazzi Sassoon



Fragments of a 16th century ceramic bowl from Fujian province, the second such find at an archaelogical site, which indicates Longvek held considerable wealth and power.
(@) Alessandro Marazzi Sassoon

## ១. សង្គ្រាមប្រឆាំងសៀមឈ្លានពាន

ដោយសារព្រះបាទចន្ទរាជាមិនចុះញ៉ម ចូលរណបសៀម ទទួលស្គាល់សៀមជាអធិរាជរបស់ព្រះអង្គ តាមការទាមទាររបស់ស្តេចសៀម ។បានបញ្ជូនកងទ័ពមកផ្តួលរំលំព្រះអង្គចំនួន២លើកផ្ទួនគ្នា

- ការវាយលុករបស់សៀមអយុធ្យាដំបូងនៅក្នុងឆ្នាំ១៥៣០ ដណ្តើមកាន់កាប់នៅតំបន់អង្គរវត្ត
- ព្រះអង្គបាននាំទ័ពទៅវាយប្រហារកងទ័ពសៀមដែលកាន់កាន់តំបន់នោះ
- ជាលទ្ធផល សៀមទទួលរងការបរាជ័យយ៉ាងធ្ងន់ធ្ងរបំផុត
- ទើបក្នុងពង្សាវតារខ្លះអះអាងថា ការបរាជ័យរបស់សៀមពេលនោះ គឺជាបុព្វហេតុនាំឱ្យព្រះអង្គបញ្ជាឱ្យប្តូរឈ្មោះខេត្តមហានគរ មកជា«សៀមរាប»វិញ

## ១. សង្គ្រាមប្រឆាំងសៀមឈ្លានពាន

- ជាលើកទី២ សៀមឈ្លានពាននៅឆ្នាំ១៥៣៦
- តាមពង្សាវតារខ្មែរភាគច្រើន ថា ចៅពញាអុង ដែលជាបុត្រាព្រះបាទស្រីរាជា ដែលស្តេចអយុធ្យាចាប់បាន យកទៅទុកនៅអយុធ្យាកាលពីឆ្នាំ១៤៨៥ បានលើកទ័ពមកវាយព្រះបាទចន្ទរាជា
- ចៅពញាអុងជាបុត្រធម៌ស្តេចអយុធ្យា និងជាចៅហ្វាយខេត្តស្តេចត្រាញ់ សវ៉ាន់ណៈខាក់លោក នៅខាងជើងសុខោទ័យ
- ព្រះបាទចន្ទរាជា បានសម្លាប់បងជីដូនមួយដែលបម្រើស្តេចអយុធ្យាអង្គនេះ នៅលើខ្នងដំរី នៅពេលប្រយុទ្ធគ្នានៅវាលម្ទូ ខេត្តពោធិសាត់

### ឱកញាឱង

ខ្ញុំគាំទ្រការសង្ស័យរបស់លោកវិកឃើរី ថា ពញាអុង ក្នុងពង្សាវតារអយុធ្យា ប្រហែលជាការចម្លងពង្សាវតារខ្មែរមួយច្បាប់ ដែលបានផ្តល់ពត៌មានដូចសិលាចារឹកនគរវត្តលេខ៤ គឺឱកញាឱង ជាចៅហ្វាយខេត្តពោធិសាត់បានបះបោរប្រឆាំងព្រះបាទចន្ទរាជា និងប្រហែលជាបុត្រាព្រះបាទស្រីរាជា ព្រមទាំងជាជីដូនមួយរបស់ព្រះអង្គចន្ទរាជា។

- ឱកញាឱង បះបោរកាន់កាប់អាណាខេត្តខាងជើង រួមទាំងអង្គរឆ្នាំ១៥៥៤-៧?
- ចៅហ្វាយខេត្តពោធិសាត់ គឺ ឱកញាស្វគ៌្គលោក > ឱកញាសួគ៌ាលោក
- នៅអយុធ្យា ខេត្ត«ស្វគ៌្គលោក» ហៅថា សវ៉ាន់ណៈខាក់លោក តាមសំនៀងថៃ ទើបនាំឱ្យពួកអ្នកចារពង្សាវតារអាចលួចចម្លងគ្នាប្រឌិតរឿងបានស្រួល

**អកប្លួងអតយរាជនុអ្នកអក ឆម្ម៌មានចិត្រសទ្ធាសាងព្រះ វិហារស្បាតនោះអំពីឆ្នាំ ថោះកាលអកញ្ញាឱង លុះ តលឆ្នាំមខាលអ្នកព្រះឱន្ការ ព្រឹត្រនិព្វានទេបស្រេច**



**ការពង្រឹងពង្រីកអំណាច**

- បរមរាជាទី៤ ឬ បរមិន្ទរាជា,បរមេន្ទរាជា ជារាជបុត្រាទី២របស់ព្រះបាទចន្ទរាជា
- ព្រះអង្គវាយប្រហារអយុធ្យាដោយចៃដន្យចំពេលសៀមចុះទន់ខ្សោយ ដោយមានសង្គ្រាមជាមួយភូមា
- ព្រះអង្គវាយប្រហារយកអាណាខេត្តខាងលិចមួយចំនួនបន្ថែមទៀត ដែលសៀមធ្លាប់រឹបយក និងបង្ហួសទៅវាយលុកអយុធ្យាតែមិនអាចវាយចូលបាន ដោយឧបសគ្គឆ្លងទន្លេ
- ផ្ទុយទៅវិញធ្វើឱ្យស្លាប់មេទ័ពអស់ជាច្រើននាក់ដោយសារត្រូវគ្រាប់កាំភ្លើងធំនៅឆ្នាំ ១៥៥៧_ប្រើកម្លាំងទ័ព២០ ០០០នាក់

# ការពង្រីកពង្រីកអំណាច

- ត្រឡប់មកវិញឆ្លៀតឱកាសកៀរយកមកជាមួយនូវគ្រួសារសៀមនៅទីនោះបានជាច្រើនគ្រួសារ
- មានឯកសារខ្លះទៀតថា នៅមានសង្គ្រាមពីរលើកទៀត នៅឆ្នាំ១៥៥៩ និង១៥៦២
- ព្រះបាទបរមិន្ទរាជា ជាស្តេចសឹកដ៏ខ្លាំងពូកែមួយអង្គចុងក្រោយគេ ដែលលើកទ័ពទៅវាយយកខេត្តមួយចំនួននៅភាគខាងលិច និងឧត្តរយកមកវិញ ហើយគម្រោមវាយអយុធ្យា
- អយុធ្យា ទើបតែបញ្ចប់សង្គ្រាមធំជាមួយភូមា ហើយរាជវង្សថ្មីនៅទីនោះ ត្រូវនៅចំណុះស្តេចភូមានៅហង្សាវតី

## សន្ធិសញ្ញាមិត្តភាពជាមួយសៀម

- ដោយហេតុនេះហើយ ទើបសៀមយល់ព្រមចូលរណបខ្មែរលង្វែក បង្ខំចិត្តទទួលស្គាល់ការកាន់កាប់របស់ខ្មែរទៅខេត្តទាំងនោះសិន
- ដើម្បីរក្សាប្រទេសកុំឱ្យមានសត្រូវទាំងសងខាង និង ដើម្បីសម្ងំស្តារប្រទេសឡើងវិញ
- ពង្សាវតារខ្មែរថា ជាសន្ធិសញ្ញាមិត្តភាព បែបដូចន័យមិត្តភាពក្នុងសម័យទំនើប។
- ការពិត គឺជាការយល់ព្រមនៅចំណុះលង្វែក និងត្រូវលើកសួយថ្វាយស្តេចលង្វែក
- មានការបញ្ជាក់ថា មានការបោះបង្គោលព្រំដែនកំណត់ការបែងចែកប្រទេសជាថ្មី
- ទោះជាយ៉ាងណា អយុធ្យាមិនកត់ត្រារឿងនេះទុកក្នុងពង្សាវតាររបស់ខ្លួន
- ប៉ុន្តែពង្សាវតារខ្មែរ បញ្ជាក់ពីការលើកទ័ពជួយអយុធ្យាប្រឆាំងភូមានៅឆ្នាំ១៥៨៣ គឺភស្តុតាងដែលខ្មែរជួយសម្ពន្ធមិត្តរណបខ្លួននោះឯង។

# សង្គ្រាមជាមួយឡាវ

- ក្នុងរជ្ជកាលព្រះបាទបរមរាជាទី៤ ដដែល៖
- ១៥៧២ ស្ដេចលាវ_លានជាង—ឱ្យមន្ត្រី២នាក់_ពល១០០០នាក់ មកបបួលស្ដេចខ្មែរជល់ដំរីដាក់នគរ បើដំរីខាងណាចាញ់ នគរខាងនោះត្រូវនៅចំណុះអ្នកឈ្នះ៕
- ដំរីខ្មែរតូចជាងដំរីលាវ តែមានសំណាងល្អបានឈ្នះ ចំណែកស្ដេចឡាវក៏ក្រលាស់សម្ដី
- ស្ដេចឡាវលើកទ័ពវាយលុកស្រុកខ្មែរ តាមជើងទឹកផង ជើងគោកផង
- ទ័ពខ្មែរបង្ក្រាបទ័ពលាវបានទាំងពីរសមរភូមិ និងចាប់បានឈ្លើយសឹកជាច្រើននាក់ ក្នុងនោះឱ្យ ១០០០ទៅនៅខេត្តបារាយណ៍, ៨០០ទៅនៅបាភ្នំ, ៥០០នៅថែរក្សាវត្តភ្នំពេញ—ខ្មែរថា លាវបាក់ទូក នាំឱ្យសព្វថ្ងៃនៅសល់ស្ថាននាមចុងថា បាក់ទូក
- នៅឆ្នាំ១៥៧៤ ឡាវប្រាថ្នាសងសឹក តែការប៉ុនប៉ងត្រូវបរាជ័យ ដោយសារភូមាឈ្លានពានខ្លួន ហើយទ័ពនៅស្រុកខ្មែរប្រឈមមុខនឹងភ្លៀងជោគជាំខ្លាំងមិនបាន

### ដងទន្លេមេគង្គឆ្លាច់ឡាវនិងកម្ពុជា



## ដងទន្លេមេគង្គភ្ជាប់ឡាវនិងកម្ពុជាមានល្បាក់ទឹកនិងថ្មប៉ប្រះទឹក




## ដងទន្លេមេគង្គភ្ជាប់ឡាវនិងកម្ពុជាមានឧបសគ្គមិនអាចឱ្យគេធ្វើនាវាចរណ៍តាមទូកបានឡើយៗ តើឡាវនាំទូកចម្បាំងមកច្បាំងប្រឆាំងខ្មែរដូចម្ដេច?



## ទន្លេមេគង្គត្រង់ព្រំដែនខ្មែរឡាវសព្វថ្ងៃហូរកាត់ដុំថ្មធំៗ និងមានល្បាក់បែបនេះ









# ទំនាក់ទំនងជាមួយពួកអឺរ៉ុប

- ចំណាប់អារម្មណ៍ដំបូងរបស់ជនជាតិអឺរ៉ុបនៅក្នុងតំបន់អាស៊ីអាគ្នេយ៍
- ប្រមូលទិញគ្រឿងទេសមកពីតំបន់មានឈ្មោះថា «កោះគ្រឿងទេស»
- គ្រឿងទេសមាន២ប្រភេទ ដែលមានសារៈសំខាន់_ផ្កាក្លាំពូ+ចន្ទន៍ក្រស្នា ដែលមានដុះតែលើកោះនោះ
- ១៥១១ ប៉រទុយហ្គាល់ដណ្ដើមកាន់កាប់បាន «ម៉ាឡាកា»
- ១៥១២ ពួកគេទៅដល់កោះគ្រឿងទេស ដែលជាកន្លែងផលិត មានកោះ Molucca/Maluca,Banda,Ternate+Tidore)សព្វថ្ងៃនៅប្រទេស ឥណ្ឌូនេស៊ី
- ប៉រទុយហ្គាល់ បង្ខំឲ្យមេដឹកនាំកោះចុះកិច្ចសន្យាប្រមូលផលគ្រឿងទេសទុកលក់ឱ្យផ្ដាច់មុខ

# ទំនាក់ទំនងជាមួយពួកអឺរ៉ុប

- ក្រៅពីចំណាប់អារម្មណ៍ជាមួយការកាន់កាប់ម៉ាឡាកាពីឆ្នាំ១៥១១ និងផលិតផលគ្រឿងទេសនៅឥណ្ឌូនេស៊ី ប៉រទុយហ្គាល់មិនចាប់អារម្មណ៍អាស៊ីអាគ្នេយ៍ដីគោកឡើយ
- រហូតដល់ទសវត្សរ៍១៥៨០ ទើបពួកគេមានទំនាក់ទំនងជាមួយកម្ពុជា
- ជនជាតិព័រទុយហ្គេរបានមកដល់កម្ពុជាមុនគេ ជាអ្នកផ្សាយសាសនា អ្នកជំនួញ និងទាហានស៊ីឈ្នួល (ប្រទេសនៅដីគោកបានជួលពួកគេយជួយធ្វើសង្គ្រាមឈ្លានពានគ្នា)
- ជនជាតិអេស្ប៉ាញបានមកដល់បន្ទាប់ពីព័រទុយហ្គេ
- ចាប់ពីសតវត្សទី១៧មក មានជនបរទេស_ដល់កម្ពុជាគឺជាអង់គ្លេស,ហូល្លង់ដ៍

# ទំនាក់ទំនងជាមួយពួកអឺរ៉ុប

- ពួកគេដឹងច្រើនពីរបៀបប្រើកាំភ្លើង និងយុទ្ធសាស្ត្រសង្គ្រាមទំនើប—ព្រះរាជានៅអាស៊ីអាគ្នេយ៍ចាត់ទុកពួកគេជាអ្នកជំនាញដ៏សំខាន់
- ជនជាតិអឺរ៉ុបខ្លះបានមកដល់កម្ពុជាជាអ្នកផ្សងព្រេង
- ជនជាតិអឺរ៉ុបខ្លះទៀតមកដល់កម្ពុជា ក្នុងនាមជាបុព្វជិតផ្សព្វផ្សាយគ្រីស្តសាសនា
- ជនជាតិអឺរ៉ុបខ្លះមកជាអ្នកពាណិជ្ជកម្ម
- ជនជាតិអឺរ៉ុបទាំងនោះ_ព័រទុយហ្គេ+អេស្ប៉ាញ បានទុករបាយការណ៍របស់ខ្លួន_ធ្វើឱ្យអ្នកចងក្រងប្រវត្តិសាស្ត្របានពត៌មានជាច្រើនអំពីរឿងរ៉ាវដែលកើតឡើងក្នុងប្រទេសកម្ពុជានៅចុងសតវត្សរ៍ទី១៦និងដើមសតវត្សរ៍ទី១៧

# ទំនាក់ទំនងជាមួយពួកអឺរ៉ុប

- បេសកទូតព័រទុយហ្គេកាតូលិកនាម Gaspar Da Cruz បានមកកាន់កម្ពុជាក្នុងឆ្នាំ១៥៥៥_១៥៥៧ បានកត់ត្រាពីព្រះបាទអង្គចន្ទខ្លះៗ
- ហូល្លង់÷ លន្ទា មកកាន់កម្ពុជារវាងឆ្នាំ១៦២០, ជាពាណិជ្ជករសំខាន់នៅកម្ពុជា ដែលមានមូលដ្ឋានខាងជើងព្រែកពាមសត្វា ប្រមាណ៥០០ម៉ែត្រ ឬ៥គីឡូម៉ែត្រពីកំពង់ហ្លួង
- ពេលនោះខ្មែរហៅពួកអឺរ៉ុបថា «បារាំង»ទាំងអស់
- លើកលែងពួកហូឡង់ ដែលខ្មែរហៅតាមជ្វាថា «លន្ទោ» ដោយផលជា «លន្ទា» ។ ព្រោះជ្វាមានទម្លាប់ហៅពួកអឺរ៉ុបដែលរកស៊ីនៅប្រទេសពួកគេថា លន្ទោ។ ទាល់តែដល់សតវត្សរ៍ទី១៩ ទើបគេច្បាស់ថា លន្ទោជាហូឡង់ ដូចខ្មែរដែរ៖ បារាំង គឺជាហ្វ្រង់សែ

# រាជវង្សអឺរ៉ុប

- ព័រទុយហ្គេ+អេស្ប៉ាញ—វត្តមាននៅកម្ពុជា ១៥៨០_
- មានពួកនេះពីរនាក់ដែលបានដើរតួនាទីដ៏សំខាន់ក្នុងឆាកនយោបាយខ្មែរ ដោយបម្រើការឱ្យព្រះបាទសត្ថា
- Diego Veloso = Spanish
- Blas Ruiz = Portuguese
- ១៥៨០_១៦០១ពួកគេបានធ្វើជាអង្គរក្សស្តេច ធ្វើអ្នកការទូត សម្លាប់ព្រះបាទរាមជើងព្រៃ និងជួយនាំក្សត្រខ្មែរត្រឡប់មកស្រុកឡាវវិញ ដើម្បីលើកបន្តុបលើរាជបល្ល័ង្កដែលទំនេរ

# រាជវង្សអឺរ៉ុប

- ពួកគាត់ត្រូវបំពេញបេសកកម្មសុំជំនួយអេស្ប៉ាញ នៅម៉ានីល ក្រោយឆ្នាំ១៥៨៧ ដើម្បីការពារលង្វែកពីការវាយលុករបស់អយុធ្យា
- ពួកគាត់ត្រូវសៀមចាប់បានពីសមុទ្ទ យកទៅឃុំទុកចោលនៅអយុធ្យា
- ក្រោយនរេសួនឈ្នះលង្វែក ត្រូវការអ្នកបកប្រែភាសាអេស្ប៉ាញ និងប៉រទុយហ្គេ ទើបដោះលែងគាត់ឱ្យធ្វើជាអ្នកបកប្រែឱ្យរាជទូតសៀម
- ពួកគាត់ដណ្តើមកាន់កាប់នាវាទូតសៀមបាន ក៏ប្រញាប់ស្រូតទៅក្រុងម៉ានីល តែចៅហ្វាយក្រុងម៉ានីលបដិសេធ មិនព្រមជួយ ទោះបីព្រះរាជាខ្មែរសន្យាប្រែមកកាន់គ្រីស្តសាសនាក្តី

# រាជវង្សក្សត្រអីវ៉ុប

- មិនបានដឹងពីការបែកបាក់លង្វែកនៅឆ្នាំ១៥៩៣_៩៤នោះទេព្រោះ
- ពួកគេត្រឡប់មកដល់លង្វែកទើបដឹងថាគ្រួសារព្រះបាទសត្ថាភៀសព្រះកាយទៅឡាវ ទើបបន្តទៅតាម
- ពេលធ្វើដំណើរឡើងតាមដងទន្លេមេគង្គ ពួកគាត់មានទំនាស់ជាមួយសហគមន៍ជំនួញចិន
- ទើបសុំកិច្ចអន្តរាគមន៍ ពីព្រះបាទរាមាជើងព្រៃ ដែលគង់នៅរាជវាំងស្រីសន្ធរ តែព្រះអង្គបដិសេធ ទើបអ្នកប្រយុទ្ធទាំងពីរនាំបក្សពួកខ្លួនវាយប្រហារផ្តក់សម្លាប់ព្រះអង្គទាំងកណ្តាលរាត្រី នៅឆ្នាំ១៥៩៦៕

# រាជវង្សក្សត្រអីវ៉ុប

- ចំណែកឯកសាររបស់លោកឧកញ៉ាវាំងជួន ថានៅឆ្នាំ១៥៩៦វីស និងវ៉េឡូសូ ទើបតែត្រឡប់មកពីស្រុកកំណើតរបស់ខ្លួនវិញ៕
- បន្ទាប់មក ពួកគាត់ស្រូតដំណើរឡើងទៅប្រទេសឡាវ តែទៅដល់ត្រឹមខេត្តស្ទឹងត្រែង ក៏បានជួបព្រះអង្គតន់ និងដឹងពីមរណភាពរបស់ព្រះបាទសត្ថា និងជ័យជេដ្ឋាជាបុត្រា ទើបពួកគាត់យាងព្រះអង្គតន់ ឱ្យមកសោយរាជ្យនៅស្រុកស្រីសន្ធរជំនួសរាមាជើងព្រៃវិញ៕

# ការស្នើសុំជំនួយអេស្ប៉ាញ

- កាលពីឆ្នាំ១៥៩១-២ ព្រះសត្ថាទី១ ឬជយជេដ្ឋាទី១ បានបញ្ជូនផឡូស្សូបំពេញបេសកកម្មការទូតទៅកាន់ម៉ានីលជាមួយកប៉ាល់ទំនិញ២ ធ្វើជាបណ្ណាការដល់ចៅហ្វាយក្រុងម៉ានីល និងការសន្យាកាន់សាសនាកាតូលិក
- ចៅក្រុងម៉ានីលទទួលយកបណ្ណាការ២កប៉ាល់នោះ និងចំណងមិត្តភាពជាមួយកម្ពុជា តែបដិសេធរាល់អន្តរាគមន៍ជួយការពារកម្ពុជាពីការវាយប្រហាររបស់អយុធ្យា
- ផឡូស្សូនាំលិខិតចងមិត្ត១សន្លឹកវិលមកវិញ ចំពេលសៀមពង្រាយសំពៅល្បាតក្នុងសមុទ្រ ពេលគេចាប់ផ្ដើមវាយលង្វែកសារជាថ្មី ទើបទ័ពសៀមចាប់គាត់បានយកទៅដាក់គុកនៅអយុធ្យា

# ព្រះមហាក្សត្រល្បីល្បាញទាំងពីរអង្គ

## ទី១- ព្រះបាទអង្គចន្ទ ឬ ចន្ទរាជា

- មិនចុះញ៉មជាមួយអយុធ្យា ដែលព្រះអង្គធ្លាប់ជ្រកកោននយោបាយ
- មានឆន្ទៈមោះមុត និងស្មារតីម្ចាស់ការ ជឿជាក់លើសមត្ថភាពខ្លួនឯង
- មានមោទនភាពជាឥស្សរបុគ្គល
- មានព្រះរាជគំនិតជឿនលឿន ទទួលយកអ្វីៗទំនើប
- គ្រប់គ្រងប្រទេសដោយប្រកាន់ច្បាប់/ធម៌

# ព្រះមហាក្សត្រល្បីល្បាញទាំងពីរអង្គ

## ទី២-ព្រះចៅនរេសួរ

- ជាស្តេចសឹកដ៏ក្លៀវក្លា
- មានស្មារតីជាស្តេចមហាប្រទេស
- មានស្មារតីឥស្សរភាព
- ធ្វើឱ្យអយុធ្យាព្រមនៅចំណុះព្រះអង្គ (សន្ធិសញ្ញាមិត្តភាព!)

## ១. សៀមវាយលង្វែកលើកទី១

- បន្ទាប់ពីគេដោះខ្លួនរួចពីចំណុះភូមា សៀមលើកទ័ពវាយលង្វែក ដើម្បី
- ដោះខ្លួនពីចំណុះខ្មែរ, ធ្វើជាអធិរាជលើខ្មែរវិញ,
- ផលប្រយោជន៍ពាណិជ្ជកម្មនៅតាមដងទន្លេសាប ដែលប្រកួតប្រជែងជាមួយអយុធ្យា
- ឆក់ប្លន់ ប្រមូលជ័យភ័ណ្ឌ និងកងកម្លាំងពីខ្មែរ
- ស្តារមុខមាត់អយុធ្យាដែលបានធ្លាក់ចុះប្រមាណកន្លះសតវត្សរ៍មុន
- លើកទ័ពដណ្តើមកាន់កាប់លង្វែកនៅឆ្នាំ១៥៨៧ មិនបានសម្រេច
- តាមពង្សាវតារអយុធ្យាថា ស្តេចនរេសួនបានបាចដុំប្រាក់ចូលរបងដើមឫស្សីរស់នៅជុំវិញ បន្ទាយ ដើម្បីបញ្ឆោតឱ្យខ្មែរឆ្ការព្រៃឫស្សីរើសយកដុំប្រាក់ទាំងនោះ ដែលពង្សាវតារខ្មែរ ច្រឡំសរសេរថា ប្រាក់ដួង នៅសតវត្សរ៍ទី១៩ ព្រោះតែការធ្វេសប្រហែស

សិលាចារឹកវត្តរំលកK.27



- នរេសួន លើកទ័ពមកវាយលង្វែកនៅឆ្នាំ១៥៨៧
- គ្រួសាររាជវង្សរត់ភៀសខ្លួនមកនៅម្តុំវត្តរំលក

# ការបែកបាក់នយោបាយ

- ក្តីប្រាថ្នាលើកបុត្រានៅវ័យកុមារឱ្យឡើងសោយរាជ្យរបស់ព្រះបាទជយជេដ្ឋាទី១ ប្រហែលជាហេតុចម្បងនាំឱ្យមានការបែកបាក់គ្នា
- អាចពួកមន្ត្រីបែកសាមគ្គីភាព និងបាក់ទឹកចិត្តក្នុងការប្រឹងប្រែងការពាររាជការ
- ពួកគេអាចយល់ថា ព្រះមហាក្សត្រគិតគូតែប្រយោជន៍គ្រួសារធំជាងអាយុជីវិតប្រទេស
- ជយជេដ្ឋាទី១ ចំណាយពេលយ៉ាងយូរនៅតំបន់អង្គរជាមួយរាជបុត្រាទារកមួយអង្គ
- ចំណែកស្រីសុរិយោពម៌ នៅលង្វែក ឬចតុមុខ អាចជាសញ្ញាមួយនៃការបែកបាក់គ្នាស្រេចហើយមុនពេលសៀមវាយកាន់កាប់លង្វែក

## ២. វិបត្តិក្រោយសង្គ្រាម

ក្រោយសង្គ្រាមដណ្តើមលង្វែកមិនសម្រេច ហើយនរេសួនដកថយ

- ការបែកបាក់សាមគ្គីភាពធ្ងន់ធ្ងរកើតឡើង
- កម្លាំងពិត សរុបរបស់ប្រទេសបានធ្លាក់ចុះ
- ប្រាក់ដួង?ក្នុងពង្សាវតារខ្មែរ ឬ ដុំប្រាក់ បើតាមការអះអាងនៃពង្សាវតារអយុធ្យា
- មានចារបុរស២នាក់របស់អយុធ្យា ឈ្មោះ តិបញ្ញោ និងសុបញ្ញោ ចូលមកបំផ្លាញបារមី និងវត្ថុស័ក្តិសិទ្ធិរបស់ខ្មែរ (តាមជំនឿ)
- របងព្រៃឫស្សីក៏ធ្លុះធ្លាយ ចំណែកទេពរក្សអ្នកតានិងព្រះស័ក្តិសិទ្ធិក៏ត្រូវបំផ្លាញ(បង្អែកធន្ទះនិងស្មារតីខ្មែរជាប្រពៃណី)

**ព្រះនាមពេញរបស់ព្រះបាទសត្ថាទី១ កាលឆ្នាំ១៥៧៩គ.ស.**







**កំណើតមុន្ត្រាច្បាប់របស់ព្រះបាទជ័យជេដ្ឋាទី១ ឬ សត្ថាទី១ ដែលមា នបញ្ជាក់នាមថា សំតេចបរមរាជាធិរាជ នៅឆ្នាំ១៥០១សកៈ ឬ ១៥៧៩គ.ស.**





## ការងាររបស់ចារបុរសសៀមអយុធ្យាទាំងពីរនាក់

- បន្សាបបារមី សិល្បសាស្ត្ររបស់ទេពរក្សានគរ
- ម្នាក់ដាក់អំពើធ្មប់ ម្នាក់ជាអ្នកដោះអំពើ
- ល្បិចបំផ្លាញព្រះពុទ្ធរូបត្រឡែងកែងដោយជោគជ័យ
- ដោយឆ្លៀតឱកាសដោះអំពើអគ្គមហេសីនៃព្រះជយជេដ្ឋាទី១ ប្រាប់ស្តេចថា មកពីបារមីព្រះធ្វើឱ្យព្រះមហេសីឈឺ។ ដំណោះស្រាយ ត្រូវបំផ្លាញព្រះចោល
- ប្រជារាស្ត្រកាន់តែអស់ជំនឿលើកាយវិការរំលាយព្រះរបស់ស្តេច
- ចារបុរសម្នាក់នៅជិតវត្តព្រះឥន្ទទេពក្នុងបន្ទាយរាជវាំង អាចបន្លំខ្លួនស្លង់កាំភ្លើងធំ លើសើនបន្ទាយលង្វែកទាំង១៦ដើមបានសម្រេច



- តើសម្តេចព្រះរាជមុនីបពិត្រនៅឆ្នាំ១៥៨៣ មកពីអយុធ្យា ដើរទេស និងធ្វើបុណ្យបិតព្រះជាច្រើនបូជនីយដ្ឋាននេះ ជាចារបុរសរបស់អយុធ្យា ទេដឹង?



- សិលាចារឹកភ្នំបាខែងK.465/K.285ដែលចារឹកដោយព្រះរាជមុនីបពិត្រ។ លោករៀបរាប់អំពីការធ្វើបុណ្យបិតព្រះបាក់បែកនៅភ្នំព្រះរាជទ្រព្យ និងនៅភ្នំបាខែង ដែលសម្រេចទាំងអស់បានរាប់សិបអង្គ និងលាបពណ៌ព្រះពុទ្ធរូបទាំងនោះ ព្រមទាំងពាក្យពេចន៍ឧទ្ទិសកុសល

**នេះជាសិលាចារឹកអក្សរខ្មែរជាភាសាថៃរបស់សម្តេចព្រះរាជមុនីបពិត្រនៅភ្នំគូលែនស្តីពីការធ្វើបុណ្យបិតព្រះរបស់ព្រះអង្គនៅទីនោះ និងនៅប្រាសាទអង្គរវត្ត ដែលលោកបានចូលគាល់ស្តេច។**
**តើព្រះអង្គអាចជាចារបុរសរបស់អយុធ្យាដែរឬទេ?**



Partie gauche K 1006 Partie droite

# ដំណោះស្រាយ

- កាលពីឆ្នាំ១៥៩១-២ ព្រះសត្ថាទី១ ឬជយជេដ្ឋាទី១ បានបញ្ជូនផឡូស្សូបំពេញបេសកកម្មការទូតទៅកាន់ម៉ានីលជាមួយកប៉ាល់ទំនិញ២ ធ្វើជាបណ្ណាការដល់ចៅហ្វាយក្រុងម៉ានីល និងការសន្យាកាន់សាសនាកាតូលិក
- ចៅក្រុងម៉ានីលទទួលយកបណ្ណាការ២កប៉ាល់នោះ និងចំណងមិត្តភាពជាមួយកម្ពុជា តែបដិសេធរាល់អន្តរាគមន៍ជួយការពារកម្ពុជាពីការវាយប្រហាររបស់អយុធ្យា
- ផឡូស្សូនាំលិខិតចងមិត្ត១សន្លឹកវិលមកវិញ ចំពេលសៀមពង្រាយសំពៅល្បាតក្នុងសមុទ្រពេលគេចាប់ផ្តើមវាយលង្វែកសារជាថ្មី ទើបទ័ពសៀមចាប់គាត់បានយកទៅដាក់គុកនៅអយុធ្យា
- ព្រះអង្គសន្យាកាន់សាសនាកាតូលិក បើសិនអេស្ប៉ាញជួយការពារលង្វែកបានគង់វង្ស

# ការវាយប្រហារលង្វែកលើកទី២

- ស្រីសុរិយោពម៌ ការពារសៀមវាយលុកលង្វែកនៅបន្ទាយពោធិសាត់
- ជយជេដ្ឋាទី១ ត្រៀមនៅលង្វែក
- ស្រីសុរិយោពម៌ចាញ់ដៃសៀម ដកទ័ពថយ
- ថយមកការពារបន្ទាយលង្វែកបានបីខែ
- ជយជេដ្ឋាទី១ និងរាជទាយាទ ភៀសខ្លួនទៅស្រីសន្ធរ រួចទៅឡាវ
- ស្រីសុរិយោពម៌ នៅការពារបន្ទាយរហូត សៀមវាយយកបាន និងចាប់យកជាឈ្លើយសឹក

# ព្រះឧបរាជស្រីសុរិយោពណ៌

- ការពារសៀមវាយលុកលង្វែកនៅបន្ទាយពោធិសាត់
- ចាញ់ដៃសៀម ដកទ័ពថយ
- ថយមកការពារបន្ទាយលង្វែកបានបីខែ
- ចុងក្រោយស្ដេចនរេសួន ចាប់ព្រះអង្គជាឈ្លើយសឹកបាន និង បញ្ជូនទៅបង្ខាំងទុកនៅអយុធ្យា

# ព្រះបាទជ័យជេដ្ឋាទី១/សត្ថាទី១

- រត់ភៀសព្រះកាយទៅស្រុកឡាវជាមួយរាជបុត្រា
- សានអានតូនីញ៉ូសរសេរនៅឆ្នាំ១៦០៣ ថាព្រះអង្គបានបាចកាក់មាសយ៉ាងច្រើនពង្រាយតាមផ្លូវ ដើម្បីគេចពីការតាមចាប់របស់កងទ័ពសៀម ដោយធ្វើឱ្យពួកគេ ចំណាយពេលរើសកាក់មាសមានតម្លៃទាំងនោះ
- ព្រះអង្គបានទៅជ្រកកោននយោបាយនៅវៀងច័ន្ទ តែបុត្រាគង់នៅស្ទឹងត្រែង
- មួយឆ្នាំក្រោយមក រាមាជើងព្រៃ ដែលជាព្រះញាតិវង្ស បានរំដោះលង្វែកពីសៀម

## ទិបត្តិក្រោយបែកធាក់

### ១.១. ព្រះបាទរាមាជើងព្រៃ និងអំណាចផុយស្រួយ

- https://www.rfa.org/khmer/news/history/king-rama-choeung-prey-12162014020301.html
- អំណាចរបស់គាត់នៅផុយស្រួយ
- អង្គរក្សអ៊ីរ៉ុប ប្រមាណជាង២០នាក់ ក៏អាចសម្លាប់ព្រះអង្គបានដែរ
- ១២មេសា១៥៩៦ គឺចំពេលចូលឆ្នាំខ្មែរ

### ១.២. ការចាត់ចែងនយោបាយរបស់អតីតមេអង្គរក្សអ៊ីរ៉ុប

- https://www.rfa.org/khmer/news/history/king-ponhea-ton-12232014025101.html
- ពញាតន់ ត្រូវបាននាំពីស្ទឹងត្រែងយកមកសោយរាជនៅប៉ាសាន វត្តស៊ីធរ
- ស្ដេចសុំជំនួយអេស្ប៉ាញ និងអនុញ្ញាតឱ្យផ្សាយគ្រីស្តសាសនាក្រោមព្រះរាជូបត្ថម្ភ
- ចាម្បជ្វានៅត្បូងឃ្មុំបះបោរ
- ជ្វានៅចតុមុខបះបោរ
- អង្គរក្សអ៊ីរ៉ុប ក្លាយជាស្ដេចត្រាញ់ខេត្តបាភ្នំ និងទ្រាំង(ប្រហែលព្រះត្រពាំង)

# បរមរាជា(ទី៥) រាមាធិបតីពញាតន់១៥៩៧-១៥៩៩

- ព្រះអង្គតន់សោយរាជ្យនៅឆ្នាំ១៥៩៧ក្នុងព្រជន្មប្រហែល១៨ឆ្នាំ(កើតឆ្នាំ១៥៧៩)
- ព្រះនាម ព្រះបាទសម្តេចព្រះរាជឱង្ការបរមរាជារាមាធិបតី គង់នៅរាជវាំងស្រីសន្ធរ(វត្តស៊ីធរ)បាន៣ឆ្នាំ។
- មិនសូវយកចិត្តទុកដាក់ចំពោះកិច្ចការរដ្ឋ បណ្តែតបណ្តាយតាមតែមន្ត្រីឡេមឡឹមផ្តុំត្រចៀក
- ប្រព្រឹត្តិតែល្បែងភ្នាល់ និងទាក់សត្វព្រៃ
- បើតាមលោក ម៉ក់ភឺន(១៩៩៥៖៦៤-៦៥)ថា មានម៉ាឡេបះបោរសំខាន់ពីរនាក់ គឺ ប៉ោរ៉ាត និង

លក្ស្មណា តែតាមប្រភពអឺរ៉ុបថា Ocuna Lacasamana និង Cancona

- ពង្សាវតារភាគច្រើនថា ប៉ោរាតជាចាម និងលក្ស្មណាជាម៉ាឡេ ឬជ្វា (មេទ័ពជើងទឹកម៉ាឡេ)

## ១.៣. ការបះបោររបស់ចាមប្រឆាំងព្រះអង្គតន់

- មានការបកស្រាយ២យ៉ាង៖
- ទី១៖ ត្រូវបានស្តេចបង្ក្រាប ទើបសារភាព និងសុំចុះចូល។ ស្តេចយល់ព្រម និងទទួលការយាងទៅធ្វើអធិបតីក្នុងពិធីថ្វាយភក្តីភាពនៅពោធិជើងខាង ដោយមានរាត្រីសមោសរផង។ ពេលយប់ទាហានហូងសប្បាយ ភ្លឹក ភ្លេចខ្លួន ប៉ោរ៉ាត និងលក្ស្មីណាបានឱកាសវាយលុកសម្លាប់ស្តេច ហើយអង្គរក្សស្តេចក៏សម្លាប់អ្នកទាំង២នាក់នេះវិញ។
- ទី២៖ មានជម្លោះរបស់ពួកជ្វាជាមួយពួកអេស្ប៉ាញ៉ុលទាហាន និងបព្វជិត(ដែលស្វែងរកអ្នកមកកម្ពុជាមួយក្រុមមុនតែខ្លួនបាត់ខ្លួន)នៅចតុមុខ។ ស្តេចបញ្ជាឲ្យផ្សេស្វ និងវីស្វមកជួយសម្រុះសម្រួល តែត្រូវជ្វាសម្លាប់ចោលអស់។ ស្តេចខ្វាល់ក៏លើកទ័ពមកបង្ក្រាបដោយអង្គឯង ក៏ត្រូវពួកជ្វាសម្លាប់ចោលទៀត។

**អំពើអនាចាររបស់ព្រះអន្ទអន**

- https://www.rfa.org/khmer/news/history/The-Kings-Ponhea-On-and-Chaovea-Ponhea-Nhom-01062015005520.html
- នៅក្មេងជក់លេងល្បែងច្រើន
- ចាប់បង្ខំប្រពន្ធចៅហ្វាយស្រុក ឈ្មោះ ពញាថី នៅព្រៃទ្រមាក់

**អំពើអនាចាររបស់ព្រះអន្ទអន**

- មិនសូវយកព្រះទ័យទុកដាក់ក្នុងកិច្ចការព្រះនគរ បណ្តែតបណ្តោយឱ្យតែមន្ត្រីធ្វើការរាជការស្តាប់តាមតែមន្ត្រីដែលស្លក្រាបបង្គំទូលនោះ ៕
- មានចៅហ្វាយខេត្តជាច្រើនមិនចុះចូល
- ប្រព្រឹត្តិតែអំពើអបាយមុខ និងល្បែងភ្នាល់
- រឹបយកភរិយារបស់មន្ត្រីខ្លួន ដែលនាំដល់ការវិនាសខ្លួន
- ប្រហែលឆ្នាំ១៥៩៩ មន្ត្រីឈឺចិត្តរូបនោះចូលរួមជាមួយមេបះបោរនាមកែវព្រះភ្លើងសម្លាប់ព្រះអង្គចោលដោយងាយ

**ល្បែងភ្នាល់ដោយព្រះអង្គឡោម**

- មិនសូវយកព្រះទ័យទុកដាក់ក្នុងកិច្ចការព្រះនគរ បណ្តែតបណ្តោយឱ្យតែមន្ត្រីធ្វើការរាជការស្តាប់តាមតែមន្ត្រីដែលស្ថក្រោមបង្គំទូលនោះ ៕
- មានចៅហ្វាយខេត្តជាច្រើនមិនចុះចូល
- ប្រព្រឹត្តិតែអំពើអបាយមុខ និងល្បែងភ្នាល់
- ព្រះមាតានិងមន្ត្រីសំខាន់ៗនាំគ្នាសរសេរសំបុត្រសុំស្តេចសៀមដោះលែងព្រះបាទស្រីសុរិយោពម៌មកសោយរាជ្យជំនួសវិញ

# មេរៀនទី៥៖

# កម្ពុជាសម័យខុដុង្គ

ដោយ បណ្ឌិត ទង់ សុធារ៉ា
ដេប៉ាតឺម៉ង់ប្រវត្តិវិទ្យា
សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

# បុច្ឆនសិក្សា

- ១. តើព្រះបាទស្រីសុរិយោពណ៌បង្រួបបង្រួមប្រទេសដូចម្ដេច?
- ២. តើរាជវង្សខ្មែរសម័យឧដុង្គ បែកបាក់គ្នាដោយសារហេតុផលដូចម្ដេចខ្លះ?
- ៣. តើកម្ពុជាធ្លាក់ក្រោមអំណាចសៀម និងយួនដូចម្ដេចខ្លះ?
- ៤. តើស្ដេចអង្គណាខ្លះ បានព្យាយាមបង្រួបបង្រួមប្រទេស? និងប្រើវិធីដូចម្ដេចខ្លះ?
- ៥. តើសៀម និងយួនយល់ព្រមលើកព្រះបាទអង្គដួងឱ្យឡើងសោយរាជ្យ ក្រោមហេតុផលដូចម្ដេចខ្លះ?
- ៦. តើខេត្តខ្មែរឈ្មោះអ្វីខ្លះ ត្រូវសៀម និងយួនលេបយក នៅសតវត្សរ៍ទី១៨ និងភាគទី១នៃសតវត្សរ៍ទី១៩?
- ៧. តើអ្នកមានដំណោះស្រាយដូចម្ដេច បើសិនអ្នកជាមេដឹកនាំប្រទេសនៅពេលនោះ?

# ការបង្រួបបង្រួមប្រទេសដោយស្រីសុរិយោពណ៌

- ព្រះបាទស្រីសុរិយោពណ៌ចាប់ផ្ដើមបង្ក្រាបចៅហ្វាយខេត្តដែលដឹកនាំដែនដីដោយឯករាជ្យជាបន្តបន្ទាប់
- បង្ក្រាប និងសម្លាប់ មេបះបោរជាស្ដេចពញាញោម ដែលធ្លាប់ជាស្ដេចប៉ោឡៃ មុនព្រះអង្គមកដល់
- ព្រះអង្គបានមេទ័ពល្បីពីរនាក់បម្រើ គឺតេជោមាស និងតេជោយ៉ត ជាចៅហ្វាយខេត្តកំពង់ស្វាយ
- ព្រះអង្គស្នើសុំស្ដេចសៀមដោះលែងព្រះជយជេដ្ឋាទី២ មកជួយព្រះអង្គធ្វើសង្គ្រាម តែសៀមបែរជាដោះលែងព្រះឧទយរាជា ជាព្រះអនុជមកវិញ នៅរវាងឆ្នាំ១៦០៥
- ព្រះឧទយរាជាបង្ក្រាបបានអាណាខេត្តជាច្រើនក្រោមបញ្ជាព្រះស្រីសុរិយោពណ៌
- ព្រះអង្គតាំងរាជវាំងនៅកោះស្លាកែត ច្បារអំពៅ និងនៅបន្ទាយធំ ល្វាឯម, អរិយក្សត្រ
- មកដល់ឆ្នាំ១៦១២ ព្រះអង្គបានសម្រេចក្នុងការបង្រួបបង្រួមប្រទេស
- ព្រះអង្គបានរៀបចំច្បាប់សម្រាប់រាជការឡើងវិញ




## បច្ចុប្បន្នភាពអតីតទីក្រុងឧដុង្គ



## បច្ចុប្បន្នភាពអតីតទីក្រុងឧដុង្គ




## ព្រែកក្ដាមក្នុងអតីតទីក្រុងឧដុង្គ



# ព្រែកក្តាមក្នុងអតីតនីក្រុងឧដុង្គ








# ប្រភេទនៃវិបត្តិរាជវង្សវ័យខ្មែរជារួម

- ១_វិបត្តិរាជវង្សានុវង្ស
- ជម្លោះរវាងមា និងក្មួយ (ឧទយរាជា≠ធម្មរាជា, ឧទយរាជា≠រាមាធិបតីចន្ទ)
- បងប្អូនជីដូនមួយកាប់សម្លាប់ គ្នា (រាមាធិបតីចន្ទ≠អង្គសូរ, អង្គតន់, អង្គឥម)
- កូនប្រសារធ្វើគត់ឪពុកក្មេក (ស្រីជយជេដ្ឋ បុត្រានៃអង្គនន់ ≠ អង្គសូរ ជាឪក្មេក/ឪពុកមា)
- មហេសី(មីង)សម្លាប់ស្វាមី (ក្មួយ) (អង្គឡី≠ ស្រីជយជេដ្ឋ)
- ជម្លោះរវាងក្មួយ នឹងឪពុកមា (អង្គជី បុត្រានៃអង្គសូរ ≠ អង្គតន់ ជាឪពុកមា មានទ័ពយួនជួយ)
- ជម្លោះរវាងបងប្អូនជីដូនមួយ(អង្គសូរ បុត្រានៃអង្គសូរ≠អង្គនន់ បុត្រានៃអង្គឥម មានយួនជួយ)
- ជម្លោះរវាងបងថ្លៃនិងប្អូនថ្លៃ(រវាងជីទួតមួយ)(អង្គឥមបុត្រានៃអង្គនន់≠ធម្មរាជាទី៣បុត្រាអង្គសូរ)
- ជម្លោះរវាងបងប្អូនជីដូនមួយ (សត្ថា អង្គជីបុត្រានៃអង្គឥម≠បុត្រារបស់ធម្មរាជាទី៣និងអង្គទង)

# ប្រភេទនៃវិបត្តរាជវង្សដ៏យូរអង្វែងជារួម

- ជម្លោះរវាងបងប្អូនបង្កើត (អង្គហ៊ីង សម្លាប់ធម្មរាជាទី៤ជាបងប្រុស)
- ជម្លោះរវាងចៅជយជេដ្ឋាទី៣(អង្គហ៊ីង+អង្គដួង បុត្រានៃធម្មរាជាទី៣) និងចៅទួតព្រះអង្គយ៉ង និងជាចៅព្រះអង្គទង (អង្គតន់ បុត្រានៃឧទយរាជាអង្គស្ងួរ និងមហាក្សត្រី ជាបុត្រីច្បងរបស់អង្គឥមកែវហ្វា)
- ជម្លោះរវាងជីលួតមួយ (អង្គតន់ បុត្រាអង្គស្ងួរ និងជាចៅលួតអង្គជី ≠ អង្គនន់ព្រះរាម បុត្រាព្រះជយជេដ្ឋាអង្គស្ងួន និងជាចៅទួតនៃជយជេដ្ឋាទី៣អង្គស្ងួរ ដែលជាប្អូនប្រុសរបស់ព្រះអង្គជី
- ជម្លោះបងប្អូនបង្កើត (អង្គចន្ទទី៣ ≠ អង្គស្ងួន និងអង្គឥម, ទាំងបីអង្គជាបុត្រាព្រះបាទអង្គអេង ជាចៅ ប្រះអង្គតន់)
- ជាសរុប៖ ជម្លោះរវាងមា និងក្មួយ, បងប្អូនជីដូចមួយ, បងប្អូនបង្កើត, បងប្អូនជីទួតមួយ, បងប្អូនជីលួតមួយ

២_វប្បធម៌ពឹងប្រទេសជិតខាង ដើម្បីអំណាច

- ដើម្បីអំណាចត្រូវរត់ទៅពឹងសៀម ឬមួយរត់ទៅពឹងយួន ចំណែកបរទេស
- មានឱកាសមាសដើម្បីធ្វើអន្តរាគមន៍ និងទាញយកផលប្រយោជន៍
- គេមានបំណងដាក់បន្តុបស្តេចរណបរៀងខ្លួន នៅឱ្យរាជវង្សចូលរួមធ្វើចម្បាំងដណ្តើមអំណាចគ្នាក្នុងរវាង១០ ទៅ២០ឆ្នាំម្តង



## ការប្រជែងគ្នារបស់កូននិងចៅស្តេចស្រីសុរិយោពណ៌




## ការពឹងពាក់បរទេស

- ក្នុងរជ្ជកាលជម្លោះបីមុំពាក់កណ្តាលទី២ស. វ. ទី១៥ស្រីរាជា_ស្រីសុរិយោទ័យ_ធម្មរាជា ÷ពឹងអយុធ្យា ដើម្បីយកឈ្នះតែម្នាក់ឯង—អយុធ្យាមានឱកាសចិញ្ចឹម និងប្រើប្រាស់បុត្រាស្រីរាជានាមពញាអុង ដើម្បីគម្រាមស្តេចខ្មែរ
- ក្នុងសតវត្សរ៍ទី១៦ ជម្លោះស្តេចទី១៖ ធម្មរាជាព្រះរាជសំភារ(ពញាតូ) ដែលពឹងផ្អែកមេទ័ពជនជាតិចិន ប្រឆាំងនឹងស្តេចទី២៖ ឧទយរាជាដ៏មានអំណាចធំជាង ដែលពឹងផ្អែកលើកងទ័ពប៉រទុយហ្គេ(ស៊ីឈ្នួល)ជាអង្គរក្ស
- បន្ទាប់មកការសងសឹករបស់បុត្រាឧទយរាជា—ចំពោះរាមាធិបតីអង្គចន្ទ មានការពឹងពាក់កងទ័ពយួនដើម្បីយកឈ្នះ នាំឱ្យយួនបានឱកាសចង់លេបយកទឹកដីខ្មែរតែម្តង—ពន្យារការទាមទារយកមកវិញនូវទឹកដីព្រៃនគរ ដែលយួនបានសន្យាខ្ចីតែប្រាំឆ្នាំពី១៦២៥?)




# ការពឹងពាក់បរទេស

- ព្រះអង្គនន់ ពឹងយួនមកជួយច្បាំងដណ្តើមអំណាចពីជយជេដ្ឋាទី៣
- ក្នុងរាជ្យសត្ថាអង្គជីបុត្រារបស់អង្គអឹម—ចៅអង្គនន់ ពឹងយួន ប្រឆាំងដៃគូម្ខាងទៀតពឹងគឺធម្មរាជាទី៣ និងបុត្រាអង្គអិម ពឹងសៀម
- អង្គនន់បុត្រអង្គស្ងួនពឹងសៀម វាយព្រះនារាយរាជាអង្គតន់ដែលពឹងយួន ចុងក្រោយលះបង់អំណាច
- អង្គអេង ជាបុត្រាទៅពឹងសៀម តាមការដឹកនាំរបស់មន្ត្រីឧកញ៉ាក្រឡាហោមប៉ុក
- អង្គចន្ទពឹងយួន—អង្គស្ងួន ពឹងសៀម
- អង្គម៉ី ត្រូវយួនបន្តុប_____ប្រជែងជាមួយអង្គដួង ដែលសៀមធានាជួយ

## ប្រហែលនេះជាការពិត ឥទីក្រុងឧដុង្គពេលនោះឈ្មោះ លង្វែក មែន។ ដោយសារ គេមិនទាន់ហៅ ឧដុង្គនៅឡើយ។ វាមិនមែនជាការយល់ច្រឡំថា លង្វែក នៅឆ្នាំ១៧៤៧នោះទេ។




## ប្លង់សំណង់សំខាន់ៗនៅតាមពាមជំនីក






# ជម្លោះគ្នាឯង ពេលសៀម និងយួនកំពុងមានវិបត្តិ

- អង្គអេង (១៧៧៩_១៧៩៦)_បុត្រអង្គតន់(សុគត១៧៧៧)_គ្រងរាជ្យពេលព្រះជន្ម៦វស្សា
- ព្រះអង្គ ក្រោមទំនុកបម្រុងរបស់ប៉ុក (ឧកញ៉ាវាំង«អធិវង្សា» ឡើងជា ឧកញ៉ាក្រឡាហោមប៉ុក នាំអង្គអេងទៅស្រុកសៀម ពេលមានមន្ត្រីបះបោរ ជាលើកទី២
- សួស/ស៊ូ «វិបុលរាជ»(រដ្ឋមន្ត្រីទ័ពជើងទឹក)
- មូ «ឧកញ៉ាវិស្ណុលោក» ចៅហ្វាយខេត្តបាសាក់ បន្ទាប់មកជា ចៅហ្វាទឡ្ហៈ(នាយករដ្ឋមន្ត្រី)
- ពាង «ឧកញ៉ាចក្រី»(រដ្ឋមន្ត្រីខាងសង្គ្រាម) _ទែន ឧកញ៉ាតេជោ _ចៅហ្វាយខេត្តកំពង់ស្វាយ
- ឧកញ៉ាយោមរាជ បែន នៅសៀម, ក្រោយមកសៀមសុំបែន ពីចៅហ្វាមូ ដែលសម្លាប់ព្រះអង្គនន់
- ឧកញ៉ាក្រឡាហោម ស៊ូ (ក្ដើ_បែន ដែលជាអតីតឧកញាយមរាជ)

# ជម្លោះផ្ទៃក្នុង ពេលសៀម និងយួនកំពុងមានឥទ្ធិពល

- ១៧៨០ក្បាតាក(ព្រះចៅតាក់ស៊ីន)ឱ្យលើកទ័ពសៀមពីរកង÷៧០០០នាក់វាយខ្មែរ
- ទ័ពខ្មែរបានជំនួយពីទ័ពអណ្ណាមមួយកងតូច«អុងជរម៉ា»ឧត្តមសេនីយ៍
- ឧកញ៉ាបែនត្រូវស្តេចសៀមលើកលែងទោស ឱ្យបរមនាមជាពញាអភ័យធិបេស
- ឧកញ៉ាស៊ូ ដែលមានជម្លោះប្រឆាំងមូពេលក្រោយ(១៧៨២)___ស៊ូ សុំបែនពីសៀមចូលមកស្រុកខ្មែរវិញ_ចាត់ការសម្លាប់នាយកមន្ត្រីមូ, (យូរក្រោយមកក៏ចាប់ ជំទាវឡង់ ជាម្តាយមូ+ពាង)
- បែន ក្រោយមកលួចវាយលុកសម្លាប់ស៊ូចោលទាំងគ្រួសារ នៅឆ្នាំ១៧៩០ រួចហើយប្រកាសខ្លួនជាសម្តេចចៅហ្វ៊ា (នាយករដ្ឋមន្ត្រី)បន្ទាប់មក
- បែន មិនហ៊ានសម្លាប់ទែន ជាប្អូនរបស់ មូ និងពាងទេ គ្រាន់តែចាប់បញ្ជូនទៅបាងកក ហើយគាត់ត្រូវព្រះចៅរាមទី១ ដោះលែងនិងលើកជារដ្ឋមន្ត្រីជាន់ខ្ពស់ ដង្ហែព្រះអង្គអេងមកឧដុង្គវិញនៅឆ្នាំ១៧៩៥
- សៀមលើកបែនជាចៅហ្វាយខេត្ត(ហ្លួមឿង)បាត់ដំបង១៧៩១÷ស្តេចត្រាញ់ខេត្តពាយព្យ



# អនិស្សរភាពរបស់ព្រះមហាក្សត្រ

- ការអភិសេកនៅបរទេស
- _ ១៧៩៥ រៀបអភិសេកអង្គអេង(២០ ឬ ២២វស្សា)នៅបាងកក
- * ការអភិសេកព្រះរាជានៅឯបាងកករបស់សៀមដូច្នេះ ការបញ្ជាក់ថា កម្ពុជាទទួលស្គាល់ថាខ្លួនជានគរចំណុះ ហើយទទួលការគ្រប់គ្រងពីសៀម
- គឺក្នុងនាមជាអ្នកការពារនេះឯងក្រោយមកសៀមបញ្ជូនអង្គអេងមកឧដុង្គ
- * បែន_នាំខេត្តភាគខាងជើងបាត់ដំបង_មង្គលបុរី សិរីសោភ័ណ(មហានគរ ព្រំទេព និងម្លូព្រៃ)+ កូរ៉ាត ឡើងទៅសៀម គឺត្រូវថ្វាយស្ឫយដល់សៀម ពីឆ្នាំ១៧៩៥_(១៩០៧)
- * អង្គអេងសុគត ១៧៩៦(២៥វស្សា_២៦ វស្សា)

# អនិស្សរភាពរបស់ព្រះមហាក្សត្រ

- ព្រះអង្គច័ន្ទ(១៨០៦_១៨៣៤)_បុត្រអង្គអេង
- សៀមអភិសេកព្រះជន្ម១៦វស្សា—លើកទី២ ដែលស្តេចសៀមបង្ហាញឱ្យឃើញអំពីអធិរាជភាពរបស់គេមកលើកម្ពុជា។ តាមផ្លូវចៅហ្វ៊ាបែន ថ្វាយកូនស្រីធ្វើជាព្រះជាយា
- មានការជំទាស់ពីអណ្ណាម ព្រមអភិសេកនៅបាងកក_ព្រះរាជាកម្ពុជាចំណុះសៀម ត្រូវចំណុះអណ្ណាម—លើកស ួយសារអាករថ្វាយជាទៀងទាត់(ដំរីឈ្មោលកំពស់៥ហត្ថ២ក្បាល+កុយរមាស២+ភ្លុកដំរី៣គូ+ក្រវាញ+ក្រមួនម្រ័ក្សណ៍)
- ព្រះអង្គទទួលស្គាល់អធិរាជអណ្ណាម_ មិនសម្បាយចិត្តពីសៀមទេ

# អនិស្សរភាពរបស់ព្រះមហាក្សត្រ

- សៀម មិនព្រម_កម្ពុជាមានអធិរាជពីរទេ—ត្រូវចំណុះសៀម១គត់_មានតែសៀមទេដែលបានអភិសេកស្តេចខ្មែរ
- ១៨១០ដើម្បីបង្ហាញអធិរាជភាព—ក្រោយពីធ្វើបុណ្យសពស្តេចជាបិតារួច ស្តេចសៀមថ្មីប្រកាសយ៉ាងឱឡារិកតម្លើងឋានៈអ្នកអង្គម្ចាស់អង្គស្ងួន+ឥម(អនុជព្រះរាជា)ឡើងជាឧភយោរាជ+ឧបរាជ ដោយមិនចាំបាច់ពិគ្រោះ ឬប្រាប់ព្រះរាជាខ្មែរជាមុនឡើយ
- ១៨១១អង្គឥម+ឌួង—កាន់រដ្ឋាភិបាលក្នុងឋានៈពាក់កណ្តាលជាខ្មែរ+សៀម_បាងកក ធ្វើអ្វីៗសំខាន់ៗត្រូវសុំយោបល់ណែនាំ ឬការយល់ព្រមពីសៀម ធ្វើសង្គ្រាមប្រឆាំងជាមួយអង្គច័ន្ទ ដែលការពារដោយទ័ពយួន

# អនិស្សរភាពរបស់ព្រះមហាក្សត្រ

- ១៨១៥ មានការអះអាងថា មានការចុះសន្ធិសញ្ញាសន្តិភាពខ្មែរ+សៀមមួយ ពុំបាននិយាយពីអំពីទឹកដីដែលសៀមទើបយកបានទេ
- ១៨១៥នេះដែរ មានការជីកព្រែកវិញតេ(ពង្សាវតារអណ្ណាម ថាជីកនៅឆ្នាំ១៨១៦)
- អង្គច័ន្ទសុគត១៨៣៤, យួនមិនលើកព្រះអង្គប៉ែន(ថៅថៅហ្វាបែន)ប្រឆាំងអណ្ណាម ទើបយួនលើកក្សត្រីអង្គម៉ី ឱ្យសោយរាជ្យ
- ព្រះអង្គអិម និងអង្គឌួង នៅក្នុងដៃសៀម ដែលត្រូវនាំមកស្រុកខ្មែរវិញ នៅបាត់ដំបង
- ១៨៤០ យួនបញ្ឆោតឱ្យអង្គអិម និងអង្គដួងចូលភ្នំពេញ ដើម្បីទទួលរាជភិសេកស្នងច័ន្ទ
- អង្គអិមចាញ់ឃោសនាក៏ចុះចូលយួន ហើយត្រូវយួនសម្លាប់ចោល តែអង្គដួងត្រូវរងកំហឹងសៀមដែលសង្ស័យថា ក្បត់គេដែរ ហើយនាំទៅឃុំទុកនៅបាងកក

# អនិស្សរភាពរបស់ព្រះមហាក្សត្រ

- ក្សត្រីអង្គមី (កើតពីអ្នកម្នាងក្រចាន់ និងព្រះអង្គច័ន្ទ(ទី៣) សោយរាជ្យក្នុងព្រះជន្ម២១
- ពុំមានអំណាចអ្វីធំដុំ, យួនបន្ទាបឋានៈព្រះនាងមកត្រឹមចៅហ្វាយខេត្តប៉ុណ្ណោះ
- មេទ័ពមន្ត្រីអណ្ណាម ១០៧នាក់នៅក្នុងរាជការ ជាអ្នកចាត់ការគ្រប់យ៉ាងជំនួសខ្មែរ
- សម័យកាលព្រះនាងនេះហើយ ដែលខេត្ត ស្រុករបស់ខ្មែរមានការផ្លាស់ប្តូរជាភាសាយួន
- ស្តេចធៀវទ្រីបញ្ជាដកទ័ពចេញពីខ្មែរ មេទ័ពយួនបានចរចាជាមួយសៀមនៅឆ្នាំ១៨៤៥ ហើយទាំងពីរយល់ព្រមឱ្យព្រះអង្គដួងសោយរាជ្យផ្លូវការនៅឆ្នាំ១៨៤៧ (សៀម÷ម៉ែ+យួន÷ឪ)
- ហេតុនោះហើយទើប ព្រះអង្គដួងលួចទាក់ទងជាមួយបារាំងពីឆ្នាំ១៨៥៣ និងសន្យាចុះសន្ធិសញ្ញាដាក់កម្ពុជាក្រោមការការពាររបស់បារាំងនៅឆ្នាំ១៨៥៥ តែត្រូវសៀមដឹងមុន ក៏ត្រូវបរាជ័យ

# ការគាបសង្កត់ និងបាត់បង់ដីសន្សឹមៗ

- ការអះអាងថា អាពាហ៍ពិពាហ៍ជយជេដ្ឋាទី២ និងអង្គចូវ រវាងចុងទសវត្សរ៍១៦១០ នាំឱ្យខ្មែរបាត់ដីកម្ពុជាក្រោម៖ មិនពិតទេ
- អគ្គមហេសីនេះត្រូវបានខេត្ត២ឡើងសួយ គឺកំពង់ស្រកាត្រី និងកំពង់ក្របី_រាជប្រទាន
- អង្គចូវ សុំឱ្យព្រះរាជានុគ្រោះឱ្យនិគមយួនចូលតាំងលំនៅធ្វើកសិកម្មនៅតំបន់ដីទំនេរ
- ១៦២៥ បានជួយសុំខ្ចីដីព្រៃនគរ៥ឆ្នាំ ដើម្បីតាំងបន្ទាយបង្ហាត់ទាហានត្រៀមវាយពួកចិន។
- កំពង់ផែព្រៃនគរគ្មានរាជការខ្មែរកាន់កាប់ ទើបអង្គចូវសុំដាក់ប៉ុស្តិ៍គយផ្ទាល់ខ្លួន
- តាមលោក ម៉ក់ ភឿន «ពុំមានវត្តមានវៀតណាមច្រើនទេនៅកម្ពុជា១៦៥០» ព្រោះពង្សាវតារពុំមានលើកពីដីគយនោះ_បារៀ(Baria) និង ដូនណៃ(Donnai)ខាងជើងហួសសៃហ្គននៅតែជាផ្នែកនៃដីកម្ពុជារហូតដល់ឆ្នាំ១៦៩០

# ការបាត់បង់ទឹកដីទៅខាងយួន

- ឯកសារខ្លះ នៅទសវត្សរ៍ ១៦៩០ យួនកាន់កាប់បារៀ, ដូនណៃ និងសៃហ្គន
- ខេត្តទី១ ដែលត្រូវបាត់គឺ បារៀ នៅគ.ស. ១៦៩៩
- រហូតមកដល់ ១៧៥៨ យួនបានមកតាំងនៅគ្រប់ខេត្តនៃដែនដីកម្ពុជាក្រោម
- ១៧៥៨ ដើម្បីសងគុណចំពោះជំនួយផ្សេងៗដែលយួនគាំទ្រក្នុងជម្លោះរវាងរាជវង្សានុវង្សខ្មែរកន្លងមក—សុខសាន្តជាមួយយួន អង្គតន់ទ្រង់លើកខេត្ត២ ព្រះត្រពាំង+ខេត្តឃ្លាំងខេត្តពីរចុងក្រោយឱ្យយួនតាំងនៅ
- យោងតាមពង្សាវតារ ក្នុងឆ្នាំ១៧៨៥ តែសឹនបានកាន់កាប់កម្ពុជាទាំងមូលលើកលែងតែសៀមរាប,បាត់ដំបង,និងពោធិសាត់ តែរយៈពេលខ្លីតែប៉ុណ្ណោះដកថយទៅវិញពេលគ្រួសារទ្រិញ ចុះខ្សោយ១៧៨០

# ការបាត់បង់ទឹកដីទៅខាងយួន

- រយៈពេល១៣៥ឆ្នាំ (១៦២៣_១៧៥៨)ខ្មែរបាត់បង់ទឹកដី ទំហំ ៦៤ ០០០គម២
- យួនផ្លាស់ឈ្មោះស្តេច និងមន្ត្រីខ្មែរ និងផ្លាស់ឈ្មោះប្រទេស ខេត្ត ស្រុករបស់ខ្មែរទៅយួន បង្រួមខេត្តខ្មែរពី៥៥ ទៅ៣៣វិញ ៕
- ១៨១៥ យួនបង្ខំឱ្យជីកព្រែកវិញតេ (ប្រវែង៥៣គ.ម. តភ្ជាប់មាត់ជ្រូកទៅនឹងសមុទ្រនៅតំបន់ពាម) ហាទៀង—ហាទៀន(កាត់តាមបណ្តោយព្រំដែនប្រទេសកម្ពុជា និងវៀតណាម(រាជអង្គច័ន្ទ)
- ព្រះរាជាអណ្ណាមបានសម្រេចប្តូរឈ្មោះខេត្ត ដោយបន្ថយចំនួនពី៥៦ មកត្រឹម៣៣វិញ(៤)

# តាមលោក អាដឹម៉ាដ៍ ឡឺក្លែរ «ប្រវត្តសាស្ត្រកម្ពុជា» យួនយកខេត្តខ្មែរជាច្រើនខេត្តនៅកម្ពុជាក្រោម ដោយឲ្យាន់ប្តូរទាំងឈ្មោះខេត្តទាំងនោះ

| ខេត្តព្រៃនគរ | ប្តូរទៅជា | **ខេត្ត យ៉ាឌិញ** |
|---|---|---|
| ខេត្តកំពង់ស្រកាត្រី | ប្តូរទៅជា | បៀនហ្វា |
| ខេត្ត ប៉ារីយ៉ា | | បាផៀ |
| ផ្សាររដែក | | សាដែក |
| ពោរលើ (ពល លាវ/ថាច់ប៉ាង/ហៅ ពោរលើ) | | បាក់លីវ |
| ទឹក ខ្មៅ (ជ្រោយ ខ្មែរ ) | | កាម៉ៅ |
| បាយឆៅ | | បាយ សៅ |
| ពាម មានជ័យ | | មីថាំង |
| ស្រុក ទ្រាំង | | សុកត្រាង |
| ពាមមេសែន | | ដូនណាយ/ង៉ាយ (ដាយង៉ាយ) |

| **កោះគង** | ប្តូរទៅជា | **ហ្គ័រ កុង** |
|---|---|---|
| កំពង់គោ | ប្តូរទៅជា | ទ្រៀង/ជឿងអាន (បច្ចុប្បន្ន តិន អាន) |
| រោងដំរី | | តៃនិញ |
| បន្ទិច | | បេន លុន |
| កោះត្រល់ (Malleret calls កោះ ស្រល់) | | ភូក្កុក |
| ពាមជើងកញ្ជើ | | កឹង យើ |
| ឈើទាលមួយ ដើម | | ធូយ៉ូវម៉ូត |
| បន្ទាយកោះក្របី | | ហុងង្វៀន |
| កំពង់កោះក្របី (សាយហ្គន) ឬ ថាច់ប៉ាង | ដើម្បីហ្វឹកហ្វឺនទាហាន | បេនង៉េ នេះហើយដែលស្តេចអណ្តាម ស្នើសុំខ្ចីរយ:ពេល៥ឆ្នាំ |
| ក្រមួនស | | រ៉ាច់យ៉ា |
| ព្រៃកប្បស្សី | | កាន់ថឺ |
| អូរម៉ែរ | | អុម៉ុន នៅក្នុង ស្រុកកិនថឺ |
| កំពូលមាស | | ប៊ិញធ្វៃ |
| មាត់ជ្រូក | | ចូវដុក |

| បារាំង | ប្តូរទៅជា | ឡុង ស្មៀង |
|---|---|---|
| ពាម ឬហៅថា ខេត្តមួងខាំ ដែរ | | ហាទៀង |
| ព្រះត្រពាំង | | ត្រាវិញ |
| កំពង់ឫស្សី | | បេនត្រែ |
| លង់ហោរ | | វីញឡុង |
| មេស (ស្មីធរ ) | | មីថ |






(DENSITÉ DU PEUPLEMENT KHMER EN 1945)
Ministère de l'Information du Cambodge (1962)

# ដែនដីបាត់បង់ទៅខាងសៀម

- ចាប់ផ្ដើមតាំងពីអយុធ្យាបង្កើតឡើងនៅរវាងពាក់កណ្ដាលស វ ទី១៤ ដូចជា នគរស្រីធម្មរាជ, ប៉ាត្តានី, រយ៉ង
- ខេត្តដែលបាត់បង់ទៅខាងលិចនៅអំឡុងចុងស វ ទី១៦ដល់ស វ ទី១៨ មានដូចជា៖
- ខេត្តបុរីរម្យ, នគររាជ, នគរនាយក, ស៊ីសាកេត, ស្រះកែវ, សុរិន្ទ, ប្រាជិនបុរី, ច័ន្ទបុរី, ខនកែន, អ៊ូប៊ុន
- ខេត្តដែលបានទៅឡាវ គឺខេត្តចម្ប៉ាសាក់ នៃអតីតស្រេស្ឋបុរៈ របស់កូនចៅឥសីកម្ពុ+មេរា

# ដែនដីបាត់បង់ទៅខាងសៀម

- ១៧៩១ សៀមបានលើកចៅហ្វាបែនជាហ្លួងមឿង(ចៅហ្វាយខេត្ត)បាត់ដំបង ងារជាចៅពញាអភ័យធីបែសវិសេសសង្គ្រាមរាម ដែលជាងាររបស់ស្តេចត្រាញ់ខេត្តបាត់ដំបង កាលនៅទឹកដីកម្ពុជានៅឡើយ ៕
- បណ្តាខេត្តដែលនៅខាងជើងបាត់ដំបងវិញ មានមង្គលបុរី សិរីសោភ័ណ្ឌ និងក្វ៉ាតពួកសៀមយកដាក់ធ្វើជាទឹកដីរបស់គេយ៉ាងស្ងៀមស្ងាត់នៅក្នុងឆ្នាំ ១៧៩៥
- ១៨១៤ សៀមលេចមុខនៅក្វ៉ាត់+ដណ្តើមកាន់កាប់ខេត្តនៅទឹកដីភាគខាងជើងទាំងអស់ចន្លោះខេត្តព្រហ្មទេព+ដងរែកយកខេត្តម្លូព្រៃ និងទន្លេរពៅ សៀមទៅយកខេត្តស្ទឹងត្រែង

## សេចក្តីសន្និដ្ឋាន

- មុនពេលកសាងទីក្រុងនៅឧដុង្គនៅឆ្នាំ១៦២០ ព្រះបាទស្រីសុរិយោពណ៌តាំងរាជវាំងបណ្តោះអាសន្ននៅល្វាឯមក្នុងស្រុកអរិយក្សត្រ ដើម្បីបង្រួបបង្រួមប្រទេសកម្ពុជាឡើងវិញ
- ពេលកម្ពុជាប្រទេសរឹងមាំមានតុល្យភាពយោធាជាមួយសៀមនៅទសវត្សរ៍១៦១០ ស្តេចឯង្ទៀនចាប់ផ្តើមទាក់ទងសុំជំរឹសឹក ជាថ្នូរជាមួយបុត្រីអង្គចូវ ដែលជយជេដ្ឋាទី២លើកជាអគ្គមហេសី ដើម្បីពង្រឹងចំណងសម្ព័ន្ធមិត្តជាមួយប្រទេសយួនខាងត្បូងផង បន្ទាប់ពីព្រះអង្គដោះដៃពីសៀម
- ក្រោយជយជេដ្ឋាទី២ចូលទិវង្គត រាជវង្សចាប់ផ្តើមបែកបាក់គ្នា និងប្រកួតប្រជែងដណ្តើមអំណាចគ្នាកាន់តែញឹកញាប់ ដោយមានការចាក់ចុចពីបរទេស ឬប្រទេសជិតខាង ហើយពួកមន្ត្រីក៏ប្រជែងគ្នា
- សៀម__យួនប្រជែងគ្នាបង្កើនឥទ្ធិពលលើឧដុង្គ ដោយការគាំទ្របេក្ខភាពព្រះមហាក្សត្រខ្មែរដែលស្និទ្ធជាមួយខ្លួន និងកាត់យកខេត្តខ្មែរជាបន្តបន្ទាប់ទាំងខាងជើងនិងខាងត្បូង
- ដោយមើលឃើញគ្រោះមហន្តរាយបណ្តាលមកពីការព្យាយាមលេបត្របាក់យកស្រុកខ្មែរនេះហើយ ទើបព្រះបាទអង្គដួង ព្យាយាមរកមហាអំណាចទី៣ គឺបារាំងនៅឯនាយសមុទ្រមកជួយសង្គ្រោះកម្ពុជា

# អារ្យធម៌សម័យកណ្តាល




## មាតិកា និងបុច្ឆនសិក្សា

- ១__កម្រងច្បាប់គ្រប់គ្រងរដ្ឋដ៏ល្អ
- ២__ ទ្រឹស្តីគ្រប់គ្រងរដ្ឋ
- ៣__ វប្បធម៌ដែលផ្អែកលើព្រះពុទ្ធសាសនា
- ៤__ការខិតខំបង្កើតឯកភាពជាតិឡើងវិញ
- ៥__ស្នាដៃអក្សរសិល្ប៍សាស្ត្រាល្បែង
- ៦__ការបាត់បង់ធនធានមនុស្ស (ពលរដ្ឋ និងអ្នកចេះដឹង )

# ក្រមច្បាប់ ដ៏ល្អសម្រាប់ គ្រប់ គ្រង

- លោក។អាដេម៉ារ។ឡឺក្លែរ (Adhémard Leclère)
  - ប្រទេសខ្មែរ។ធ្លាប់ ជាប្រទេសនីតិរដ្ឋមួយ
  - ព្រោះធ្លាប់ មានច្បាប់
- ច្បាប់ សម័យកណ្ដាល សម្រាប់ គ្រប់ គ្រងតាំងពីមនុស្ស រហូតដល់ សត្វ,។*Cambodge.. une nation qui fut un grand peuple et qui mérite et notre admiration pour ce quelle a fait dans le passée,* Adhémard Leclère.
- ក្រមទម្រង់ ស័ក្តិសម្រាប់ បញ្ញត្តិវិន័យការងារស្របតាមតួនាទីខ្លួន និងពាក្យថ្លៃថ្នូរ
- ក្រមស្រុកដែល យ៉ាងហោចណាស់ ពីឆ្នាំ១៦១៣ បង្ហាញនូវនីតិវិធីជ្រើសរើស។និងវិន័យរដ្ឋបាលរបស់ មន្ត្រីស្រុក។ប្រកបដោយគតិបណ្ឌិត

# ក្រមច្បាប់ ដ៏ល្អសម្រាប់ គ្រប់ គ្រង

- កម្រងច្បាប់ ជាច្រើនក្រម។មានការប្រមូលផ្តុំចងក្រង និងធ្វើវិសោធនកម្ម ឡើងវិញ នៅចុងសតវត្សរ៍ទី១៧ ដោយព្រះបាទជយជេដ្ឋាទី៣ ។
- មានច្បាប់ មួយសម្រាប់ ពួកចៅក្រមស៊ើបអង្កេតនិងកាត់ ក្តី ។៤ ល្បិចចៅក្រម។គឺ*មន្ទលេន, ។សេនបទ, មណ្ឌុកជ, ។សីហលោ*។ដែលគេមិនទាន់ រកឃើញសំណៅពិស្តារ
- មានច្បាប់ មួយឈ្មោះថា *ក្បួនទំនឹមពីបុរាណ*។ដែលជាកំណត់ ត្រាខ្លីៗ ពីការកាត់ ក្តី នៅសម័យបុរាណចាប់ ពីរាជ្យនារាយណ៍រាជា។ដល់ រាជាព្រះបាទជយជេដ្ឋាទី៣ នៅឯង ។កំណត់ ត្រានេះ បាន ឱ្យយើងមើលឃើញនូវគម្រូអភិបាលកិច្ច ល្អជាច្រើន

## គម្រូខច្បាប់ ដ៏ល្អសម្រាប់ គ្រូប់ គ្រូខ

(១១)ទុំនីម១០(២០)។កាលរាជព្រះអង្គអំពីមុននោះ មានមហាតសម្តេចព្រះឯកខ្សត្រី។ព្រះនាម ឯ
(១២)ក្រោយហៅអ្នកមានបុន ់ ពីសែស។មហាតព្រះ អង្គនោះ វា នៅរាតត្បាតបែះបោចសារពើ
(១៣)ដំណាំគេ ទើបអសអ្នកស្រុកហៅថា។អ្នកមានបុណ្យពីសែស។អ្នតថាពីសេសម្តេច។
ហើយ។ឱ្យតែ(១៤)មហាតមក រែរាតត្បាតគេ។ទើបអសមហាតនោះ វា ឮហើយវា ទៅទូលព្រះ
អង្គ។ៗជ្រាបហើយ។(១៥)ព្រះអង្គខ្ញាល ់ ។ហើយ ឱ្យទៅប្រកោះអ្នកស្រុក ដែលថានោះមក ឱ្យជុំនុំ
។ទើបអស ់ ជុំនុំពី(១៦)ចារណា។ទើបអសអ្នកស្រុកឆ្លើយថា ព្បិតយលអសមហាតនោះ នៅរាត
បេះបោចអស ់ (១៧)ដំណាំនោះឯង។ខ្លួននេះស្រដីមែន ទើបព្រះ អង្គឱ្យវិន័យអ្នកស្រុក ដែលថា
នោះ ពឹង ជុំទ្បឹង(១៨)១៧។ឯមហាតដែល នៅរាតនោះ។ព្រះអង្គ ឱ្យកាប ់ ក្បាល៥រណ្ដៅ
សម្រាប ់ មួយទូរ(ម្នាក ់ )។ហើយអស ់ (១៩)ជុំនុំចុះ ទៅសាឡា។ហើយ ឱ្យរាក ់ ងារ ទាហាន
កាប ់ ក្បាលអសមហាតទាំង៥នាក្ខ ់ ។ហើយនាំ(២០)ក្រយ ៉ាពិន័យថ្វាយ៕ៈ «នេះជាការ ្ ផ្ទា
ទោសអ្នក បម្រើល្មើសអាងចៅហ្វាយខ្លួនជាអ្នកធំ» ៕

## គម្រូខច្បាប់ ដ៏ល្អសម្រាប់ គ្រូប់ គ្រូខ

(១៧)មានទំនីម១៥(២៥) កាលព្រះ អង្គឯ ់ នៅក្នុងបន្ទាយធំនោះ មានចិន១ស្កាលជម្រួចឃ្លាំង ។
មកខ្ចីបៀ(១៨)អ្នកឃ្លាំង ។ឱ្យបៀរហ្លួង ទ្រង ់ បៀរនោះបាត ់ ។ហើយព្រះ អង្គជ្រាបជាបៀរនោះ
បាត ់ ។ទើប ឱ្យចៅក្រម(១៩)ជុំនុំ លុះចៅក្រមជុំនុំពិចារណា យល ់ ទាស ់ ថា។អ្នកឃ្លាំង
នោះខុស។ឱ្យបៀរទ្រង ់ ទៅចិនពុំបានក្រាបទូល(២០)ឱ្យបានជ្រាបឡើយ យលជាតាក ់ តែងចិត្ត
ឯង ទើបអស ់ ជុំនុំឡើងក្រាបទូលដោយទោស។ទើបព្រះអង(២០_(១))ពុំឱ្យពិន័យជាតាក ់ តែង
នោះឡើយ ។ឱ្យរងតែថ្លៃបៀរទើបអសជុំនុំចុះ ទៅសាឡា។ហើយ(២)អស ់ ជុំនុំឱ្យទៅជន្លឹងចិន
ឯផ្សារ ។ថ្លៃបៀររាស្រ្ត។តើបុ ៉ ន្មាន ទើបអស ចិនផ្សារថា។ឯថ្លៃបៀរ(៣)នោះបាទ៥ ៉ក៏មាន។បាទ១០
ក៏មាន ទើបអស ់ ជុំនុំកាត ់ ថ្លៃបៀរនោះបាទ១០។ហើយធ្វើឡើង(៤)១ជា១០ ត្រូវជាប្រាកជឹង១
ដុំម្លឹង៥ហើយឡើងមកក្រាបទូលជ្រាប។ហើយចុះទៅឱ្យធ្វើសំបុត្រ(៥) ឱ្យអ្នកឃ្លាំងរកប្រាកជឹង១
ដុំម្លឹង៥ថ្វាយ លុះឱកញ្ញាក្រហ្លាហោមឡើង ទៅគាល ់ ។ ៉ក៏មានព្រះ(៦)បន្ទូលត្រាស ់ ជន្លឹងឱកញ្ញា
ក្រហ្លាហោមថា។បៀរតើថ្លៃបុ ៉ ន្មាន ទើបឱកញ្ញាក្រហ្លាហោមថា ឯថ្លៃ(៧)បៀររាស្តនោះបាទ១០ ។
ឯថ្លៃបៀរហ្លួងថ្លៃ៥ដុំម្លឹង ទើបព្រះអង្គខ្ញាល ់

## គម្រូខច្បាប់ ដ៏ល្អសម្រាប់ គ្រូប គ្រូខ

។។ ឱ្យអាជ្ញាទៅនឹងចៅក្រម (៧៨)អស់ ចៅក្រំម ឱ្យិតក្រយ ាពិន័យ(ឡើង)វិញ(ម្តង)ទៀត ទើប ៗអស់ ចៅក្រមទាំងនោះគិតក្នុងថ្លៃបៀរហ្លួងដំម្លឹង៥(៩)ទ្វេជា១០។នោះត្រូវជាដំម្លឹង៥០ ឱ្យនអ្នកឃ្លាំងៗពុំ ទទួលឡើយ អ្នកឃ្លាំងឡើងក្រាបទូល (១០)ទើបហ្លួងមានព្រះបន្ទូលថា ចៅក្រមឥតពិចារណា គិតខុសឯងហើយ។តើនឹង ឱ្យម្តចត្រូវគេ(១១) វិញទៀត។កុំ ទទួលឡើយ ចៅក្រមរើបង្គាប់ ឯង ត្រូវ ក្យិត អណ្តាតទើប ឱ្យទូល ទើបមាន(១២)ព្រះបុន្ទូល ឱ្យត្រូវចៅក្រមអស់ទាំងនោះ ត្រូវក្រយ ាពិន័យត ាងគេជីង១ដុំម្លឹង៥ ទើបអស់ (១៣)ជុំនុំចៅក្រមគ្រប់ គ្នា។រកប្រាក់ ជីង១ដុំម្លឹង៥ឡើងថ្វាយ អ្នកឃ្លាំង យកប្រាក់ ជីង ជុំម្លឹង៥(១៤) ទៅឱ្យចៅក្រម ថ្វាយព្រមត្រូវជាប្រាក់ ដុំឡឹង៥០ហោងជាសួរេច។ទើបព្រះ អង្គប្រដៅអស់ ចៅក្រម(១៥)ថា ជុំនុំសេចក្តីមុខក្រោយ ។ឱ្យនិត្យពិគ្រោះ។ឱ្យថៃទាំដូចឱកញាក្រហ្លាហោម ។នេះច្បាប់ (១៦) ជូរវាញទ្រព្យហ្លួងនៅក្នុងព្រះឃ្លាំង ជា១០។ នោព្រះឱប្បយោរាជ១ជា៩ ។នោសម្តេច(១៧)ព្រះទាវ-មាតុច្ឆា ១ជា៨។ទោះស្តេចសព្វព្រះអង្គ១ជា៧។៕:

«នេះជាការពិន័យមន្ត្រីជាន់ ខ្ពស់ ឃុបឃិតគ្នា កេង ប្រវ័ញ្ចប្រាក់ រាជការពេលទិញបៀរសងស្តេចវិញ»

## គម្រូខច្បាប់ ដ៏ល្អសម្រាប់ គ្រូប គ្រូខ

(១៦)មានទុំនីម២៣(៣៣)។កាលព្រះបាទសម្តេចព្រះរាជឱង្ការព្រះស្រីធម្មិរាជ្ជា។កាល្មោះមានអក់ម៉ឺនមហាស្នឹតមហាត(១៧)ឡឹក១ ។ទៅបរសែះលេងពានលើកូនចៅជ្ជេត បាញ្ញាថ្លោះត្រគាក។ទើបចៅជ្ជេតបា ញ្ញាពុំ(១៨)អត់ ឡើយ។បានជង្វាយ ឡើងទៅក្រាបទូល។ទ្រង់ ព្រះករុណាជ្រាប ហើយ។ដាក់ សេចក្តីឱ្យអស់ (១៩)នាម៉ឺនចត្តុស្តមទាំង៤។ឱ្យជុំនុំពិចារណា នៅសាឡាបាញ្ញាន់ សឹង ។ទើបអស់ ជុំនុំ ឱ្យហៅ(២០)អក់ម៉ឺន ។ថឹងជាខ្លួនខុស ហើយថាទៅប្រពន § ឈ្មោះនាងអេវ ថា នាងអើយអញយលខ្លួននេះជាខុសហើយ។(២១)នាងយកប្រាក់ ជីង ជុំម្លឹង១៧ ទើបប្រពន § ទៅយកប្រាក់ ជីង ជុំម្លឹង១៧ ឱ្យផទើបអក់។(២៩-(១))ម៉ឺនយកប្រាក់ ទៅបង់ ក្រយាពិន័យ(ឱ្យ)អសជំនុំនៅសាឡាបាញ្ញ៉ាន់ សឹង ពុំឱ្យចៅក្រំម(២)ព្រួយចិត្រ ឡើយទើបអក់ម៉ឺនចាក់ប្រាក់ នឹងរាប់ ឱ្យចៅជេតបា ញ្ញា ។ពុំអត់ ឡើយ(៣)ខឹង ថាទៅទៅកាន់ អក់ម៉ឺន

# ក្បួនច្បាប់ដ៏ល្អសម្រាប់ គ្រប់ គ្រង

គាត់ ធ្វើអំណាចដូចស្តេច ប៉ែសះពានលើកូនអញ ទើបអក់(៤)ម៉ឺន ៊ីងចៅក្រមជុំនុំពិចារណា យលចៅជេតបា ញាថាដូច្នោះ។យលពុំគួរណាស់ ហោង។(៥)គេខ្លាចដ្បិតគេឥតអំម្ន ាច។ទើបគេយកមកបង់ ក្រយ ាពិន័យ ទើបអស់ ជុំនុំ ឱ្យអក់ម៉ឺន(៦)យកប្រាកទុករិង។ទើបអស់ ជុំនុំយកអក់ម៉ឺន និងប្រាក់ ទៅថ្វាយទ្រង់ ព្រះកួណាពិសេស។សព្វ(៧)ព្រះរាជហប្ញទ័យ។ហើយមានព្រះបន្ទូល ឱ្យប្រាក់ ដុំឡឹង១៣បាត្រ៣។ល្ហ ទឹងស័ក្តិអក់ម៉ឺន (៧៨)សំណល់ អំពីនោះ បានជាដង្វាយទ្រង់ ព្រះកួណាពិសេស ។ទើបអស់ ជុំនុំហួតប្រាក់ ដំម្លឹង១៣(៩)បាត្រ៣ យកចុះទៅព្រះសាលា ។ ត្រឡាក់ (នោះ)ទៅចៅជេតបា ញា។៕

«នេះជាការពិន័យមន្ត្រីជំនិតស្តេច។ដែលពានពៀរលើអ្នកស្រុកដោយអចេតនា»

# ក្បួនច្បាប់ដ៏ល្អសម្រាប់ គ្រប់ គ្រង

(១០)មានទុំនីម២៤(៣៤)។ឈ្មោះចៅសោមប្រយូងមានខ្ញុំស្រី១ឈ្មោះមៀស្រុក។ទៅជន្ទាត់ ហើយ(១១)បានត្រីមកស្ល ។ចៅទំទាំ(ឱ្យ ព្រស្ល)ដោយទាំង កូនកោត់ ទៅក្នុងសំឡរ។លើកទៅ ឱ្យចៅសោមហូប(១២)បាយ ចៅសោមយល់ កូន កោត់ នៅ ច្នានសំម្លរហើយ ។ទើបចៅសោមហៅមេស្រុកមកវាយលុះ ទុំ(១៣)ខ្លួន ធ្ងន់ ឈាមដាប។មេស្រុករត់ ទៅនៅផងមហាតអង្ក្រាក់ ឈ្មោះអក់ហ្លួងកូវ។ចៅសោមទៅ(១៤)យកជើង ៣មេស្រុក មិនកឡើយ ។នៅលើ ផ្ទះអក់ហ្លួងកូវ ទើបចៅសោមរកដង្វាយឡើងទៅ(១៥)ក្រាបទូលអំពីដំណើរតួមេស្រុករត់ ទៅ ផ្ទះអក់ហ្លួងកូវ ទើប ទ្រង់ ព្រះចិន្តាថានឹងចៅហ្វាយ ឱ្យប្រើ(១៦)ទៅយកតួមេស្រុក។ទើបចៅហ្វាយប្រើអក់ហ្លួងកុំចរសីល និងកូនងារ ពនាក់ ឈ្មោះចាន្ទ ១(១៧)នៀ១ឆាន់ ១ ទៅយកមេស្រុកអំពីផ្ទះអក់ហ្លួងកូវ បើក ឱ្យដំណើរមកដល់ កណ្តាលផ្លូវ (១៨)មេស្រុករត់ ទៅចូលក្នុងស្រូវចៅ ច្នាន ព្រៃងារ ទើបអក់ហ្លួងកុំចរសីលនៅអស់ កូនងារដេញ(១៩)តាមទៅ ច្បាប់ មេស្រុកចងថងវាយ ព្រួត ព្រួន នៅក្នុងស្រូវចៅចន្ទ ។ទើបចៅចាន្ទ ស្រដីអង្វរឃាត់ ។(២០)កុំ ឱ្យច្បាប់ ក្នុងស្រូវដ្បិតស្រូវកុំពង់ ផ្លែ អក់ហ្លួងកុំចរសីលនៅអសកូនងារថា។ខ្លួនជាមហាត ព្រ(២១)កោតញញើតឡើយ។ហើយនាំតួមៀស្រុកយកមកដល់ ចៅហាយ ទើបចៅហាយឱ្យតមេសក

## កម្រងច្បាប់ ដ៏ល្អសម្រាប់ គ្រប់ គ្រង

(៣០_(១) )ទៅចៅសោម ។ហើយចៅសោមបង់ ប្រាក់ ដំម្លឹង១ ឱ្យទៅអក់ហ្លួង កុំចរសីលនៅអស់ កូនងារ
ជាឈ្នួល។(២) ទើបចៅចាន្ទ អំម្ចាស់ ស្រូវឡើងក្រាបទូល ទ្រង់ ព្រះកូរុណាពិសេស។ដោយដំណើរ
ជ្រាបសព្វគ្រប់ ហើយ(៣)ដាក់ សេចក្ដី ឱ្យទៅចៅហ្វាយជុំនុំពិចារណា យលអក់ហ្លួងកុំចរសីលនៅ
កូនងារធ្វើអំពើពាល្យង្វាយ(៤)ពុំគួរ ដ្បិតព្រះព្រៃស្រពនេះ ជាព្រះជីនីទ្បជីនុកចិញ្ចឹមមនុស្សផង ។ទើប
ចៅហ្វាយនៅអស់ ជុំនុំម(៥)កាត់ សេចក្ដីនេះ ។ឱ្យចៅចាន្ទ អូសខ្ញុំអំពីចៅសោមយក ទើបឱ្យអក់ហ្លួង
កុំចរសីលនៅកូនងារ(៦)យកប្រាក់ ដុំម្លឹង៣០ទៅលោះមេស្រុកអំពីចៅចាន្ទ នោះ។ត្រូវអក់ហ្លួង កុំចរសីល
ជីង១ត្រូវអស់ កូន(៧)ងារដុំម្លឹង១០ ឱ្យទៅចៅចាន្ទ អំម្ចាស់ ស្រូវ ទើបចៅចាន្ទ ទំទួលយកប្រាក់
បើកគួមេស្រុក។ឱ្យទៅអកហ្លួង(៨) កុំចរសីល ហើយអក់ហ្លួង ប្រគល់តួមេស្រុក ឱ្យទៅចៅសោម ។ទើបចៅ
ចាន្ទ យកប្រាក់ ជីង១ ឱ្យចៅហ្វាយនាំ(៩)ឡើងក្រាបទូលថ្វាយទ្រង់ ព្រះកូណាពីសែស ។ហើយត្រាស់
ឱ្យចៅហ្វាយទុកប្រាក់ ជីង១ ឱ្យរាប្រាក់ ង្វារ ឱ្យលោះ(១០)មហាតនៅអស់ ពល កុំឱ្យកុំជីងទ្រព្យអស
អាណាប្រជានុរាស្រ្ដផងទាំងពួង។ក្រែងខ្វាត់ ភ្លាត់ បាត់ (១១)អស់ មហាតនៅពលអស់ ទាំងនេះ ។
សឹងជាខ្ញុំសំរាប់ព្រះបាទអ្នកជាអំម្ចាស់ សព្វរាជរៀងមកហោង។៕ :។

«នេះជាការពិន័យភ្នាក់ ងាររាជការ ដែលធ្វើការមិនគោរពតាមនីតិវិធី អាងអំណាចចៅហ្វាយនាយ និង
ជំនឿនៃការគោរពស្រូវពេលកំពុងចេញផ្លែ»

## កម្រងច្បាប់ ដ៏ល្អសម្រាប់ គ្រប់ គ្រង

(១៤)មានទុំនីម២៧(៣៨)។កាលរាជ្យព្រះបាទ សម្ដេចព្រះរាជឱង្ការព្រះ ជៃជេស្ឋាបរមទានាដួបរំម្ម
បពិត្រ។(១៥)កាល្នោះមានចិន១ឈ្មោះចៅឡាក់ ។ជាក្ដីនឹងព្រះស្រែនជៃ្យជានាយ
អង្គរក្ស។ព្រះស្រែនជៃ្យបានទៅក្ដីនឹងចៅ(១៦) ហ្វាយ។ៗឱ្យទៅហៅចៅឡាក់ ពាជើង មកពុំ
ឡើយ។ថារវេររវល់ ។ទើបចៅហ្វាយ ឱ្យទៅថានឹងឱកញ្ញា(១៧)រាជនុរេស ។ឱ្យទៅអូសខ្ញុំចៅ
ឡាក់ បាន ៥នាក់ ប្រុស ៣ស្រី២។ខ្ញុំ១ឈ្មោះអានង១, ពៅ១, សិត ១។ខ្ញុំស្រីមេ ម៉ារ១,
ពៅ១ ។(១៨)លុះបានទាំង ៥នាក់ មកហើយ ឱ្យឱកញ្ញារាជនុរេស ។យកទៅទុកនៅដៃ
ព្រះសួភាអន្ទិត។ៗមាន(១៩) ចិត្រង់ មេពៅ (ក៏)ស្រដីប្រលោមយកចិត្តវាថា នឹងយកជា
ប្រពន្ធ ។ទើបមេពៅព្រមដោយព្រះសួ(២០)ភាអន្ទិត ។ៗ ឱ្យសំពត់ ១ស្បៃ១ លុះ
ហើយសេចក្ដីព្រះស្រែនជៃ្យ។នឹងចៅឡាក់ ។ទើបអស់ ជុំនុំ បង្គាប់ ឱ្យព្រះសួភាអន្ទិតយក
ខ្ញុំទាំង៥នាក់ ។មកឱ្យចៅឡាក់ ។(២១)ចៅឡាក់ ។មើលយល់ មេពៅបានស្បៃ។(៣៤_
(១))កាស្បៃ ១សំពត់ ១។យល់ អង្គើរក្ដីឱ្យច្នោះ

## ក្រមច្បាប់ ដ៏ល្អសម្រាប់ គ្រប់ គ្រង

។ចៅឡាក់ លោមដន្លឹង(សួរ)មេពៅ ប្រាប់ ដោយនូវពាក្យពុំនឹកថា។(២)ព្រះសូភាអន្ទីត មកជាស្មួន់ អនុករ ហើយ ឱ្យស្បនៅសំពត់ នេះឯង ទើបចៅឡាក់ ពុំអត់ ឡើយ ។ក្រាប(៣)ទូលព្រះបាទអ្នកជាអំម្ចាស់ បានជ្រាបសព្វគ្រប់ ហើយ មានព្រះបន្ទូល ត្រាស់ ឱ្យចៅហ្វាយជុំនុំមពិចារណា(៤)រកសេចក្ដីព្រះសូភាអន្ទីត។និងមេពៅ ទើបអ្នកចៅហ្វាយ ឱ្យហៅព្រះសូភាអន្ទីត់ ទៅសាឡាព្រះ បញ្ញាន់(៦)សីង្ឃ ជុំនុំជួបជុំមនីងអស់ ចៅក្រមនៅព្រះសាល ។ ទើបពីចារណាព្រះសូភាអន្ទីត។ឆ្លើយជុំរាប(៧)អ្នកចៅហ្វាយ។និង អសជុំនុំថា ខ្ញុំប្របាទជាអនុករនីងមេពៅមែន មេពៅឆ្លើយត្រូវដូចពាក្យ(៨)ព្រះសូភាអន្ទីត។ដូច្នោះទើបឱ្យពិន័យព្រះសូភាអន្ទីតដោយនៅសក្ខីពីរចុះ។ហើយ ឱ្យព្រះសូភាអន្ទីត (៩)តាមទៅសូមលោះមេពៅអំពីចៅឡាក់ ។ជីង៣ដំម្លឹង១០ជាសួរេចហោង។៕៚«ការកាត់ សេចក្ដីដាក់ ពិន័យ និងបកស័ក្តិដោយមិនឃុបឃិតថាជាមន្ត្រីដូចគ្នា និងការមិនសមគំនិតរបស់ ស្ដេចជាមួយមន្ត្រីធ្វើល្មើសរឿងសាហាយស្មន់ ។ក្នុងតំណែង»

## ក្រមច្បាប់ ដ៏ល្អសម្រាប់ គ្រប់ គ្រង

(១៧)មានទុំនីម២៩(៤០)។ឈ្មោះអាយុក់ ជាក្មេងទៅលេងក្រោមសំណាមស្រែចៅយុង់ នោះ ចៅយុង់ ជាអំម្ចាស់ (១៨)ដំណាំទុកឆ្នាំងបាយ,បាយ,សម្លរ អង្ករស្បោង។និងត្រីងៀតលើខ្មនោះ ចៅយុង់ ជាអំម្ចាស់ សុំណាំមនោះ (ពុំ១៩)នៅមក ឯង។ទើបចៅយុក់ ឡើងទៅលេងលើសំណាំមនោះពុំជួរកាលឡើយ លុះដល់ ចៅយុង់ (២០)មកអំពីផ្ទះ ឃើញចៅយុក់ នៅលើសំណាំមហើយ ចៅយុំងដន្លឹងចៅយុកថា។នរណាប្រើចៅឯងមក (២១)លេងលើសំណាំមអាញ់ ។សំណាំម នេះបុន់ អាញ់ ។តែមក្រែងដុំរ,ប្រើស,ជ្រូក ,ទ្រាយ,ទន្សោង,ទន្សាយ,រមាំង,គោព្រៃ(២២)វាមកស៊ីស្រូវអាញ់ ។ឥឡូវនេះចៅឡើងឯង ។បើខុសត្រណមអាញ់ ហើយ។អាញ់ ពុំអត់ ចៅយុក់ ឯងឡើយ (១៣៥_(១))ទើបចៅយុង់ នាំចៅយុក់ ទៅប្រាប់ ម្ដាយអាពុក់ ។និងអស់ អ្នកស្រុក ឱ្យជួយជាសាក្សី ចៅយុង់ វិលមកសំ(២)ណាំមចាំស្រូវ

## កម្រងច្បាប់ ដ៏ល្អសម្រាប់ គ្រប់ គ្រង

- លុះយប់ នោះជ្រូកនិងដំរីទន្សោងគោព្រៃ។វាមកស៊ីស្រូវ ចៅយុង បាញ់ បោះ(៣) ដេញ បង្អើលវា ពុំស្លប់ ឡើយ វាស៊ីស្រែ១, ២សហើយ។លុះព្រឹកឡើងចៅយុង មក ផ ។បានអង្គរ(៤)ស្រាវស្លារម្ហូវទៅ ឪងឱកញ្ញា *ហ៊ុល ទេព្វខ្សេត្រាទិប្តី*។ ឱ្យទៅប្រកោះចៅយុក យកមកដន្ដឹង(៥)ពីចារណា ចៅយុក ឆ្លើយត្រូវដូចពាក ប្រចៅយុង ។ទើបអស់ ជុំនុំឱកញ្ញា ព៍ហុលទេព្វក្សេត្រា(៦)ទិប្តីនាំសេចក្តី នៃឡើងទៅដល់ ព្រះសាឡា ។ ជួធើងអំុស ព្រះសូភាបានពីចារណាវិញទៀត(៧)ត្រូវពាកគ្នារ ទើបរកសត្រា ឱ្យន័យចៅយុក គ្រឹងតួ ។ ហើយបែងជាភាគ៣ ភាគ២ ឱ្យាន(៨)ទៅចៅយុង ជាអំម្ចាស់ សំណាំម ភាគ៍១ ឱ្យ ប្រណីព្រៃហ្លួង ដ្បិតចៅយុក នែះវាជាក្មេង ស្ញុំ ទាំង(៩)សេចក្តីខុសត្រូវនៅឡើយ ទើបពេញ គុង្វាល ទើបអស់ ជុំនុំ ឱ្យប្រណី។ ពុំឱ្យបកពេញ ឡើយហោង ៕៚«ការកាត់ សេចក្តីរឿងកម្រិតរដ្ឋប្បវេណី លើបទល្មើសដែល ផ្អែលើជំនឿមិនសមហេតុផល—តំណម ខ្ទមស្រែ»

## កម្រងច្បាប់ ដ៏ល្អសម្រាប់ គ្រប់ គ្រង

(៥)មានទុំនីម៣៣(៤៤)។ឈ្មោះចៅកូវបែកផ្សេងទៅទិញ អង្ករឯកំពុង ទិញ បានហើយយកកញ្ជើរមក(៦)ផ្គង នៅជ្រែកហើយ ។ គាព្វ ព្រះនន ធូបែសចំបងកុំឡោះទៅងូតទឹក នៅកំពុង ។លុះឡើងមកពួតសំពត់ (៧)ងូតរួចហើយ ចៅកូវបែកផ្សេងលើក អំម្រេកដើរទ្មៅ ។ព្រះនន ធូបែស នោះដើរតាមក្រោយទ្មៅ នៅ(៨)ព្រះនន ធូបែសយកសំពត់ ងូត នោះពាក នោះង ដងវ៉ែក ។ ឯចៅកូវ នោះពុំដឹង ឡើយលុះបង្វិល(៩)ដង្រែក នោះទៅមុក យល់ សំពត់ ងូត នោះ ចៅកូវដន្ដឹងថានែះសំពត់ ងូត ណនា ទើបព្រះនន ធូបែស(១០)ឆ្លើយថាសំពត់ អាញ់ ។ចៅកូវពុំអត់ ឡើយទៅដល់ ផ្ទះចៅកូវបានដង្វាឡើងក្រាព្វទូលថ្វាយ។ហើយទូលដោយដុំណើ(១១)បានជ្រាព្វសព្វគ្រប់ ហើយ។ទ្រង់ព្រះកូរណាដាក់ សេចក្តី ឱ្យទៅចៅហ្វាយ។នៅឱកញ្ញារាជនុរេសជុំនុំ នៅ សាល ា(១២)ព្រះបញ្ជាន់ សីង្គ ។

## ក្បួនច្បាប់ដ៏ល្អសម្រាប់គ្រប់គ្រង

ហើយ ឲ្យព្រះនន់ធូបែសមកពីចារណា ព្រះនន់ធូបែសឆ្លើយថា ពាក់លេងទេវ។(១៣)ទើបអស់ជុំនុំយលថា ព្រះនន់ធូបែសពាយងាយយកសំពតងូតឯងទៅពាក់លើដង្រែកគេដូច្នេះ។ទើប ឲ្យាត់(១៤)ក្រយ៉ៅពិន័យដំម្លឹង៣០ សែង ជាភាគ៣។ភាគ១ប្រណិ្យ។ភាគ២យកជាក្រយ៉ៅពិន័យ ឲ្យ ចាក្ខូវបែកផ្សេង(១៥)ហោង។៕ៈ

«ជាការពិន័យចំពោះបទល្មើសរដ្ឋប្បវេណី។បែបលេងសើចមួយ ដែលប្រព្រឹត្តដោយមេអង្គ-រក្សមន្ត្រីធំ រំលោភទៅលើអ្នកស្រុក សាមញ្ញ»

# ទ្រឹស្តីគ្រប់គ្រងរដ្ឋបែបឥណ្ឌា

- គេ នៅងចាំទ្រឹស្តីនៃ«ធាតុទាំង ៧របស់រដ្ឋ»បែបឥណ្ឌា និងចងក្រងទុកជាបន្តទៀត សម្រាប់អប់រំវណ្ណៈអ្នកដឹកនាំ និង សម្រាប់យកមកអនុវត្តន៍ក្នុងការគ្រប់គ្រងរដ្ឋ ។

ជាភស្តុតាងគេឃើញ នៅក្នុង

- សិលាចារឹកនគរវត្តលេខ៣៩(ប.២៩)ឆ្នាំ១៥៧៩ អំពី«សប្តប្រក្រឹតិ» និង
- នៅក្នុងសៀវភៅសំណៅឯកសារដើមរបស់ ន្យ។ឈើន។ដែលគេតម្កល់ នៅបណ្ណាល័យសាលាបារាំងចុងបូព៌ាប្រទេស (No. P. Camb. 53)៕
- សិលាចារឹកវត្តនគរបាជ័យ K.(82A, l.8)ឆ្នាំ១៥៦៦អំពីបច្ចេកពាក្យថា«សត្តរត្តន»សម្រាប់ ស្តេចចក្រពត្តិ។(ចក្រ, ដំរី, សេះ, ត្បូងរ័ត្ន, នារី, ទ្រព្យសម្បត្តិ និងទីប្រឹក្សា)៕

# ទ្រឹស្តីគ្រប់គ្រងរដ្ឋបែបឥណ្ឌា

ភារកិច្ចរបស់ព្រះមហាក្សត្រ

- ជាម្ចាស់ផែនដីត្រូវមានវត្ថុ៧។គឺភាពជាម្ចាស់ ១ ,មានអាមាត្យ១, មានទូវ(ជនបទ )ដែនដីខេត្តទាំងឡាយ១, មានរាជធានីប្រកបដោយគូទឹកជុំវិញ និងកំពែងឆ្លងក្រុង១, មានទូវឃ្លាំង១២សម្រាប់ដាក់ទ្រព្យសម្បត្តិ១, មានទូវ(កងទ័ព)ពលពាហណៈដ៏ក្លៀវក្លា ១,និងមានព្រះរាជសម្ព័ន្ធ § មិត្តដែលយល់ចិត្តគ្នាកាលណាមានភ័យ ១៕
- មុនអ្វីៗទាំងអស់ត្រូវតែហាត់ហ្វឹកហ្វឺន ,ព្យាយាមធ្វើឱ្យស្ទាត់ជំនាញក្នុងកិច្ចការផងទាំងពួង។ហើយត្រូវសេពគប់អ្នកមានធម៌សប្បុរស,។អ្នកមានប្រាជ្ញា ,អ្នកមានគុណវិជ្ជា
- ប្រកាន់ទសពិធរាជធម៌។និងមិនប្លន់ក្នុងទ្រព្យសម្បត្តិរបស់អ្នកដទៃ ត្រូវដឹងអធ្យាស្រ័យចំពោះអ្នកដទៃ ឱ្យហ័ស

# ទ្រឹស្តីគ្រប់គ្រងរដ្ឋបែបឥណ្ឌា

- សង្កេតពិចារណាជានិច្ចកាលលើពួកខ្ញុំ បម្រើជការទាំង៦ពួក ចាប់ពីអាមាត្យ។រៀង ទៅ
- ព្រះរាជាគប្បី។ត្រូវចេះដឹងគុណគេ ហើយ ឱ្យក្លៀវក្លាសមាគមសេពគប់ជាមួយអ្នកធំទាំង ពីអ្នកមានប្រាជ្ញាច្រើន។និងមានអាយុវែង អ្នកមានត្រកូលខ្ពស់ ១ អ្នកមិនបានធ្វើអំពើ ឱ្យវិនាសខ្លួន ។មានការភ្ញាក់។និងការភ្ញាក់ជាដើម ១មុនធ្វើការងារទាំងពួងតោងពិចារណារួចទើបធ្វើ ១មិនបានតិះដៀលគេ ។ដែលកុំគួរនឹងតិះដៀល១។ប្រាជ្ញាដូចម្តេចស្រួបកាន់ខ្ជាប់ខ្ជួនដូច្នោះ ១
- កុំ ឱ្យភ្លេចភ្លាំង ស្មារតី។ហើយកុំកាច់ចង្កូមព្រះនគរ កុំញីញក់ទង់ជ័យ ឬកុំកាច់ទង់ជ័យព្រះនគរ, កុំបង្ខិបរិតព្រះនគរ ៗកុំឆ្កៀលភ្នែកព្រះនគរ, កុំញីញក់ក្បាលព្រះនគរ កុំទម្លាយមុខ (ធ្វើ ឱ្យរាបយស)ព្រះនគរ ៕
- ទម្លាយមុខព្រះនគរ។គឺការទម្លាយញីញក់កូនប្រុសកូនស្រីរបស់គេ ចាប់យកដោយកម្លាំងពលទាហាន និងការកំហែង គំរាម ៕ ។

# ទ្រឹស្តីគ្រប់គ្រងរដ្ឋបែបឥណ្ឌា

- ព្រះរាជបុត្រ និងព្រះជេដ្ឋា ជាចុងចង្កូមព្រះនគរ ,។អ្នកប្រាជ្ញបុរោហិតដែលចេះដឹងគម្ពីរព្រះត្រៃបិដក និងត្រៃវេទជាភ្នែកព្រះនគរ, ។សេដ្ឋី គហបតីជាពោះព្រះនគរ, មហាឫសីមុនីជាទង់ជ័យព្រះនគរ, កូនប្រុសស្រីនៃមហាជនទាំងពួង។គឺជាកញ្ចក់ឆ្លុះ, ។ បិតាមាតា ជាចន្ទោលមុខ(រទេះ),។ពលទាហានក្លៀវក្លា ជាជើងព្រះនគរ៕ ។
- ព្រះរាជា និងពួកអាមាត្យ។ព្រមទាំងខ្ញុំព្រះរាជការត្រូវជំនុំគ្នា១ថ្ងៃ ៣ពេល គិតប្រឹក្សានឹងគ្នា ១ញ៉ាំងកិច្ចការព្រះនគរឱ្យរាបទាបព្រមគ្នា ១,ការ៉ាន់ យកខ្វាត់ សួយទៅដាក់ បង្គាប់ (អាយត្ត) ឱ្យត្រឹមត្រង់ ដោយសមគួរ ១,រាប់ អានចាស់ ព្រឹទ § ាចារ្យ១, ។ មិនបានញីញក់ បៀតបៀនបុត្រធីតាអ្នកនគរ ១គួរាប់ រាប់ អានបូជាទេវតាក្នុងព្រះនគរក្រៅព្រះនគរ។ដោយធ្វើតាមទម្លាប់ ១, ។ រក្សាសមណជីព្រាហ្មណ៍ដោយប្រពៃ១។(ប្រការ ធម៌ទាំង ៧ប្រការ )

# ទ្រឹស្តីគ្រប់គ្រងរដ្ឋបែបឥណ្ឌា

- លោកអ្នកដ៏មានគុណទាំងឡាយមាន ៨គឺព្រះឥន្ទ្រ១ ព្រះច័ន្ទ១ ព្រះអាទិត្យ ១ព្រះពាយុទេវតា ១ព្រះយមរាជ១ ព្រះមហាស្រមុទ្ទ ១ ។ភូមិទេវតា១ ព្រះវេស្សវណហៈទេវតា ១ព្រះទាំង ៨អង្គនេះ ជាទីប្រៀបនិងព្រះមហាក្សត្រ ដែលទ្រង់ទសពិធរាជធម៌ ៕
- ទ្រង់ ប្រព្រឹត្តិធម៌ ៥ប្រការ គឺពិចារណាអំពីប្រព្រឹត្តកម្មរបស់ ប្រជាជន ធ្វើនូវប្រយោជន៍ និងមិនប្រយោជន៍ចំពោះរាជ្យព្រះអង្គ ១ ។ទំនុកបម្រុងមនុស្សដែលមានសីលសត្យ ប្រមូលព្រះរាជទ្រព្យទុកដោយយុត្តិធម៌ ១រក្សាព្រះនគរ រាជសីមា ឱ្យក្សេមសុខដោយយុត្តិធម៌១ ស្ថិតក្នុងរាជកិច្ចប្រវេណីមិនដាច់ ១។

# ទ្រឹស្តីគ្រប់គ្រងរដ្ឋបែបឥណ្ឌា

ភារកិច្ចរបស់ មន្ត្រី ឬអាមាត្យ

- ជាមន្ត្រីមានអង្គ ៨គឺបានសណ្ដាប់ មកច្រើន១។គឺមានសីលគុណ ១ក្លៀវក្លា ១មានសេចក្ដីព្យាយាមច្រើន១។ធ្វើកិច្ចការរាជការរួច បានឆាប់ ១ មានកម្លាំងច្រើន ១មិនលោភតិច ១មានលក្ខណៈជាទីស្រលាញ់ ១ ប្រកបអង្គទាំង នេះ ទើបអាចធ្វើជាមន្ត្រីបាន ៕
- ជាខ្ញុំបម្រើព្រះរាជការ គប្បីទូលជំទាស់ ព្រះមហាក្សត្រដែលប្រព្រឹត្តការអាក្រក់ ១ គប្បីឱ្យប្រកបដោយប្រយោជន៍ច្រើន ១។ ជួយបិតបាំងចំណុចអាក្រក់ របស់ អម្ចាស់ ចេញ ១សម្ដែងគុណម្ចាស់ ឱ្យប្រាកដ១ វេលាអាប់ ចុះមិនចោលអម្ចាស់ ១ ។ វេលាអត្តខាត់ មិនរាថយការសង្គ្រោះម្ចាស់ តាមសតិកម្លាំង ១លក្ខណៈ ឲ្យការនេះ

## វប្បធម៌ដែលផ្អែកលើពុទ្ធសាសនា

- ពុទ្ធសាសនាថេរវាទ ខុសគ្នាពី ពុទ្ធសាសនាហីនយាន ។ដែលមាន គម្ពីរធម៌មិនជាភាសាសំស្ក្រឹត ។ តែគោលការណ៍ជំនឿ និងការប្រតិបត្តិស្ទើរតែដូចគ្នានឹងថេរវាទ ដែរគេឃើញវត្តមានរបស់ វានៅកម្ពុជា តាំងពីសតវត្សរ៍ទី៦ រាជ្យរុទ្រវរ្ម័ន ចុងសម័យហ្វូណន
- ពុទ្ធសាសនាថេរវាទ ៖ ។ពុទ្ធសាសនា គម្ពីរធម៌ភាសាបាលី ចាប់ សតវត្សរ៍ទី៥ ដែលបាន ផ្សាយចេញពីកោះស្រីលង្កា ដោយមាន ចែងវិន័យកិច្ចប្រតិបត្តិតាមពុទ្ធវាទដើម
- នៅសម័យកណ្ដាល។ព្រះសង្ឃ□មានចំនួនលើសពី១ភាគ៣នៃបុរសខ្មែរពេញវ័យ (Gaspar da Cruz)
- គេជឿថា ពុទ្ធសាសនាថេរវាទនេះ នាំមក ឱ្យខ្មែរដោយពួកមន តាមរយៈពួកថៃ (François Bizot)
- តាមពិតគេឃើញមានគាថាខ្លីៗនៃពុទ្ធសាសនា គម្ពីរភាសាបាលី នៅលើសិលាចារឹក ឬនៅលើពុទ្ធរូប តាំងតែពីសតវត្សរ៍ទី៧ម្ល៉េះ៕។តែលោក សឺដេស ជឿថា វត្តមានពុទ្ធសាសនា គម្ពីរភាសាបាលី ចាស់ ជាងគេរបស់ កម្ពុជា គឺទើបតែលេចឡើងនៅឆ្នាំ១៣០៩ ដូចមានចារឹកគោកស្វាយចេកជា ភស្តុតាង ៕

## វប្បធម៌ដែលផ្អែកលើពុទ្ធសាសនា

- សាសនានេះចូលមកស្រុកខ្មែរយូរយារណាស់មកហើយ។ ខ្មែរមិនមែនយកគម្ពីរធម៌នេះមកពីមន។ ឬសៀមនោះ ដែរ បើពុំនោះទេ គម្ពីរធម៌ដែលថៃ និងសៀម ប្រើតាំងពីដើមរៀងមកដល់ពាក់កណ្តាលទី១នៃសតវត្សរ៍ទី២០ សុទ្ធតែគេសរសេរជាអក្សរមន ឬថៃ តែប៉ុណ្ណោះ ទៅវិញពួកថៃ ។ និងសៀមតែងតែប្រើគម្ពីរធម៌នេះ ជាអក្សរខ្មែរ ហើយអក្សរសាស្ត្រសាសនាដទៃទៀត សុទ្ធសឹងសរសេរជាអក្សរ និងភាសាខ្មែរ ដែរ។ តែសៀមហៅថា «អក្សរខម» ៕
- គម្ពីរធម៌នេះ ជាប្រភពចំណេះដឹងខាងសីលធម៌, ទស្សនវិជ្ជា, ពេទ្យ, នយោបាយ និងវិទ្យាសាស្ត្រសង្គម។ ដែលអាចឱ្យខ្មែរក្រេបជញ្ជក់បាន។ ដើម្បីក្លាយខ្លួនជាបណ្ឌិត ឬ ប្រើការក្នុងជីវិតប្រចាំថ្ងៃរបស់ពួកគេ
- មន្ត្រីរាជការត្រូវព្រះរាជាជ្រើសរើសចេញពីចំណោមមនុស្ស ដែលធ្លាប់មានការសិក្សាផ្នែកធម៌អាថ៌ បានជ្រៅជ្រះ ជាពហូស្សូត្រ ឬចេះចប់គម្ពីរព្រះត្រៃបិដក

## វប្បធម៌ដែលផ្អែកលើពុទ្ធសាសនា

- ពង្សាវតារឡាវគ្រប់ច្បាប់ ។ អះអាងថា ពុទ្ធសាសនាថេរវាទ។ របស់ពួកគេនាំចូលពីស្រុកខ្មែរ។ ដោយព្រះរាជូបត្ថម្ភស្តេចខ្មែរនៅអង្គរ។ (ទំនងជាជ័យវរ្ម័នទី៩ )
- ព្រះបាទហ្វាងុម ជាកូនប្រសារ និងជាមេទ័ពរបស់ជ័យវរ្ម័នទី៩
- ក្រោយពីបង្កើតរដ្ឋឡាវឯករាជ្យរួបរួម—អត្តមហេសីកែវកន្យា។ ជាអ្នកដឹកនាំពួកមន្ត្រីឡាវ
- សុំស្តេចខ្មែរបញ្ជូនបេសកជនពុទ្ធសាសនា និងព្រះពុទ្ធរូបធ្វើពីមាសហៅព្រះបង។ ទៅដាក់នៅទីក្រុងមួងស្វា ដែលក្រោយមកទៅជា ហ្លួងប្រះបាង
- តែមជ្ឈមណ្ឌលសិក្សាជាន់ខ្ពស់ខាងសាសនានេះសំខាន់ជាងគេ។ ស្ថិតនៅវៀងចន្ទ។ និងប្រទេសឡាវ នៅឯង តាំងពីសតវត្សរ៍ទី១៥រៀងមក

## វប្បធម៌ដែលផ្អែកលើពុទ្ធ § សាសនា

- ឋានានុក្រមរបស់ ព្រះសង្ឃនៅកម្ពុជានៅសម័យកណ្តាលមានលក្ខណៈ ស្មុគស្មាញបន្តិច
- សហគមន៍ព្រះសង្ឃត្រូវ បែង ចែកពីរធំៗ គឺ *គាមវាស*។និង*អារញ្ញវាស*។ដោយសហគមន៍នីមួយៗ មានសង្ឃនាយកមួយ អង្គជាប្រមុខ ឬអធិបតីភាព
- មកដល់ ដើមរាជ្យ អង្គឌួង។ព្រះ អង្គបានតែងតាំងសង្ឃនាយកពីរ អង្គសម្រាប់ គ្រប់ គ្រង សហគមន៍ព្រះសង្ឃពីរគឺ។ខាង*គន្ថធុរៈ*។និងខាង*វិបស្សនាធុរៈ*។ ៕ ទោះជា យ៉ាងណា ក៏គ្មាន ឯកសារណាមួយបានពន្យល់ អំពីភាពខុសគ្នា ឬដូចគ្នារវាងគណៈសង្ឃទាំងពីរខាងក្រោយនេះ ។ ជាមួយនឹងគណៈសង្ឃពីរខាងលើនោះ ដែរ៕
- មកដល់ ឆ្នាំ១៨៥៥ព្រះបាទ អង្គឌួង បានសម្រេចព្រះទ័យកែប្រែរចនាសម្ព័ន § ព្រះសង្ឃសារជាថ្មី ។ដោយនាំចូល និកាយថ្មី*ធម្មយុត្តិក និកាយ*មកពីស្រុកសៀម។ទើបគណៈសង្ឃត្រូវ បែង ចែកថ្មី ទៀត គឺ*គណៈសង្ឃមហានិកាយ*។ជា និកាយចាស់ ប្រតិបត្តិធម៌ តាមអាចារ្យវាទ និង*គណៈសង្ឃធម្មយុត្តិក និកាយ*ដែលជា និកាយថ្មីប្រតិបត្តិធម៌ តាមគម្ពីរព្រះត្រៃបិដកបាន ចែងនិងសូត្រធម៌ តាមសំនៀងដើម ដែលស្រដៀង នឹងការសូត្រនៅស្រីលង្កា។ឬភាសាបាលីដើម។ដោយគ្មានទំនាញសូរ។និងតាមទម្លាប់

## វប្បធម៌ដែលផ្អែកលើពុទ្ធ § សាសនា

រចនាសម្ព័ន § គ្រប់ គ្រងសង្ឃ

- សម្តេចព្រះមហាសង្ឃរាជ—សង្ឃនាយក
- សម្តេចសង្ឃរាជ ឋានារាជាគណៈ មាន ថ្នាក់ ។(ដូចចតុស្តម្ភមន្ត្រី)
- មេគណ (ចៅហ្វាយខេត្តខាងពុទ § ចក្ក),។បាឡាត់ គណ។(អនុប្រធាន)
- អនុគណ។(ចៅហ្វាយស្រុកខាងពុទ § ចក្ក),។បាឡាត់ អនុគណ
- ចៅអធិការវត្ត_ចៅវត្ត—មេវត្ត, ។
- គ្រូសូត្រ ស្តាំ។គ្រូសូត្រឆ្វេង (បាឡាត់ វត្ត)
- នៅរាជ្យព្រះបាទអង្គឌួង ឋានៈព្រះសង្ឃមានលំដាប់ ស័ក្តិដូចមន្ត្រីខាងអាណាចក្រដែរ

## វប្បធម៌ដែលផ្អែកលើពុទ្ធ សាសនា

ឋានានុក្រមចំណាស់ វស្សា និងចំណេះដឹង

- សម្តេចព្រះ.......មហាសង្ឃរាជបពិត្រ
- សម្តេច.........សង្ឃរាជបពិត្រ ។
- សម្តេច ..........បពិត្រ
- មហាថេរ.......បួសជាប់ គ្រប់ ២០ឆ្នាំ
- ព្រះថេរ ឬ។ភិក្ខុ
- អនុថេរ ឬ។សាមណេរ
- វត្តនីមួយៗមានទ្រព្យគរុភ័ណ្ឌ៖ទ្រព្យព្រះពុទ្ធ រូប ព្រះគម្ពីរធម៌។ព្រះសង្ឃ។ចេតីយ៍។ ដើមពោធិ៍...
- ព្រះសង្ឃត្រូវលុះនៅក្រោមច្បាប់ ព្រះវិន័យតាមគម្ពីរព្រះត្រៃបិដក និងច្បាប់ រងសង្ឃខាង អាណាចក្រ

## ការចិតខំបង្កើតឯករាជជាតិឡើងវិញ

- ក្នុងរជ្ជកាលព្រះបាទ ជ័យជេដ្ឋាទី៣(១៦៧៥_១៧០៦)

  _លះបង់ រាជសម្បត្តិ ឱ្យទៅ ...ន និង ...យជីដូនមួយ។និងកូនប្រសារ។ដែលមានបិតាធ្លាប់ ជាគូសត្រូវរបស់ ទ្រង់ ។និងដែល ធ្លាប់ ពឹងកងទ័ពយួន ឱ្យយដណ្តើមរាជបល្ល័ង្កអស់ ពេលជាច្រើនឆ្នាំ

  _ប្រវត្តិវិទូខ្លះ យល់ ថា កម្ពុជា នៅសម័យនេះ មានអំណាចរឹងមាំ នៅឡើយទាំងនយោបាយ និងសេដ្ឋកិច្ច ដោយសារតែភាព ឈ្លាសវៃរបស់ ស្តេចអង្គនេះ

- ក្នុងរជ្ជកាលព្រះបាទនារាយរាជាអង្គតន់ ។(១៧៥៨_១៧៧៥)

  _លះបង់ រាជសម្បត្តិ ឱ្យទៅដៃគូប្រជែងនាម រាមាធិបតីអង្គនន់ ។ដែលបានពឹងសៀម ឱ្យយធ្វើសង្គ្រាមដណ្តើមយករាជបល្ល័ង្ក នោះអស់ រយៈពេល យ៉ាងយូរ

# ស្នាដៃអក្សរសិល្ប៍_សាស្ត្រាល្បែង

- សាស្ត្រាល្បែង ÷ សត្រារឿងផ្សេងៗសម្រាប់ អានកំសាន្ត បង្កើនប្រាជ្ញ និងបទពិសោធន៍ក្រៅពីសត្រាទេសន៍ (សត្រាសម្រាប់ ប្រើទេសនាធម៌)
- សាស្ត្រាល្បែងរួមមាន រឿងអក្សរសិល្ប៍ទាក់ ទងសាសនា, ជំនឿ, បុណ្យ, បាប, កម្ម_ផលឬពៀរវេរា ដែលឆ្លុះបញ្ចាំងតាមទ្រឹស្ដីសាសនា ដូចជា ល្បើកនគរវត្តរបស់ អ្នកប៉ាង ទាក់ ទងរឿងរាមកេរ្តិ៍, កំណាព្យជយនន្ទ១៧០២, រឿងសង្ខសិល្ប៍ជ័យ....
- ស្នាដៃអក្សរសិល្ប៍អប់ រំសីលធម៌ រួមមានច្បាប់ ប្រដៅសីលធម៌ (Codes des conduites), ច្បាប់ រាជនេត្រ, ច្បាប់ ក្រម, ច្បាប់ កឹងកន្រ្តៃ, ច្បាប់ ស្រី, ច្បាប់ ប្រុស...
- «សៀមមិនបង់ ក្បួន យួនមិនបង់ ពុត ខ្មែរសុទ § ទ្រុត មិនចោលចែចូវ...
- «បុណ្យក៏ធ្វើ ឈើក៏កាប់ សត្វក៏សម្លាប់ សីលក៏សុំ.....

# ស្នាដៃអក្សរសិល្ប៍_សាស្ត្រាល្បែង

ច្បាប់ កឹងកន្រ្តៃ មានលក្ខណៈអប់ រំខ្លួនផង និងការព្យាករណ៍ផង ដូចជា ។

- «ហ៊ីងកំប៉ោង កុំអាលអើត គីងគុកចំទើតកុំអាលថា យាលគេដើរកុំអាលថាគ្នា ក្រែងគេជាសត្រូវផង ខ្លាឈ្មោលស្វែងរកស៊ី ។ ខ្លាញីដើរទេងទោង ខ្លាពពាលខ្ទងកងកន្ទុយ រមាសមានកុយកុំពឹងព្រៃ ស្វាដំរីមានភ្លុកកុំពឹងព្រៃរនាម ក្រែងថ្ងៃវព្រៃវាតាម វាទាន់ វាបាញ់ ដួលច្រងៃ៕
- «ស្រម៉ មិនដែលទុំ ក្រមុំមិនដែលស្លូត ពពៃមិនដែលងូត ចង្កូតមិនដែលនឹង ។ខ្មោចមិនដែលសុទ § ។ព្រះពុទ § មិនដែលខឹង ។ត្រាវស្មោរមិនដែលលិច ។ស្មៅបឹងមិនដែលត្រង់ ៕

# ស្នាដៃអក្សរសិល្ប៍_សាស្ត្រាល្បែង

- «ប្រើរត្រាប់ កុកសាប់ ។កុំត្រាប់ កុក ស ប្រើត្រាប់ ឬស្សីល កុំត្រាប់ ពុតស្មាយ ។ប្រើត្រាប់ ពុត ក្ងោកកុំត្រាប់ ពុតទន្សាយ។ប្រើត្រាប់ អ្នកប្រាជ កុំត្រាប់ អ្នកខ្លៅ ។ទៅបើដើរ ទៅមានដៃ្យ ន់ុះចាប់ ៕ ងើយត្រង់ កើតស្អុក ខិនជជ្រកកើ(ត)គ្រាព្ត់ ។ចង់ ចេះប្រើស្តាប់ ។ចង់ ភ័ព្វ ប្រើឧស្សាហ៍ ។ប្រើប្រក់ ស្បូវក្លាំង ប្រើរាំងព្រះសូភារ ។ប្រើប់ ញាតិកា មានកុំម្រផ្សឹង ។បា្យ ស្រូវជាភាព្វ់ ឆ្ន ។ ប្រពុនមារជាភាព្វ់ ក្បួ ជំម្រឿស្លាប់ ជាភាព្ត់ គួយ ប្រពុន្ធជាភាព្ត់ មារ ៕ ។

- «អស្នារ្យធំចោរ កង្កែបអាច់ គោ ដេញខាំពស់ វែក អស្នារ្យ ចម្លែក។មៀមដេញខាំក្អែក ។រាត់ ចេញឆ្ងាយ អស្នារ្យ ទូ១ហាយ ម្តេចឡើយទន្សាយ មកដេញខាំឆ្កែ ពងមាន់ ដាក់ នៅរៀវរែ ។ ម្តេចឡើយមកប្រែ ពាំក្អែកហើរ ទៅឆ្កែ ស៊ុយអូស ទៅចោលកណ្តាលត្រាញ់ ។ម្តេចឡើយមកប្រែ ។ដេញខាំឯ ក្រត វិញ៕ អស្នារ្យ១ត្រពាំង រត់ រូសនូវកំលាំង។ដេញតាមអណ្តើក ទៅអស្នារ្យ ១ ត្រឡាំង ម្តេចធ្វើស្រែប្រាំង លើចុងរកា អស្នារ្យ១ណា ម្តេចសំណាញ់ បង់ ប្រា ក្នុងគុម្ពឬស្សី ។ អស្នារ្យមហិមា ម្តេចឥតពិចារណា យកខុសជាគាប់ ។រីអ្នក មានចុនភ័ព្វ រស់ នៅ គាប់ សាប់ ទៅក៏គរ។ធើស្រែមិនបាច់ ព្រយភរ។រក្សាតែមរបានស្រវសល់ ខាត។រករបស់ ពំព្រយ

# ស្នាដៃអក្សរសិល្ប៍_សាស្ត្រាល្បែង

- «អនាគតទៅ។កង្កែបនឹងដេញខាំពស់ ។ៗនឹងដេញខាំស្គារ ដំរីសារនឹងរត់ នឹងកន្ទួរបង្កងហោង ៕អ្វីធ្វើ ឱ្យបាន្ត អ្វីៗធ្វើ ឱ្យាន ធ្វើអ្វី ឱ្យផ្ទង់ ។ធ្វើអ្វីឱ្យត្រូវ ធ្វើអ្វី ឱ្យតង់ ។ធ្វើអ្វីឱ្យគង់ ។ធ្វើអ្វី ឱ្យាប់ ។រីធ្វើ ឱ្យបាន្ត ប្រើអត្ថក្រោតបាន។រំសាសទោសឆាប់ ។ រីធ្វើ ឱ្យ បាន ប្រើ ឱ្យានទ្រព្យ ប្រើផ្ទង់ ចិត្ត ស្លូ ។ច្បាស់ ច្បាប់ មាត្រា ៕ ។

- «ធម្មតាអ្នកជា អ្នកមានប្រាជ្ញា មានផៅសន្តាន មិនចេះអាងអួត។ប្រកួតរៀនកាន ចំពាក់ បំពាន បង្អួតអង្គ ៕ទោះនឹងយាត្រា។ ទៅទិសឋានណា តើដោយភុជង្គ។។សិរសាទន់ ទាប សុភាពផ្គត់ ផ្គង់ ។លំឱតឱនអង្គ ការកើ្តអ្នកជា។៕ រីអ្នកសាមាន្យ ឱ្យត់ ខ្សោយសន្តាន អាប់ ឥតប្រាជ្ញា ដំណើរឯងឱង កែងកោងហត្ថា តូច ស្ងួយសោះសារ មែនមានពិសតិច »៕

## ការបាត់បង់ធនធានមនុស្ស

- ខ្មែរស្លាប់ ដោយសារធ្វើសង្គ្រាមច្បាំងគ្នាឯងច្រើនលើកច្រើនគ្រា
- ខ្មែរស្លាប់ ដោយសារសង្គ្រាមជាមួយសៀម និងបាត់ ពល ដោយសារកៀរជាឈ្លើយ ពេលលុកលុយម្តងៗ
- ខ្មែរស្លាប់ ដោយសារជាប់ កំណែនជួយច្បាំង ឲ្យទេសជិតខាង,។ សៀម និងយួន
- ខ្មែរស្លាប់ ដោយសារកំណែនធ្វើការងារធ្ងន់ ធ្ងរ កាយដីកព្រែក និងការបង្ក្រាបកាប់ សំលាប់

## ការបាត់បង់ធនធានមនុស្ស

- នៅសម័យលង្វែកពេលជួបសឹកសង្គ្រាម គេអាចកេណ្ឌមនុស្សបានរាប់សិបម៉ឺននាក់ បាន តែមកដល់ ចុងសម័យឧដុង្គ គេអាចកែនបានបី_បួនម៉ឺននាក់ យ៉ាងលំបាក
- ពេលបារាំងគ្រប់ គ្រងដំបូងធ្វើជំរឿន ជនជាតិខ្មែរ មានមិនដល់ មួយលាននាក់ នៅពាក់ កណ្តាលទី២នៃសតវត្សរ៍ទី១៩ នេះហើយជាវិនាសកម្មសង្គ្រាមប្រមាណ២០០ឆ្នាំរបស់ ខ្មែរ
- សៀម និងយួនបានឡើងជាមហាអំណាច ក៏ដោយសារពួកគេមានប្រជាជនច្រើនដែរ

# សេចក្តីសន្និដ្ឋាន ឬសង្ខេប

- បើគេពិនិត្យលើឯកសារជាច្បាប់ ,។ក្បួនខ្នាតផ្សេងៗ, ស្នាដៃអក្សរសិល្ប៍ និងស្នាដៃខាងសាសនាដែលបង្ហាញ ឱ្យឃើញនូវចំណេះដឹង ខ្ពង់ ខ្ពស់ ។ឈ្លាសវៃរបស់ មនុស្សខ្មែរ និងអ្នកដឹកនាំខ្មែរ ។នៅឡុងសម័យក្រោយអង្គរ ។បើតាមភស្តុតាងទាំងនេះមិនសក្តិសមនឹងភាពអាប់ អោន ផុនដាបនៃនយោបាយខ្មែរ នៅសម័យ នោះដូចមានចារឹកក្នុងពង្សាវតារខ្មែរទាល់ តែសោះ ៕
- តើគេបានប្រើប្រាស់ ចំណេះដឹងទាំង នោះ ដើម្បីយកមកដឹកនាំប្រទេសដែរឬទេ?
- ខ្មែរមានសញ្ញាណនៃការអនុវត្តអភិបាលកិច្ចល្អ, ។នីតិរដ្ឋ, ។អ្នកទន់ ខ្សោយអាចស្វែងរកយុត្តិធម៌ បាន, ។អ្នកចេះខាងផ្លូវធម៌ អាចមានឱកាសក្លាយជាមន្ត្រីរាជការ
- ចម្បាំងឈ្លានពានច្រើនពេកនាំ ឱ្យខ្មែរស្លាប់ ស្ទើរអស់ ។និងត្រូវគេកៀរធ្វើជាទាសករ